

# វេជ្ជបណ្ឌិត អ.ប៉ានដើថេ៌

កំណត់ខ្មែរ

## ក្រអៅបេះដូងស្រុកខ្មែរ

Dr. A. Pannetier

Notes cambodgiennes

## Au Cœur du Pays Khmer

បកប្រែពីភាសាបារាំង

ដោយ

អ្នកស្រី ហង់សាវ័ត្យា

អតីតសាស្ត្រាចារ្យភាសាបារាំង

នេះរូបក្របសៀវភៅជាភាសាបារាំងច្បាប់ដើមដែលបានបកប្រែជាភាសាខ្មែរ៖




បោះពុម្ពលើកទី១នៅគ្រឹះស្ថានប៉ៃយ៉ូត៍ នៅប៉ារីសឆ្នាំ១៩២១។




បោះពុម្ពលើទី២នៅប៉ារីស៍ដោយមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ

នៅឆ្នាំ១៩៩៣។

# បុព្វកថា

លោកវេជ្ជបណ្ឌិតប៉ាននើថេរ៍ Pannetier មិនយល់ថាខ្មែរខ្ជិលទេ។

លោក Pannetierជាគ្រូពេទ្យជនបទ បានមកធ្វើការស្រុកខ្មែរអស់រយៈពេល១៦ ឆ្នាំ ក្នុងទសវត្សរ៍១៩០០។ ដោយសារលោកចេះភាសាខ្មែរ រស់នៅជិតស្និទ្ធនិងកសិករខ្មែរ លោកបានស្គាល់ជម្រៅបេះដូងខ្មែរ។ លោកអត់ទ្រាំនិងការតិះដៀលដោយអយុទ្ធធម៌ របស់បារាំង ថាខ្មែរខ្ជិល លោកបានសរសេរឯកសារជាប្រវត្តិសាស្ត្រដែលមានចំណងជើងថា: "Au coeur du pays khmer" ប្រែថា "ក្រអៅបេះដូងខ្មែរ" បោះពុម្ពផ្សាយដោយរោង ពុម្ព Payot, Paris ក្នុងឆ្នាំ 1921

បារាំង មកដល់ស្រុកខ្មែរ រកឈ្នួលប្រើមិនបាន បានដៀលថាខ្មែរជាជនជាតិខ្ជិល។ ហេតុអ្វីបានជាខ្មែរមិនព្រមធ្វើឈ្នួលគេ។ លោកPannetier បានពន្យល់ថា ក្នុងផ្នត់គំនិតខ្មែរ ការធ្វើឈ្នួលគេធ្វើឲ្យអាប់អោនកិត្តយស់ដែលខ្មែរមិនព្រមទទួល។ មិនត្រឹមតែផ្តល់យោបល់ផ្ទាល់ខ្លួនថាខ្មែរមិនមែនជនជាតិខ្ជិលប្រអូស លោកPannetier បានស្រង់មតិអ្នកស្រាវជ្រាវដូចជាលោកAymonier និងលោក Pavie។ លោក Aymonier បានសរសេរថា កសិករខ្មែរដែលត្រូវគេមើលស្រាលថាខ្ជិល ការពិត កសិករខ្មែរ បើគេស្គាល់ឲ្យច្បាស់ ដោយបានរស់នៅជិតស្និទ្ធជាមួយគាត់ កសិករខ្មែរមិនមែនខ្ជិលទេ គាត់មានអំណត់អត់ធន់ ធ្វើការមិនខ្លាចនឿយហត់។ លោក Aymonier បន្ថែមថា ធ្វើការជាមួយកសិករខ្មែរ លោកអាចសង់ពីរ៉ាមីត (pyramide)បាន។ ឯចំណែកលោក Pavie វិញ ដែលបានរស់នៅយូរជាមួយខ្មែរ ចេះនិយាយខ្មែរ លោកបានសរសេរថា ជំនួយការខ្មែរមានគុណសម្បត្តិធំធេង មានបេះដូងបរិសុទ្ធ មានការតស៊ូស្វិតស្វាញ មានចិត្តក្លាហានអង់អាច ក្រោមការដឹកនាំរបស់មេកើយដែលខ្លួនយល់ថាជាអ្នកដឹកនាំប្រកបដោយគុណធម៌។

ដោយ បណ្ឌិត ត័ង ប៊ុនស៊ុយ

# ស្នាដៃ លោកវេជ្ជបណ្ឌិតប៉ាននើចេរ៍ ខ្លះទៀតដែលបានបោះពុម្ពផ្សាយ៖

1- Sentences et proverbes cambodgiens, recueillis par le Docteur Pannetier, Hanoï, Impr. d’Extrême-Orient, 1916, In-4e, 25 p.

2- Lexique français-cambodgiens. Nouvelle édition complémentaire avec collaboration de M. Poulichet. Phnom Penh, Albert Portail (s.d., ca 1925). In-4°, XXXVIII+505 p.

3- Lexique français-cambodgien. Avignon, H. Auzac et J. Augier, 1907. In-8°, XXXII+441 p.

4- En collaboration avec Dr. R. Verneau, Paris, Masson (s.d.). In-8°, pp.279-317+fig (Extrait de l’ « Anthropologie », XXXI, 1921).

# *ជំពូកទី១*

## *ស្រុកខ្មែរ, ខ្មែរ ហៅ កម្ពុជាជន*

### (LE PAYS KHMER, LES KHMERS, DITS CAMBODGIENS)

ព្រះរាជាណាចក្រកម្ពុជា ឬក្រុងកម្ពុជាបានក្លាយទៅជាទឹកដីមួយរបស់ប្រូតិចតូរាឬអាណានិគមបារាំង។ ចំនួនប្រជាជននៅមានតិចតួច ឯផ្ទៃក្រឡាដីមានទំហំស្មើ ប្រហែលនឹងមួយភាគបីនៃប្រទេសបារាំង។

ប្រទេសខ្មែរមានអាកាសធាតុរបៀបជាប្រទេសក្តៅ (ត្រូពីកាល់) ហើយមានរដូវពីរគួរកត់ចំណាំ គឺរដូវក្តៅនិង រដូវភ្លៀងដែលផ្លាស់ប្តូរគ្នាក្នុង៦ខែម្តង ។ លើសពីនោះ ប្រទេសនេះនៅមានទទួលទឹក ជំនន់ដ៏ធំដែលបន្តភ្ជាប់ដោយទឹកសំរកយ៉ាងទៀងទាត់ជារៀងរាល់ឆ្នាំ។ អំណោយទានធម្មជាតិនេះ ជាជំនួយដ៏សំខាន់មួយចំពោះប្រព័ន្ធធារាសាស្ត្រក្នុងប្រទេសទាំងមូល។

កាលពីមុនមក ព្រះរាជាណាចក្រខ្មែរមានផ្ទៃដីធំទូលាយ លាតសន្ធឹងគ្របដណ្តប់រហូតដល់ទឹកដីកម្ពុជាក្រោមទាំងមូល និងលើដីមួយផ្នែកធំនៃប្រទេសស្យាម (ប្រទេសថៃសព្វថ្ងៃ) និងប្រទេសលាវ។

កាលពីព្រេងនាយគេនិយាយថា ប្រទេសខ្មែរជាប្រទេសសម្បូរណ៍សប្បាយ មានដំណាំដាំដុះ មានឈើហូបផ្លែគ្រប់កន្លែងតែ ដោយសារមានការប្រែប្រួលច្រើន សតវត្សរ៍ក្រោយៗមក ដីអស់នោះក៏ត្រូវព្រៃព្រឹក្សាទន្រ្ទានទីបន្តិចម្តងៗ ។ មិនតែប៉ុណ្ណោះ បច្ចាមិត្តរបស់ខ្មែរក៏បានបន្សល់ទុកនូវស្លាកស្នាមនៃការបំផ្លិចបំផ្លាញបន្ថែមរបស់ពួកគេ នៅសឹងគ្រប់ទីកន្លែងដែរ។

*"**សំបូររុងរឿងដូចនៅចិនឡា**" គឺជាសម្លោកដែលល្បីសុះសាយរហូតដល់ស្រុកចិននៅសតវត្សរ៍ទី៧។ ពាក្យចិនឡានេះ គឺជាឈ្មោះដែលចិនហៅប្រទេសខ្មែរនៅក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ចិនតាំងពីជំនាន់សតវត្សរ៍ទី៧នោះ ដែរ។*

*ក្នុងសម័យរុងរឿង ក្រោមរាជ្យព្រះបាទជ័យវរ្ម័នទី៧ នាសតវត្សរ៍ទី១២ រាជាណាចក្រខ្មែរមានផ្ទៃដីលាតសន្ធឹងសឹងតែពីឈូងសមុទ្រ បង់ហ្កាល រហូតដល់សមុទ្រចិន ហើយមានរដ្ឋាភិបាល ចំនួន៦០សំរាប់ជួយគ្រប់គ្រង។ ដីអាងទន្លេមេណាម (ខាងត្បូងកំពែង កំផែងផិត) ក្នុងសតវត្សរ៍ទី១១ និងដីចាប់ពីអាងទន្លេមេគង្គរហូតដល់ហ្លួងព្រះបាង ក្នុងសតវត្សរ៍ទី១៤ ក៏សុទ្ធតែជារបស់ខ្មែរទាំងអស់។ ទាល់តែដល់ឆ្នាំ១៦៥៨ ទើបកងទ័ពអណ្ណាមបានមកជាន់ទឹកដីខ្មែរកម្ពុជាក្រោមជាលើកទីមួយ។*

*ការគ្រប់គ្រងដ៏យូរលង់ច្រើនសតវត្សរ៍ បានបន្សល់ទុកនូវស្លាកស្នាមយ៉ាងក្រឡៅក្នុងប្រទេសជិតខាង ទាំងឡាយរបស់ខ្មែរសព្វថ្ងៃ។ ជនជាតិខ្មែរជាច្រើនដែលបន្តការរស់នៅក្នុងដំបន់ទាំងនោះ នៅតែរក្សាយ៉ាងខ្ជាប់នូវទំនៀមទម្លាប់ប្រពៃណី និងភាសារបស់ខ្មែរ។ មិនតែប៉ុណ្ណោះជនជាតិខ្មែរទាំងនោះតែងខិតខំរក្សាពូជសាសន៍ របស់គេឲ្យនៅបរិសុទ្ធល្អជាងអ្នកនៅខាងក្នុងប្រទេសខ្មែរសព្វថ្ងៃនេះទៅទៀត។*

ប្រជាជនដែលយើងបានឲ្យឈ្មោះថាកម្ពុជជន(១)នោះមិនចូលចិត្តការរៀបប្រមូលផ្តុំជាក្រុង ឬជាភូមិទេ (លើកលែងតែទីក្រុងសំរាប់ស្តេច ឬវាំងរបស់ស្តេច)។ លំនៅពួកគេត្រូវគេសង់លើ សសរទ្រខ្ពស់ ពីដី(កំពស់ពីរម៉ែត្រ) ពង្រាយជិតឬឆ្ងាយគ្នា តាមវាលស្រែ ឬក្នុងព្រៃ ។ ដើម្បីការរស់នៅ ពួកគេ ត្រូវពឹងផ្អែកលើធនធានធម្មជាតិទាំងស្រុង ដែលមួយភាគធំរកបានមកពីក្នុងព្រៃ ។ នេះជារូបភាពទី មួយដែលបញ្ជាក់ពីគម្លាត រវាងជនជាតិខ្មែរ និងជនជាតិអណ្ណាមដែលចូលចិត្តរស់នៅជាក្រុម ជាសហគមន៍។

គេនឹងបានឃើញនៅពេលក្រោយថា នៅក្នុងលោកនេះ គ្មានជនជាតិណាដែលរស់នៅជិតខាងគ្នាហើយមានលក្ខណសម្បត្តិផ្ទុយគ្នាស្រឡះដូច្នេះទេ។ ពាក្យថាជនជាតិខ្មែរ និងពាក្យថាជនជាតិ អណ្ណាម ជាពាក្យដែលតែងតែប្រឆាំងគ្នាសឹងតែគ្រប់ពេល ប្រៀបបាននឹងទស្សនៈ ពីរដែលផ្ទុយគ្នាស្រ ឡះ។

*ទីកន្លែងរស់នៅអាចជាកញ្ចក់មួយឆ្លុះបង្ហាញឲ្យស្គាល់មនុស្សម្នាក់បានមួយចំណែកធំ ។ តាមការយល់ ឃើញរបស់ខ្ញុំ ឫសគល់ចំបងនៃប្រាជ្ញាវាងវៃនៅក្នុងផ្នត់គំនិតខ្មែរសព្វថ្ងៃ គឺដុះឡើងដោយសារការរស់នៅក្នុងព្រៃដែលជាលំនៅដ្ឋានពិសេសនេះ ៖ ពួកគេត្រូវសម្របទៅតាមរដូវដែលប្តូរផ្លាស់ពីការរាំងស្ងួត ទៅជាជំនន់ធំ ដែលធ្វើឲ្យពួកគេរស់នៅដាច់ស្រយាលឆ្ងាយពីអ្នកឯទៀត ។ លោកអាយម៉ូនៀ បាននិយាយថា ជួនកាលផ្លូវគមនាគមន៍តែមួយ អាចប្រើជាផ្លូវសំរាប់រទេះគោផង សំរាប់ទូកផង។*

*ចំពោះជនជាតិអណ្ណាមវិញ ការនិយមរស់នៅតាមទូកសំប៉ាន រកស៊ីជាមួយទូកដ ធ្វើនេសាទតាមដងទន្លេ រស់នៅផ្តុំគ្នានៅជិតទីផ្សារ ...ក៏ជាការបញ្ជាក់ផ្នែកចិត្តសាស្ត្រចំពោះពួកគេដែរ (ជាពិសេស សំរាប់អ្នកដែលរស់នៅកម្ពុជាក្រោម)។*

តាំងពីបុរាណកាល ដោយសារការទទួលឥទ្ធិពលពីអារ្យធម៌មហិណ្ឌូ ប្រទេសខ្មែរបានរស់នៅក្រោម របបមួយគឺរបបសក្តិភូមិ។ របបនេះខុសស្រឡះអំពីរបបនាម៉ឺន ដែលមានមូលដ្ឋាននិងរដ្ឋអំណាច ដូចនៅប្រទេសជិតខាង (ខាងកើតប្រទេសខ្មែរ) ដែលបានទទួលយកពីអារ្យធម៌មចិន។ របប

សក្តិភូមិនេះជិតជាប់ជាពិសេសក្នុងសតិអារម្មណ៍របស់ប្រជាជនខ្មែរទាំងអស់តាំងពីដូនតាមកៈគេតែងរក្សាភក្តីភាពជានិច្ចចំពោះមេកើយរបស់ពួកគេ ។ ខ្សែទំនាក់ទំនងក្នុងក្រុមប័ក្សមានឥទ្ធិពលខ្លាំងណាស់សម្រាប់ខ្មែរ។

*ភស្តុតាងជាក់ស្តែងគឺ មានពាក្យ ថា "**អាង**"មានអ្នកធំការពារ..."**ពឹង**" អ្នកធំឲ្យជួយ... ។ល។ ដែលគេតែងនិយមប្រើជាទូទៅ។ ផ្នែកផ្លូវនយោបាយក៏មានការរៀបចំដោយពឹងផ្អែកទៅលើលោកម្ចាស់ទាំងនោះដែរ។ លោកម្ចាស់តែងមានទ្រព្យប្រទាន មានពួកអ្នកហែហមជាកងកម្លាំង មានខ្ញុំបំរើដាច់ថ្លៃ (ទាសាទាសី) ដែលគេវេរពីម្ចាស់មួយទៅម្ចាស់មួយតាមការទទួលថានន្តរសក្តិរបស់លោកម្ចាស់។ របបសក្តិភូមិមួយនេះ អាចមានការកែប្រែខ្លះដោយសារការប្រកាន់សាសនាក្នុងសង្គម ឬក៏ដោយសារអំណាចផ្តាច់ការរបស់ព្រះរាជាអង្គណាមួយ ដែលពេលខ្លះអាចដកហូតអំណាចនិងប្រទាន អំពីលោកម្ចាស់ទាំងនោះមកវិញដែរ។*

ទឹកដីប្រទេសខ្មែរតែងទទួលការប្រទង់ប្រទាញចង់បានអំពីសំណាក់អ្នកជិតខាងពីរនាក់ពោលគឺប្រទេសស្យាម និងប្រទេសអណ្ណាម តាំងពីច្រើនសតវត្សរ៍រួចមកហើយ។ ប្រទេសទាំងពីរនេះ ជាប្រទេសក្មេងខ្ចីដែលទើបនឹងចូលមកក្នុងទ្វីបឥណ្ឌូចិនក្រោយគេ។ ដោយសារតែអន្តរាគមន៍យ៉ាងរហ័សរបស់ប្រទេសបារាំង ទើបប្រទេសខ្មែរអាចរក្សាទុកបាននូវកេរមរតកដ៏អស្ចារ្យរបស់បុព្វបុរសខ្លួនខ្លះ ដែលសេសសល់អំពីការលោភលន់របស់អ្នកជិតខាងទាំងនេះ។ យើងពិបាកនឹកស្រម័យ ថាអាចមានការរស់ដោយរងទុក្ខទោសណាដែល លំបាកលើសពីការរងទុក្ខរបស់ប្រជាជនខ្មែរក្នុងរយៈពេលប៉ុន្មានសតវត្សរ៍កន្លងមកនេះទេ៖ គេត្រូវទទួលការរឹបអូសទ្រព្យសម្បត្តិ ទទួលការគំរាមកំហែង ទទួលការបរាជ័យរត់គេចពីកងទ័ពសៀមដែលឆ្លៀតចូលឈ្លានពានពេលរដូវប្រាំង ឬពីកងទ័ពអណ្ណាមដែលឈ្លបចូលពេលយប់នៅរដូវភ្លៀង ឆ្លៀតពេលមានទឹកជំនន់អាចប្រើទូកបាន...។ល។

ពួកសៀមច្រើនចូលមកដើម្បីកេណ្ឌកងទាសករខ្មែរយកទៅកសាងទឹកដីស្រុកគេនៅប៉ែកខាងមេណាម ។ ឯពួកអណ្ណាមច្រើនមកដេញឬសម្លាប់ខ្មែរម្ចាស់ស្រុកនៅនឹងកន្លែងដើម្បីដណ្តើមយកទឹកដីខ្មែរធ្វើជារបស់គេ។រឿងនិទាននៅតាមផ្ទះឬតាមស្រុកស្រែនៅពេលព្រលប់មុនចូលនិទ្រាច្រើនជារឿង សោកសង្រេងទាក់ទងនឹងសោកនាដ្យកម្មទាំងនេះដែលរាស្ត្រខ្មែរមិនអាចបំភ្លេចបានទេ។ ហើយខ្មែរក៏មិនអាចភ្លេចបានឡើយថា ការធ្វើអន្តរាគមន៍របស់បារាំងឲ្យមានសន្តិភាពនៅឥណ្ឌូចិន ក៏បានជួយស្រោចស្រង់ជីវិតរបស់ខ្មែរផងដែរ។

*ខ្ញុំសូមលើករឿងមួយ (ដែលគេធ្លាប់បានឮរ៉ាប់រយដងមកហើយ) ស្តីពីអំពើឃោរឃៅយង់ឃ្នង ដែលឆ្លាក់ជាប់ក្នុងដួងចិត្តជនជាតិខ្មែរមិនអាចលុបបំបាត់បាន ៖ ខ្មែរអ្នកទោសសង្គ្រាម បានត្រូវគេចាប់ចងជាក្រុម ក្នុងមួយក្រុមបីនាក់ ក្រុមខ្លះត្រូវគេកប់ក្នុងដីទាំងរស់រហូតដល់ក នៅសល់តែក្បាល ក្រុមខ្លះទៀតគ្រាន់តែត្រូវគេចងឲ្យដេករាបនឹងដី ធ្វើយ៉ាងណាឲ្យតែក្បាលពួកគេទាំងនោះអាចផ្តុំគ្នាឡើងជាម៉ុំជើងក្រានបាន។ គឺនៅលើជើងក្រានមានជីវិតនេះហើយដែលអ្នកឈ្នះសង្គ្រាមគេយកឆ្នាំងមកដាក់។ គឺនៅលើជើងក្រានដែលកំពុងភ័យរន្ធត់នេះហើយដែលគេនឹងចំអិនបាយ និងដាំទឹកឆុងតែ។ អណ្តាតភ្លើងចាប់ផ្តើមឆេះ លឺបលលូនចន្លោះលលាដ៍ក្បាលជាមុមជើងក្រានទាំងនោះ ។ ផ្សែងហុយឡើង...ងងើកបែកផ្កាភ្លើងផ្ទុះព្រោងព្រាត...។ អ្នកទោស ដកចង្កាមាន់រកដង្ហើមចុងក្រោយ... ជើងក្រានញ័ររង្គើកាន់តែខ្លាំង... តែ...សម្រែកឈឺចាប់ របស់ពួកគេនៅមិនបានយូរប៉ុន្មានទេ... ។ អ្នកកូនចៅជនជាតិអណ្ណាម ដែលកំពុងធ្វើទារុណកម្មដល់ពួកគេ ឥតមានរំភើបតក់ស្លុតនឹងទិដ្ឋភាពនេះទេ ៖ គេឈរជុំវិញជុំចង្ក្រានសម្លឹងមើលដោយគ្មានប៉ប្រិចភ្នែក មិនតែប៉ុណ្ណោះ គេថែមទាំងនិយាយចំអកឡកឡឺយបញ្ឈឺចិត្តអ្នកទោសដោយគ្រាប់ជាភាសាខ្មែរប៉ែឡាំថា ៖ "ឈប់សិនវ៉ី ! ស្ងៀមសិនវ៉ី ! កំពប់តែអុង!។ គេបញ្ជាអ្នកទោសឲ្យឈប់កំរើក ឲ្យខំទ្រាំ ឲ្យទទួលការស្លាប់ដោយស្ងប់ស្ងាត់ ដើម្បីកុំឲ្យកំពប់ទឹកតែរបស់«អុង»ដែលជាលោកចៅហ្វាយរបស់ពួកគេ។*

*ចំណែកជនជាតិស្យាមវិញ ពេលឈ្នះសង្គ្រាមលើខ្មែរក៏មានវិធីព្រៃផ្សៃយ៉ាងពិសេសសំរាប់ជាន់ឈ្លីឈ្លើយសឹករបស់ពួកគេដែរ។ ក្រោយពីបានវាយកំទេចនិងដុតបំផ្លិចបំផ្លាញទីតាំងស្រុកភូមិឲ្យទៅជាទីរហោស្ថានហើយ គេកេណ្ឌប្រជាជនដែលនៅសល់ពីស្លាប់យកទៅធ្វើជាទាសករនៅប្រទេសគេ ។ ឈ្លើយសឹកត្រូវគេចង បន្តគ្នាប្រៀបបីដូចជាសត្វធាតុដោយដោតខ្សែជាត្រណោតតាមទងស្លឹកត្រចៀក។ អ្នកណាដើរមិនលឿន ធ្វើឲ្យយឺតដំណើរក្បួនទ័ព គេគ្រាន់តែទាញខ្សែខាងចុងបន្តិចនឹងដាច់ស្លឹកត្រចៀកអ្នកនោះហើយ។ ឈ្លើយទាំងនោះត្រូវដើរជាក្បួនខ្សែយ៉ាងវែងអន្លាយកាត់វាលឆ្លងព្រៃ... សាកសព សឹងតែទាំងអស់របស់ពួកគេបានត្រូវគេបោះទុកចោលជាហូរហែលើផ្លូវនរកលោកិយនេះ...។ អនុស្សាវរីយ៍ មួយទៀតដែលរឹតតែជូរចត់នៅ ក្នុងចិត្តខ្មែរភ្លេចមិនបាន គឺទិដ្ឋភាពនៃការរំលោភលើស្ត្រីភេទខ្មែរទាំងហ្វូងៗដោយពួកមនុស្ស អ្នកជិតខាងគ្នាប៉ែកខាងលិចដ៏គួរឲ្យស្អប់ខ្ពើមទាំងនេះ។ តែមានរឿងមួយដែលគួរឲ្យខ្ញុំចាប់អារម្មណ៍គឺ គេថាពួកអាល្មោភតណ្ហានេះវានៅគោរពច្បាប់ខ្លះដែរព្រោះថាវាមិនប៉ះពាល់ស្ត្រីដែលមានប្តីហើយជាដាច់ខាត។ដូច្នេះហើយទើបគេឃើញបងប្រុសខ្មែរខ្លះស្ម័គ្រចិត្តរៀបការជាមួយប្អូនស្រីបង្កើត (ជារបៀបឧបកិច្ច)ដើម្បីជួយនាងឲ្យគេចផុតពីរឿងអាស្រូវនោះ។*

ខ្ញុំសូមសង្កត់ហើយសង្កត់ទៀតលើសេចក្តីពិចារណាពីមុននេះទាំងប៉ុន្មាន ព្រោះថាត្រូវមានការប្រយ័ត្នតាំងពីដើមទី ជៀសវាងការយល់ច្រឡំច្របូកច្របល់ ពិសេសគឺរវាងជនជាតិខ្មែរ និងជនជាតិអណ្ណាម នៅក្នុងរឿងរ៉ាវខ្លះដែលអាចបំភ័ន្តភ្នែកយើងព្រោះពេលមើលមួយភ្លែតឃើញថាហាក់ដូចគ្នា។ គេអាចសន្និដ្ឋានបានថា ជំនោរចិត្តយើងចូលចិត្តទុកដាក់ជនជាតិនៃប្រទេសទាំងពីរ ដែលជាគូបដិបក្សជានិច្ចនោះ ថាជាជនជាតិដូចគ្នា។ នេះក៏ដោយសារយើងឃើញថាគេនៅជិតខាងគ្នា មានរូបរាងប្រហាក់ប្រហែលគ្នា... តែបើមើលថយក្រោយច្រើនសតវត្សរ៍ទៅ យើងនឹងឃើញថា ការដែលយើងទុកដាក់ខ្មែរដូចជាអណ្ណាមនេះហើយដែលជាប្រភពនៃរឿងអពមង្គលចុងក្រោយ របស់រាជាណាចក្រខ្មែរ។

ក្នុងចំណោមប្រជាជនទាំងអស់នៅលើលោក ជនជាតិអណ្ណាមជាមនុស្សដែលពូកែបត់បែនបានរហ័សបំផុត ៖ ជាមនុស្សឆ្លាត ទន់ភ្លន់ រៀនឆាប់ចេះ ហើយគិតពីប្រយោជន៍ផ្ទាល់ខ្លួនណាស់។ ទោះជាមានចរឹតខ្លាំងយ៉ាងណាក៏គេចេះលាក់ហើយច្រើនបង្ហាញតែភាពសើៗខាងក្រៅប៉ុណ្ណោះ ប៉ុន្តែនៅពេលណាមានបញ្ហា ពេលនោះគេនឹងបញ្ចេញប្រតិកម្មការពារខ្លួនភ្លាម ៖ គេសម្របសម្រួលតាមស្ថានការណ៍ ហើយគេតស៊ូរហូតបានជ័យជំនះនៅទីបំផុត ។

ផ្ទុយទៅវិញ កម្ពុជជនជាអ្នកសាមញ្ញ មានចរឹតអៀនប្រៀន ចូលចិត្តនៅតែឯង..។ នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ គាត់ដូចជាជនរងគ្រោះដែលរង់ចាំតែទទួលផលលំបាកពីអំពើយង់ឃ្នងគ្រប់បែបយ៉ាងប៉ុណ្ណោះ។ តាំងពីកើតចេញពីពោះម៉ែមក គាត់តែងបានឮរឿងនិទានអំពីសម័យអង្គររុងរឿង អំពីរូបសំណាកថ្មភក់ធំៗ អំពីសិលាចារឹក... ក្នុងមួយជិវិតរបស់គាត់ៗ តែងបង្ហើរអារម្មណ៍អោយអណ្តែតអណ្តូងនៅក្នុងក្តីស្រមើស្រមៃជាមួយរូបភាពដ៏អស្ចារ្យហួសវិស័យទាំងនោះ។ រឿងរាមកេរ្តិ៍មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការរស់នៅរបស់គាត់ ៖ អ្នកដែលស្មោះត្រង់ល្ងង់ឆោតស្លូតស្លាប់ដូចគាត់នេះគឺហួស ពីវិស័យនៃការស្មាន។ ចំណែកព្រះពុទ្ធសាសនាដែលគាត់ងាកទៅតោងពេលមានអាសន្នអន្ទ្រក ក៏រឹតតែធ្វើអោយគាត់កាន់តែទន់ខ្សោយថែមទៀត។ ខ្មែរជាអ្នកមានមនោសញ្ចេតនា ចូលចិត្តស្ងឹងស្ងាធឹ ជឿស៊ប់លើព្រះពុទ្ធ។ ដោយគាត់ជាមនុស្សមានមោទនភាព គាត់ឆាប់រសើបណាស់កាលណាគេប៉ះពាល់អំពីរឿងពូជអំបូរ គាត់សុខចិត្តដកខ្លួនថយមិនប្រឆាំងតបនឹងគេវិញទេ។ គាត់មិនទប់ទល់នឹងគេទេ សុខចិត្តបន្ទាបខ្លួន សុខចិត្តរត់ទៅអោយឆ្ងាយ ឬពួនអោយបាត់ យកព្រះពុទ្ធឬប្រពៃណីទំនៀមទំលាប់មកធ្វើជាខែលបិទបាំង។ គាត់សុខចិត្តត្រឡប់ទៅចូលព្រៃ ទៅរស់នៅជាមនុស្សព្រៃពាក់កណ្តាលដូចពីដើមកំណើតរបស់ពួកគាត់វិញ។

*ប្រវត្តិសាស្ត្រខ្មែរបានចារទុកអំពីរឿងបះបោរមួយចំនួនរបស់ប្រជាជនក្នុងស្រុកដូចជាការបះបោរមួយនៅដំបន់កំពត នាថ្ងៃ១៤មេសាឆ្នាំ១៩០៩ ក្រោមការដឹកនាំរបស់មនុស្សម្នាក់ដែលជឿជាក់ថាខ្លួនគេបានទទួល តាំងពីកំណើតនូវស្លាកសម្គាល់គិត្យានុភាពអធិធម្មជាតិ។ គាត់ចង់ស្តារប្រទេសជាតិអោយបានល្អរុងរឿងដូចសម័យដើមឡើងវិញព្រោះគាត់ជឿថាខ្លួនគាត់ពិតជាអវតារបស់វិរបុរសធំខ្មែរណាមួយកាលពីជាតិមុនៗ ។ ព្រឹត្តិការណ៍ទាំងអស់នេះច្រើនកើតមាននៅរដូវប្រាំង គឺពីខែធ្នូទៅខែឧសភា (ព្រោះជាពេលដែលពួកគេអាចជួបជុំគ្នានៅក្នុងព្រៃឬលើភ្នំបាន) ក្រោយពេលដែលគេបានរៀបចំពិធីបន់ស្រន់ ដោយមានការកាន់តំណមជាច្រើនដូចជាការអត់បាយហូបតែល្ងជាដើមដើម្បីសូមជ័យជំនះនិងសូមការការពារជីវិតអំពីវត្ថុសក្តិសិទ្ធិទាំងឡាយហើយ។លុះពេលវេលាល្អមកដល់ ពួកអ្នកបះបោរដែលអាចមានគ្នាពីប្អូនដប់នាក់ទៅពីរបីរយនាក់ ក្បាលកោរត្រងោលដូចលោកសង្ឃ ទ្រូងបញ្ចេញសាក់យ័ន្តនិងពាក់ខ្សែគាថាពេញខ្លួន ខ្លះកាន់បាដា ខ្លះកាន់លំពែង ខ្លះកាន់កាំភ្លើងចាស់ ដែលប្រើឆ្នួនថ្មឬ Piston ។ គេនាំគ្នាដើរហែរជាក្បួនទៅតទល់ជាមួយកងទ័ពរាជការដែលឈរចាំនៅពីមុខហើយស្រេច រង់ចាំតែបំបែកពួកគេជានិច្ច។*

ដូច្នេះហើយទើបយើងត្រូវយល់ថា តើយើងត្រូវមានសេចក្តីអំណត់និងចេះបញ្ចុះបញ្ចូលដោយទន់ភ្លន់យ៉ាងណាខ្លះក្នុងប្រទេសនេះ លើសពីកន្លែងដទៃ ដើម្បីស្វែងរកការពិត (ដូចជាផ្នែកតុលាការជាដើម) ជាមួយប្រជាជនទាំងអស់នេះដែលស្លូតត្រង់ផង ដែលចូលចិត្តគោរពអ្នកមានអំណាចមានបុណ្យសក្តិជាអ្នកធំផង ហើយគោរពច្បាប់ទម្លាប់ផង។ មួយវិញទៀតគេមានទម្លាប់ឲ្យចម្លើយតម្រូវតែទៅតាមចិត្តអ្នកសួរចង់បានប៉ុណ្ណោះ គេមិនមែនយកការពិតជាធំឡើយ។ យើងដឹងទៀតថា អ្នកស្រុកដែលនៅធ្វើការជាមួយយើងមានថ្វីដៃពូកែណាស់ខាងជំរុញយើងឲ្យធ្វើអ្វីមួយដើម្បីបង្ក្រាបប្រជារាស្ត្រអ្នកនៅក្នុងភូមិឲ្យខ្លបខ្លាចយើង។ ពួកគេធ្វើរឿងនេះនៅតែនឹងមុខយើងដោយមិនឲ្យយើងដឹងខ្លួនមុនទេ។

ឆ្លៀតពេលដែលប្រទេសខ្មែរមានបញ្ហានយោបាយនិងសេដ្ឋកិច្ចប៉ុន្មានសតវត្សរ៍មុននេះ ព្រះពុទ្ធសាសនាបានមកតាំងទីនៅតំបន់នេះជាមួយជនជាតិសាសន៍ ដែលបានរក្សាទម្លាប់សាមញ្ញរហូតមកតាំងពីជំនាន់តទ្ធិពលតណ្ហា។ ដូច្នេះចិត្តមេត្តាធម៌ ស្មារតីលះបង់ ការសូមតែសុខ ក៏រឹតតែជ្រួតជ្រាបក្នុងផ្នត់គំនឹតប្រជាជនទាំងនេះ។ ពពួកគេគ្រប់វណ្ណៈ (លើកលែងតែអ្នកក្ររហាមចេញ) ចូលចិត្តនាំគ្នាចូលសាងផ្នួសចាប់ពី ២ឬ៣ថ្ងៃរហូតអស់មួយជិវិតក៏មាន។ តែជាមធ្យមគឺពី២ទៅ៣ឆ្នាំ។ ឯការលាចាកសិក្ខាបទវិញក៏ស្រួល ឲ្យតែអស់និស្ស័យហើយ គេរៀបចំពិធីបុណ្យមួយដើម្បីដោះ

ស្បង់ចីពរចេញជាការស្រេច ព្រោះថាការថ្វាយខ្លួនក្នុងព្រះពុទ្ធសាសនាមិនមែនជាចំណងជាប់មួយជិវិតទេ។

ក៏ប៉ុន្តែ ដើម្បីជៀសវាងភាពមន្ទិលសង្ស័យចំពោះគេរឈ្មោះព្រះសង្ឃដែលសុំលាសិក្ខាបទ គេហាមមិនឲ្យអ្នកចាកផ្នួសនេះរៀបការជាមួយស្ត្រីដែលជាក្រុមគ្រួសាររបស់គ្រូបព្វជិត ឬក៏រស់នៅក្នុងភូមិជុំវិញវត្តអារាម(អ្នកជើងវត្ត)របស់ ព្រះសង្ឃនេះទេ។

តាមយើងស្មាន ព្រះសង្ឃខ្មែរពិតជាមានកិត្យានុភាពយ៉ាងខ្លាំងនៅក្នុងទូទាំងប្រទេស ។ ដោយសារថាសេចក្តីត្រូវការរបស់ព្រះសង្ឃមិនច្រើនហួសហេតុ មិនពិបាកដោះស្រាយ ជាពិសេសនៅក្នុងស្ថានភាពធាតុអាកាសស្រុកនេះ អ្នកស្រុករឹតតែគោរពលោកកាន់តែខ្លាំងឡើង ផ្ទុយពីអ្នកនៅលើទឹកដីអណ្ណាមដែលគេមិនឲ្យតម្លៃដល់ព្រះសង្ឃទេ។

គេអាចទាញយកផលប្រយោជន៍ជាច្រើនសំរាប់ការវិវត្តន៍របស់កម្ពុជាទៅថ្ងៃមុខអំពីរចនាសម្ព័ន្ធនៃប្រពៃណីនេះដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹង ចិត្តសាស្ត្រផង សង្គមសាស្ត្រផង របស់ប្រជាពលរដ្ឋ។

ព្រះសង្ឃទាំងនេះដែលភាគច្រើនជាអ្នកមកពីស្រែ មិនសូវរើសអើងការងារហត្ថកម្មដូចនៅប្រទេសស្យាមទេ។ ក្នុងចំណោមសង្ឃទាំងនោះមានអ្នកពូកែធ្វើការមិនចេះហត់ គឺចេះធ្វើតដ្ឋ ចេះកាប់ឧសចេះជួសជុលនាឡិកា អាចជាឧស្សាហករ ឬសិល្បករ អាចជាអ្នកបណ្តុះបណ្តាលចំណេះសំរាប់ធ្វើជាមុខរបរដល់អ្នកស្រុខនៅជុំវិញវត្ត។

*ធម៌បញ្ចសិលា ឬសីល៥ ជាធម៌ដែលប្រជារាស្ត្រទូទៅទុកជាច្បាប់សំរាប់ត្រេងត្រាប់ក្នុងការរស់នៅរាល់ថ្ងៃ ៖ ទី១មិនបៀតបៀនជិវិតគេ ទី២មិនយកទ្រព្យរបស់គេ ទី៣មិនយកប្រពន្ធឬប្តីអ្នកដទៃ ទី៤មិននិយាយភូតកុហក ទី៥មិនផឹកទឹកស្រវឹង។ដើម្បីជៀសវាងមិនសម្លាប់សត្វមូសដែលមកខាំលោក ព្រះសង្ឃតែងយកដៃទៅ»បបោស»ដើម្បីដេញសត្វមូសនោះចេញ។*

*ធម៌ទសសីលាឬសីល១០ជាសីលសំរាប់ព្រះភិក្ខុសង្ឃ ៖ មេត្តា ករុណា មុតិតា(ចិត្តជ្រះថ្លានឹងបុណ្យទាន) ឧបេក្ខា សច្ច(ទៀងត្រង់) សប្បុរិសធម៌ គតិបណ្ឌិត ស្មោះត្រង់ ខ្លាំង មោះមុត...(តាមសៀវភៅ «ព្រះពុទ្ធ« របស់លោកអុលដិនបែរ)* ។

អ្នកសង្កេតការមួយចំនួនដែលមិនបានពិចារណាវែងឆ្ងាយ ឆាប់ចាប់ថ្នាក់ជនជាតិខ្មែរថាជាមនុស្សខ្ជិលច្រអូសព្រោះថាខ្មែរមិនសូវពូកែធ្វើជាអ្នកស៊ីឈ្នួលបំរើគេក្នុងផ្ទះទេ។ ក៏ប៉ុន្តែ យើងគួរយករឿងនេះមកវែកញែកឲ្យបានល្អិតល្អន់ ព្រោះថារឿងនេះទាក់ទងនឹងការអប់រំផង និងផ្លូវចិត្តសាស្ត្រផង។

អ្នកខ្លះប្រហែលមិនដឹងទេថា ពាក្យ «ស៊ីឈ្នួល» ឬ យកប្រាក់ខែ កាលពី សម័យមុនយើងនេះបន្តិច មានន័យថាជននេះរស់នៅក្នុងរបបសក្តិភូមិមែនតែគ្មានអ្នកធំការពារ គ្មានអ្នកធំរាប់អាន៖ គឺជារឿងដែលមិនអាចមានទៅកើតទេ ព្រោះថា បើដូច្នេះមែន ឋានៈគេត្រូវទាបជាងពពួកទាសករទៅទៀត។ ពាក្យថា«ស្រីឈ្នួល» បានត្រូវគេឲ្យនិយមន័យថា «ស្រីពេស្យា» ព្រោះពាក្យក្រោយនេះ និងអាជីពនេះមិនទាន់មាននៅជំនាន់នោះនៅឡើយទេ។ សព្វថ្ងៃនេះក៏ដោយ អ្នកទេសចរដែលមកដល់ស្រុកខ្មែរលើកទីមួយក៏អាចសង្កេតឃើញដែរថានៅក្រុងភ្នំពេញ និងនៅគ្រប់ទីតាំងព្រះរាជាណាចក្រខ្មែរ គេមិនអាចរកបានខ្មែរធ្វើជា«គូលីធាក់ស៊ីក្លូ» ទេ ទោះបីជាអ្នកនោះក្ររហេមរហាមយ៉ាងណាក្តី។ តែប៉ុន្តែសព្វថ្ងៃនេះ អ្នកដែលចូលចិត្តហត្ថពលិកខ្មែរមានកាន់តែច្រើនឡើងៗហើយ សូម្បីពួកនិគមជន ពួកសហគ្រិន ពួករាជការ ឬជាយោធាក៏ដោយ។ មានម្នាក់ក្នុងចំណោមអ្នកទាំងនោះ ចូលចិត្តនិយាយដដែលៗថា៖ «ជាមួយខ្មែរ ខ្ញុំចង់សាងសង់ប្រាសាទពីរ៉ាមីឌ!»។នៅក្នុងឯកសារដ៏សំខាន់មួយរបស់លោក អាយម៉ូនៀ Aymonier ឈ្មោះថា «កម្ពុជា Le Cambodge» លោកបានសរសេរតាំងពី២០ឆ្នាំរួចមកហើយថា៖ «អ្នកស្រែមិនគួរទទួលការតិះដៀលថាជាមនុស្សខ្ជិលច្រអូសដូចអ្នកនិពន្ធប្រទេសអឺរុបមួយចំនួនដែលតែងសរសេរចម្លងតាមគ្នាទៅវិញទៅមកនោះទេព្រោះ គេជាមនុស្សយឺតមែន តែមានអំណត់ មិនចេះត្អូញត្អែរពីការងារ...»។ ហើយម្យ៉ាងវិញទៀត បើមានគេមកពីក្រៅរកស៊ីកើតមានបាននៅស្រុកខ្មែរ (ពួកចិន ឬក៏សាសន៍ដទៃផ្សេងទៀត) ក៏ដោយសារតែមានអ្នកនៅក្នុងស្រុកខំប្រឹងប្រែងធ្វើការងារដើម្បីបង្កើតភោគផល ឲ្យគេដែរ។

តាមការពិតទៅ ខ្មែរសព្វថ្ងៃនេះ ដែលមានគុណសម្បត្តិផ្នែកសិល្បៈតាំងពីកំណើតមក ទោះបីគេខំចិញ្ចឹមក្នុងចិត្តថាខ្លួនគេមានពូជអំបូរជាអ្នកថ្លៃថ្នូរ មានមោទនភាពនឹងកើតមកជាខ្មែរ ខំរក្សាយ៉ាងខ្ជាប់ខ្ជួននូវកេរមរតកដ៏មានតម្លៃរបស់បុព្វបុរសខ្លួនយ៉ាងណា ក៏នៅតែមិនមានការទុកចិត្តលើខ្លួនឯង ព្រោះថា ការទុកចិត្តនឹងកើតមានឡើងបាន លុះត្រាតែធ្លាប់បានជួបស្គាល់ជោគជ័យ។ ដូច្នេះត្រូវតែមានការបណ្តុះបណ្តាលឡើងវិញអំពីរឿងទំនុកចិត្តនេះ ដោយត្រូវរក«គន្លឹះ»វាឲ្យឃើញ។ មនុស្សយើងម្នាក់ៗតែងធ្លាប់បានស្គាល់ការខ្វះទំនុកចិត្តលើខ្លួនឯងនេះ ខ្លាំង ឬតិចទៅតាមរឿងរៀងៗខ្លួន។សេចក្តីខ្លាចធ្វើឲ្យគេបាត់បង់មធ្យោបាយអស់។ បើចង់ឲ្យគេបានរីកចំរើនទាល់តែឲ្យគេមានទំនុកទុកចិត្តលើអ្នកដទៃផង។នេះជាមូលហេតុនៃការវាយតម្លៃប្លែកៗខាងលើមុននេះ។

ក៏ប៉ុន្តែ តើការទន់ខ្សោយដែលថាមកពីស្រុកធ្លាក់ក្នុងភាពដុនដាបនេះវាត្រូវនៅជាប់ជាអលង្កាស្រង់លែងរួច មើលលែងជាហើយឬ? តើអ្នកណាហ៊ានអះអាងដូច្នេះ? តាមពិត ការនៅស្ងៀមមិនកំ

រើកនេះគ្រាន់តែជាប្រតិកម្មការពារខ្លួនដោយការប្រឹងអត់ធ្មត់មិនតបតប៉ុណ្ណោះព្រោះគេរស់នៅក្នុងស្ថានភាពមួយ ក្នុងបរិយាកាសមួយដែលខ្វះការស្មើភាព។

អ្នកណាដែលធ្លាប់បានសាកល្បង ក៏បានឃើញហើយថាតើគេបានទទួលផលប្រយោជន៍អ្វីខ្លះពីខ្មែរ ពេលណាដែលគេបានទាក់ទាញមនោសញ្ចេតនាខ្មែរម្នាក់នោះឲ្យមានការទុកចិត្តមកលើគេហើយ។ អ្នកណាដែលមានទំនាក់ទំនងជិតដឹតស្និទ្ធស្នាលដោយស្មោះជាមួយខ្មែរ ក៏អាចធ្វើជាសាក្សីបានដែរថា តើខ្មែរជាមនុស្សមានមនោសញ្ចេតនាខ្លាំង ឆាប់រំភើបហើយស្មោះយ៉ាងណាចំពោះអ្នកមានគុណ ឬចំពោះនាយចៅហ្វាយ ។ គ្មានរាស្ត្រឯណាដែលគេអាចដឹកនាំបានដោយស្រួល និងដោយសប្បាយចិត្តយ៉ាងនេះទេ។ ហើយមានតែអ្នកដែលបានស្គាល់ខ្មែរច្បាស់ដោយសារបានរស់នៅជិត ធ្លាប់បានថ្លឹងចិត្ត ធ្លាប់បានឆ្លុះមើលព្រលឹងខ្មែរនេះទេ ទើបអាចដឹងថាតើខ្មែរអាចធ្វើអ្វីខ្លះដើម្បីបង្ហាញការដឹងគុណ បង្ហាញការស្រឡាញ់នាយចៅហ្វាយដោយស្មោះ ឥតគិតដល់ផលប្រយោជន៍ផ្ទាល់ខ្លួននេះ។

យើងងាកទៅមើលសមុច្ច័យឯកសារការងាររបស់ក្រុមបេសកកម្មប៉ាវី Mission Pavie Indochine (1879-1895) វិញម្តង។ លោកប៉ាវីដែលជាអ្នកស្វះស្វែងរុករកដ៏ស្ទឹតស្ទាញម្នាក់ លោកចេះភាសាខ្មែរយ៉ាងស្ទាត់ អាចនិយាយជាមួយពួកខ្មែរដែលធ្វើការជាមួយលោកបាន ដូច្នេះលោកបានស្គាល់ខ្មែរច្បាស់ណាស់ ហើយបាននៅជិតដឹតជាមួយយ៉ាងយូរទៀតផង។ គាត់បានយល់អំពីរបៀបទាក់ទងជាមួយខ្មែរ ធ្វើយ៉ាងណាទាក់ទាញខ្មែរឲ្យជួយធ្វើការងារដ៏ធំធេងច្រើនវែងអន្លាយហើយមានតម្លៃរបស់គាត់។ រាល់ពេលដែលគាត់និយាយអំពីរឿងខ្មែរ គាត់តែងរំលឹកអំពី៖ «*ជនជាតិមួយដែលមានគុណសម្បត្តិខ្លាំងក្លា មានមនោសញ្ចេតនាទូលំទូលាយ តែអ្នកភាគច្រើនចេះតែយល់ច្រឡំចោទប្រកាន់ផ្តេសផ្តាសហាក់មានកម្មតាមមកផ្តន្ទា*»......«*គុណសម្បត្តិនៃចិត្តថ្លើមគេ សេចក្តីក្លាហានក្នុងការបំរើអ្នកដែលគេបានទទួលយកជាមេកើយ*» (ភាគទី១ទំព័រ៨៣និង២០០)។ និយាយក៏មិនអស់ដែរ ទាល់តែអានឯកសារទាំងអស់នោះទើបដឹងថាលោកប៉ាវីស្រឡាញ់និងលើកតម្លៃខ្មែរយ៉ាងណា។ បើសិនជាអ្នកចង់ទៅនៅជិត ឬចង់ស្គាល់ខ្មែរ យ៉ាងហោចណាស់ក៏គួរអ្នកបានអានដោយយកចិត្តទុកដាក់នូវបុព្វយោគនៃឯកសារទាំងនេះដែរ។ តើមានអ្វីដែលបង្ហាញនូវភាពស្រស់ញញឹមកក់ក្តៅ រំភើបនិងគួរឲ្យជក់ចិត្តជាងការរៀបរាប់របស់លោកប៉ាវីស្តីពីការគាត់ជួបខ្មែរជាលើកដំបូងនោះ?

អំពីបញ្ហានេះ មានលក្ខណៈពីរដែលគួរឲ្យយើងចាប់អារម្មណ៍៖ ផ្នែករាងកាយ គេមានភិនភាគជាមនុស្សមាំខ្លាំងលើសមធ្យមភាគនៃជនជាតិជិតខាង។ បើផ្នែកសីលធម៌វិញ អ្នកនិពន្ធទូទៅ

តែងទទួលស្គាល់ថាគេមានចរិយាមារយាទស្រគត់ស្រគំជាងអ្នកនៅស្រុកជិតខាងឆ្ងាយណាស់។ សិល្បៈរបស់ខ្មែរក៏មានលក្ខណៈពិសេសមួយដែរគឺ ការការពារបិទបាំងភាពអៀនខ្មាស ។ ហើយគេឮល្បីទៀតថាព្រះសង្ឃខ្មែរ ជាសង្ឃដែលមានការប្រកាន់វិន័យតឹងតែងស្របទៅតាមគន្លងធម៌នៃព្រះពុទ្ធ។ ពេលគេធ្វើដំណើរកាត់ស្រុកស្រែចំការនៃប្រទេសកម្ពុជា អ្នកណាមិនចាប់អារម្មណ៍នឹងអ្នកស្រែមាឌមាំ មានទំរង់មុខពេលខ្លះដូចជនជាតិពូជ«កូកាស traits caucasiques» រូបសរាយរាក់ទាក់ស្លូតបូតទៀងត្រង់ ជឿគេស្លូតស្លាប់ ដែលរស់នៅជិតក្បែរយើងនេះសោះ? តើអ្នកណាមិនចូលចិត្តនឹង ការរាប់អានដោយភាពស្មោះត្រង់ ដោយគ្មានចំណង គ្មានគិតពីផលប្រយោជន៍របស់គេ? ឲ្យតែឮសំដីផ្អែមល្ហែម ទឹកមុខគេរីកទទួលភ្លាម។ បើឮលោកធំចេះនិយាយភាសារបស់ខ្លួនផង អ្នកធ្វើការច្បាស់ជាបាត់ហត់នឿយភ្លាម រីអ្នកជាប់ចោទវិញក៏បែរជាសុខចិត្តសារភាពតាមសម្រួល! (ជារឿងមួយដែលកម្រជួបប្រទះនៅចុងបូព៌ាប្រទេស)។

*លោក អាយម៉ូនៀ Aymonier បាននិយាយអំពីស្ត្រីក្រមុំខ្មែរថា ៖ «ចរិយាមារយាទរបស់នាងអាចយកទៅប្រឡងប្រជែងជាមួយក្រមុំទាំងឡាយលើពិភពលោកនេះបាន»។ នាងបានទទួលការអប់រំក្នុងគ្រួសារឲ្យនាងមានភាពស្រគត់ស្រគំដោយ ការរស់នៅឆ្ងាយពីភ្នែកមនុស្សទូទៅចាប់ពីអាយុ១២ទៅ១៥ឆ្នាំ ពោលគឺដោយ«ចូលម្លប់»។ គេតែងរៀបចំពិធីបុណ្យធំដែលគេរក្សាទុកនៅតាមស្រុកស្រែដល់សព្វថ្ងៃ ទីមួយ «បុណ្យចូលម្លប់» និងទីពីរ «បុណ្យចេញម្លប់»។ រយៈពេលចូលម្លប់នេះអាចយូរឬឆាប់ទៅតាមធនធានរបស់ឪពុកម្ដាយនៃកូនក្រមុំ (ច្រើនថ្ងៃ ឬច្រើនឆ្នាំ)។*

យោងតាមការរៀបរាប់ខាងលើ តើយើងនៅតែសង្ស័យយ៉ាងដូចម្ដេចទៀតលើប្រជារាស្ត្រដែលមានសុខភាពមាំមួនល្អ ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ជាសុខភាពដែលធានា ចំពោះហាមពល«លាក់ទុកមិនទាន់បញ្ចេញ» នេះ? គ្រាន់ តែមានសេចក្ដីអំណត់បន្តិច មានការស្រឡាញ់ទុកចិត្តដោយស្មោះ រឿងអីដែលថាមិនអាចទាញយកផលប្រយោជន៍បាន បើយើងក៏ធ្លាប់មានស្មារតីសាមគ្គីធម៌រវាងមនុស្សទាំងឡាយ ទូលំទូលាយដែរនុះ!

***

******

បច្ចុប្បន្ននេះយើងអាចយល់និងវាយតម្លៃឲ្យព្រឹត្តិការណ៍មួយចំនួនធំ ដែលសឹងតែមិនអាចជាក់នៅទីណាក្រៅអំពីនេះបាន។ ឧទាហរណ៍ជាក់ស្ដែងដូចជា កាលពីឆ្នាំ១៩០៨ លើកទីមួយដែលយើងត្រូវចាក់ថ្នាំការពារនឹងជម្ងឺប៉េស្ដ la peste នៅជុំវិញរាជធានីភ្នំពេញមានការភ័យស្លន់ស្លោដោយមានពាក្យចចាមអារាមថា ពួកពេទ្យជនជាតិបារាំងដែលមកចាក់ថ្នាំឲ្យនេះ គឺជាពួកប្រមាត់

ប្រមង់ចាប់ក្មេងវះពោះខ្ទេះយកប្រមាត់។ ប្រជាជនគាត់នៅចងចាំរឿងថ្មីៗមុននេះពេលដែលមានក្រុមចោរសាហាវដើរកាប់សម្លាប់រាស្ត្រអ្នកស្រែស្លូតត្រង់ដើម្បីខ្វេះយកប្រមាត់យកទៅជូនអស់លោកធ្វើថ្នាំ កាលនោះពួកគាត់សម្ងំពួនក្នុងផ្ទះមិនហ៊ានចេញទៅណាទេ។

ក្នុងសម័យកាលនោះដែរ មានរឿងមួយទៀត៖ អ្នកស្រុកស្រែខ្លះល្ងង់ពេក សុខចិត្តបង់ពន្ធដារ ឲ្យទៅជនពាលខ្លះដែលដើរអះអាងថាពួកគេជាអ្នកហូតពន្ធជូនប្រទេស«ព្រះអាទិត្យរះ» គឺប្រទេសជប៉ុននេះឯង។រហូតដល់ពេលដែលគេទ្រាំលែងបាន នឹងការជិះជាន់ជ្រុលហួសហេតុពេកពួករាស្ត្រស្លូតត្រង់នេះក៏កញ្ជ្រោលបះបង្រះនាពេលថ្មីៗនេះ កាលពីខែមករានិងកុម្ភៈឆ្នាំ១៩១៦ ៖ មនុស្ស១០ម៉ឺននាក់ ដែលធ្លាប់តែស្លូតដូចកូនចៀម បាននាំគ្នាបះបោរដើម្បីបញ្ចេញកំហឹង។ តែពេលនោះពួកគេឥតមានប៉ះពាល់ដល់ខ្លួនប្រាណមេកើយជាជនជាតិបារាំង (គយ ឬមេព្រៃ...ដែលរស់នៅដាច់ស្រយាលតែឯងក្នុងព្រៃ) ណាម្នាក់ឡើយ។

*បារាំងដែលរស់នៅជាមួយជនជាតិខ្មែរតែងបានដឹងឮគ្រប់ៗគ្នាថា ពួកនេះនាំគ្នាបះបោរក៏ព្រោះតែការឈឺចាប់ក្នុងចិត្ត ព្រោះតែការរំលោភគ្រប់បែបយ៉ាងដែលប្រជាជនខ្មែរតែងទទួលរងគ្រោះតាំងពីយូរមកហើយ ៖ គឺជារឿងមួយដែលពួកបារាំងមួយចំនួនគេគាំទ្រព្រោះគេយល់ឃើញថាការបះបោរនេះជារឿងត្រឹមត្រូវ។*

ក្រោយនេះគឺជាចំណុចមួយទៀតដែលចង្អុលបង្ហាញឲ្យរឹតតែច្បាស់នូវគម្លាតនៃប្រតិកម្មរបស់ជនជាតិទាំងពីរ។ ពេលដែលម្នាក់តវ៉ាស្រែកឡូឡា ម្នាក់ទៀតខំទ្រាំសម្ងំនៅស្ងៀម ៖នៅក្នុងឆមាសទីមួយនៃឆ្នាំ១៩១៦ បារាំងបានធ្វើអំពើភាន់ច្រឡំមួយ ដូចនៅកូសាំងស៊ីន(កម្ពុជាក្រោម)ដែរ នៅពេលដែលគេត្រូវការរើស«អ្នកស្ម័គ្រចិត្ត»ចូលធ្វើជាទាហានចម្បាំង។ នៅទីនេះ គ្រាន់តែបំពាក់ខ្មោះលើស្មារតីក៏គ្រប់គ្រាន់ទៅហើយ មិនចាំបាច់ធ្វើទារុណកម្មលើរាងកាយទេ ព្រោះពួកគេខ្លបខ្លាចពួកអាជ្ញាធរដែលដើរទៅប្រមូលពួកគេណាស់។ នៅពេលគេទៅកត់ឈ្មោះ « អ្នកស្ម័គ្រចិត្ត ទាំងនោះ» ញ័រខ្លួនចំប្រប់ ដូចទន្សាយជាប់អន្ទាក់ តែនាំគ្នាចេញមកប្រកាសយ៉ាងក្លាហានថាចង់ចុះឈ្មោះធ្វើជាទាហានទៅច្បាំង។ បុរសម្នាក់ មានកូនដល់ទៅ៨នាក់ ក៏មកចុះឈ្មោះនឹងគេដែរ។ ទាល់តែទៅដល់ភ្នំពេញ ក្រុមអ្នកជំរើសគេសាកសួរដោយប្រើពាក្យលួងលោមទន់ភ្លន់ទៅទើប«អ្នកស្ម័គ្រចិត្តទាំងនោះហ៊ានសារភាពអំពីទឹកចិត្តពិតប្រាកដរបស់គេ។

នៅទីកន្លែងឆ្ងាយដាច់ស្រយាលខ្លះ(ដូចជានៅ«ថ្កង់លើ»ជាដើម) បើមានមនុស្សទុច្ចរិតណាម្នាក់ហ៊ានមកក្អេងក្អាងថា៖«ក្របីនេះជាក្របីរបស់ខ្ញុំពីមុន ខ្ញុំស្គាល់ច្បាស់ណាស់ ខ្ញុំត្រូវនាំវាទៅវិញហើយ» ទោះនៅនឹងមុខ ក៏ម្ចាស់ពិតប្រាកដឥតហ៊ានឈ្លោះប្រកែករកខុសត្រូវជាមួយចោរដែរ យ៉ាង

ច្រើនគ្រាន់តែតវ៉ាបន្តិចបន្តួចប៉ុណ្ណោះព្រោះខ្លាចអំណាចគេ។ មានរឿងមួយទៀតគឺថា រាល់ឆ្នាំ ដើម្បីជំរុញឥទ្ធិពលលើតម្លៃស្រូវ ពួកឈ្មួញចិនច្រើនតែបង្ហោះរឿងវ៉ាវផ្សេងៗដែលហួសពីជឿបាន តែអ្នកស្រែនៅតែជឿគេជាដរាប។

&&&&&&&

## ជំពូកទី២
## អំពីមន្ត្រីរាជការខ្មែរ

ហេតុផលដែលយើងបានទាញមកនិយាយពីមុនពិតជាអាច ពន្យល់បានអំពីបញ្ហាមួយចំនួនដែលមាននៅតាមគ្រប់វិស័យសកម្មភាពរបស់យើង ហើយក៏អាចបន្ធូរបន្ថយការវាយតម្លៃទៅលើលទ្ធផលដ៏តិចតួចបំផុតដែលយើងបានទទួលដែរ។ ហេតុផលទាំងនេះវាគ្របសង្កត់លើនយោបាយផ្ទៃក្នុងទាំងមូល។

មុខតំណែងមន្ត្រីទាំងអស់នៅតែរក្សាភាពជំនាន់ដើម គឺប្រៀបបីដូចជាកសិដ្ឋានមួយ ដែលគេជួលឲ្យទៅអ្នកណាដែលហ៊ានឲ្យថ្លៃលើសគេ ឬអ្នកណាដែលចេះដើរផ្លូវវៀច។ បើយើងមានស្គាល់មន្ត្រីណាម្នាក់ជិតដិត គេពិតជាមិនខ្លាចអ្វីនឹងអួតប្រាប់យើងទេថា តើគេបានទិញកន្លែងធ្វើការនេះ អស់ថ្លៃប៉ុន្មាន។ ភាសាស្តេចថា«សោយរាជ្យ»មានន័យថាស្តេច«គ្រប់គ្រងរាជ្យ» តែគេ អាចប្រែតាមរបៀបលេងសើចថាស្តេច«ស៊ីរាជ» ឯចំណែកអស់លោកមន្ត្រីក៏«ស៊ី»តំណែងរបស់គាត់ដូចគ្នាដែរ។

*រហូតមកដល់ប៉ុន្មានឆ្នាំក្រោយនេះ មានកសិដ្ឋានសម្ងាត់មួយ គ្រប់គ្រងដោយពួក«អាជ្ញាហ្លួង» ដែលជាអ្នកធ្វើការហូតពន្ធស្រូវដោយ ភាគច្រើន មិនទាំងឲ្យបង្កាន់ដៃទៅអ្នកបង់ផង។*

*បើយើងយកពាក្យគួរស្អប់ខ្ពើម របស់យើងមកប្រើក្នុងករណីនេះ ដូចជាពាក្យថា «វីតិក្រម ឬការស៊ីសំណូក» ពាក្យថា«អាងអំណាច» ។ល។ ហាក់ដូចជាមិនតំណាងការពិតជាក់ស្តែងសោះ ព្រោះថា ទង្វើនេះក្លាយទៅជាទំនៀមទម្លាប់ប្រពៃណី ដែលគ្រប់គ្នាទទួលយកទៅហើយ។ ខ្ញុំមានស្គាល់ចៅហ្វាយខេត្តខ្លះដែលមានទម្លាប់នៅពេលបើកប្រាក់ខែម្តងៗ (ប្រហែល១០០ត្រណោត) តែងតែទុកប្រាក់៥ត្រណោតឲ្យស្មៀនរបស់លោករ៉េស៊ីដង់បារាំងជានិច្ច។ បើសិនលោកខេត្តមិនទុកប្រាក់បំណាច់នេះទេ ឯកសារប្រាក់ខែគាត់ច្បាស់ជាធ្វើមិនបានហើយទាន់ពេលវេលា គាត់នឹងត្រូវត្រឡប់មកម្តងទៀតហើយនឹងត្រូវចំណាយក្នុងការធ្វើដំណើរលើកទីពីរថែមទៀតដែរ ដូច្នេះគាត់ត្រូវដឹងថាតើ ធ្វើយ៉ាងណាទើបចំណេញពេល។*

*ម្យ៉ាងទៀត មុខតំណែងខ្លះឥតមានទទួលប្រាក់ខែទេ (ដូចជាមេឃុំជាដើមដែលមានកិច្ចការងាររាល់ថ្ងៃកើនកាន់តែច្រើនឡើងៗ)។*

*មុខងារខ្លះទៀតទទួលប្រាក់ខែតិចតួរឲ្យអស់សំណើច ដូចជាចៅក្រម «លោកសុភា» ទទួលតែ១៨ត្រណោតប៉ុណ្ណោះក្នុង១ខែ តិចជាងអ្នកធ្វើបាយជនជាតិអណ្ណាមទៅទៀត។ដូច្នេះពួកគេតែងឆ្លៀតគ្រប់ឱកាសជានិច្ច។ យ៉ាងដូចរឿងរ៉ាវថ្មីៗមួយនេះ ៖ មានបញ្ជាមកពីលើថាត្រូវដាក់ទង់ជ័យដោតតាម«សាលាខេត្ត»ដើម្បីជាបដិសណ្ឋារកិច្ចទទួលលោកទេសាភិបាលបារាំងដែលនឹងធ្វើដំណើរឆ្លងកាត់តាមនោះ។ មេឃុំម្នាក់ដែលនៅជិតផ្ទះខ្ញុំប្រាប់ខ្ញុំថា គេតម្រូវឲ្យគាត់និងសហការីផ្តល់ទង់ម្នាក់១៤ដើម ។ ថាមានចិនម្នាក់ជាអ្នកទទួលធ្វើទង់ជ័យនេះ។ ដោយយល់ឃើញថាមេឃុំនេះក្រ ខ្ញុំក៏*

*ប្រាប់ឲ្យគាត់ទៅទិញទង់ជ័យចិននោះមួយឲ្យភរិយាគាត់ធ្វើជាគំរូដើម្បីដេរទង់១៣ទៀតខ្លួនឯង។ គាត់អរណាស់ ខំរត់ទៅធ្វើតាមគំនិតនេះ។ តែឥតបានការទេ ព្រោះអ្នកខាងលើគេចងក្រឡាជាប់ហើយ... គាត់ត្រូវតែទៅទិញទង់ទាំងអស់ពីចិននោះតាមបង្គាប់។*

តាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម គេមានបំណងតែមួយដូចពីជំនាន់ដើមអញ្ចឹង គឺធ្វើយ៉ាងណាឲ្យកសិដ្ឋានសម្ងាត់គេបានទទួលកំរៃច្រើនបំផុត ហើយបើសិនជាមានការផ្លាស់ប្តូរក៏ត្រូវតែរេផ្អៀងទៅតាមរបៀបចាស់ដែរ។ យើងសុទ្ធតែធ្លាប់បានស្គាល់ហើយអស់លោកអភិបាលខេត្តចាស់ៗ (ពួជគាត់កំពុងតែរលាយបាត់បន្តិចម្តងៗក្រោមភ្នែកយើង) លោកទាំងនោះមានអំណាច និងមានកិត្យានុភាពដែលគេមិនដែលស្គាល់ក្នុងពេលបច្ចុប្បន្ននេះទៀតទេ។ ពួកលោកស្រឡាញ់ទឹកដីដែលលោកត្រូវគ្រប់គ្រងណាស់ ហើយរាស្ត្រប្រជាភាគច្រើនក៏ចូលចិត្តស្រឡាញ់លោក ដែរ។ ជិវិតរស់នៅរបស់លោកមានភាពសាមញ្ញ របៀបឪពុកដែលគ្រប់គ្រងកូនចៅក្នុងគ្រួសារ។ លោកមានភរិយាច្រើន តែក៏មិនធ្វើលួចលាក់ ដូចអ្នកជំនាន់ក្រោយទេ។ កាលណាលោកបានទិញគ្រឿងអលង្ការបំពាក់ភរិយាទាំងនោះអស់ហើយ លោកគ្មានឱកាសនឹងចំណាយលើសពីនេះទេ។ និយាយឲ្យចំ ពួកលោកមិនសូវ«ល្មោភ»ដូចអ្នកជំនាន់ក្រោយនេះឡើយ។

ផ្នត់គំនិតអ្នករាជការសម័យថ្មីខុសគ្នាពីមុនឆ្ងាយណាស់។ ភាគច្រើនៗ ធ្លាប់ធ្វើជាអ្នកបកប្រែ គេមាន ឡានជិះ មានសេចក្តីត្រូវការច្រើន តែមិនសូវគិតគូរពីសុខទុក្ខរាស្ត្រទេ ។ហើយបើសិនជាគាត់ឆ្លាតចេះមើលឯកសារថវិកាវិញផង គាត់ច្បាស់ជាលៃលកបង្កើតវិធីទំនើបមួយធ្វើយ៉ាងណាប្រមូលធនតាមផ្លូវខុសច្បាប់ឲ្យបានច្រើនថែមទៀតមិនខាន។

*តើគេមានដឹងទេថា ការរំដើបរំជួលនៅខែមករានិងកុម្ភៈឆ្នាំ១៩១៦បានផ្ទុះឡើងដោយរបៀបណា? ក្នុងផែនការដែលបានគ្រោងទុកសំរាប់ឆ្នាំ១៩១៦នុះ មានគំរោងសាងសង់ផ្លូវជាច្រើនឆ្លងកាត់ខេត្តមួយចំនួនដូចជា ខ្សាច់កណ្តាល មុខកំពូល ជើងព្រៃ កំពង់សៀម។ ដឹងដូច្នោះអស់លោកអភិបាលខេត្តនិងមន្ត្រីរាជការពាក់ព័ន្ធនៅតាមខេត្តទាំងនោះក៏បាននាំគ្នារៀបចំជារចនាសម្ព័ន្ធដើម្បីគ្រប់គ្រងអ្នកដែលត្រូវជាប់កំណែនមកធ្វើផ្លូវនេះព្រោះអីជាលើកទីមួយហើយដែលរាស្ត្រត្រូវគេកេណ្ឌឲ្យបង់ពន្ធជាកម្លាំងកាយផ្ទាល់ដូច្នេះ។ វិធីគេស្រួលណាស់ ហើយក៏មិនមែនជាលើកទីមួយទេដែលគេដាក់ឲ្យដំណើរការ ៖ ពួកគេរើសកម្មករចាក់ដី (ភាគច្រើនជាជនជាតិចិន) ដែលសុខចិត្តទទួលប្រាក់ប្រហែល១០ត្រណោតដើម្បីធ្វើការលើកផ្លូវនេះ។ ពេលរាស្ត្រអ្នកជាប់កំណែនមកដល់ អស់លោកទាមទារឲ្យគ្នាបង់ប្រាក់ជំនួសការងារដែលមិនបានធ្វើ ចំនួនពី១៥ទៅ២៥ត្រណោត (ត្រឹមតែកំណែនពី៨ពាន់នាក់ទៅដល់១ម៉ឺននាក់ប៉ុណ្ណោះ លើកំណែនទាំងអស់ប្រហែលជា២ម៉ឺននាក់ដែលប្រុងក្នុងគម្រោង ឃើញថា ប្រាក់ចំណេញដូចជាគួរឲ្យចាប់អារម្មណ៍ដែរ)។ កាលនោះគេប្រុងប្រៀបគ្រប់សព្វអស់ហើយ ៖ គេបានទិញសំភារៈ ( បង្គី ចប...) គេបានដាក់ពួកកម្មករជំនួសឲ្យចាប់ផ្តើមការងារ អ្នកដើរតួជួសអភិបាលខេត្តក៏ចាប់ផ្តើមចេញទៅអង្កាសពន្ធពីអ្នកកំណែនដែរ ស្រាប់តែចលនាបះបោរផ្ទុះសាយភាយពេញទាំងប្រទេស ធ្វើឲ្យខូចគម្រោងគេអស់ ។ ប្រាក់ទាំងប៉ុន្មានត្រូវសងទៅម្ចាស់គេវិញ*

*ភ្លាម ប្រពន្ធកូនដែលគេទុកបញ្ចាំជំនួសការខ្វះប្រាក់ក៏ត្រូវដោះលែងយ៉ាងឆាប់រហ័ស ។ អ្នកដៃដល់របស់អភិបាលខេត្តម្នាក់បានទទួលរងគ្រោះដោយពួកបាតុករចូលទៅវាយកំទេចផ្ទះសំបែង ហើយបើកុំតែអាយុនៅថ្លៃកុំអីវិះតែអស់ជីវិតទៀតផង។*

*តាមពិតទៅ ពេលវេលាបានផ្លាស់ប្ដូរហើយ ៖ ប្រជារាស្ត្រនៅតាមដំបន់សម្បូរសប្បាយមានការចេះដឹង ម្ល៉ោះហើយគេមិនព្រម«ធ្វើតាមតែចិត្តអស់លោក»ទេ។ គេបានចាប់ផ្ដើមដុតផ្ទួនរំសេវចាប់ពីខេត្តមួយនេះទៅ រហូតដល់ភ្លើងឆាបឆេះពេញទូទាំងព្រះរាជាណាចក្រខ្មែរ។*

មន្ត្រីរាជការជំនាន់ដើមច្រើនតែសាមញ្ញធម្មតា ឯមន្ត្រីរាជការជំនាន់ក្រោយនេះគឺ វាយរឹកក្រអឺតក្រទមណាស់ ៖ គេមិនជួយសំរួលទំនាក់ទំនងរវាងយើងជាមួយនឹងជនរួមជាតិរបស់គេទេផ្ទុយទៅវិញ គេបែរជាខំប្រឹងប្រែងបង្កើតបញ្ហាឲ្យកាន់តែច្រើន។ គេដាក់ខ្លួនហាក់ដូចជាអ្នកចាំតែទទួលធ្វើតាមបញ្ជាពីយើង ឬក៏ជាអ្នករងគ្រោះដោយសារយើងថែមទៀតផង។ គេខំធ្វើយ៉ាងណាឲ្យដូចបារាំងអ្នកអាណាព្យាបាលរបស់គេដោយរើសយកតែអាកប្បកិរិយាខាងក្រៅប៉ុណ្ណោះមកធ្វើជាគំរូ។ មានរឿងមួយដែលគេបានដឹងឮពេញស្រុក អំពីគ្រូពេទ្យខ្មែរម្នាក់ដែលទើបនឹងចេញពីសាលាវេជ្ជសាស្ត្រនៅហាណូយ៖ពេលគាត់ពិនិត្យសុខភាពរាស្ត្រជាជនរួមជាតិ គាត់និយាយតែជាភាសាបារាំងទេ ទុកឲ្យអ្នកបកប្រែនិយាយទៅរកអ្នកជម្ងឺផ្ទាល់ទៅវិញ។ មានប្រាជ្ញាឈ្លាសវៃ មានភាពស្លូតត្រង់សោះ តែប្រហែលជាគាត់គិតថាបើនិយាយផ្ទាល់អាចធ្វើឲ្យអាប់ឱនកិត្តិយសគាត់ហើយមើលទៅ។

ដោយសារគាត់បានទទួលការអប់រំរបៀបបារាំង គាត់ក៏ខំចម្លងកាយវិការគ្រូទាំងអស់ ហើយគិតថាយកអ្នកប្រែភាសាមកប្រើពិតជាត្រឹមត្រូវតាមរបៀបរបបជាគ្រូពេទ្យហើយ។

&&&&&&&

## ជំពូកទី៣
## អំពីបញ្ហាចិន

ទោះច្រើនឬតិច ប្រទេសកម្ពុជាតែងមានទំនាក់ទំនងជាមួយប្រទេសចិនជានិច្ច។ សព្វថ្ងៃនេះ គេឃើញមានជនជាតិចិនប្រហែលជា១៥ម៉ឺននាក់រស់នៅលើដីកម្ពុជា គឺស្មើនឹង១ភាគដប់នៃប្រជាជនខ្មែរ។បើសិនជានៅតុងកឹង នៅអណ្ណាម ឬក៏នៅកូសាំងស៊ីន គេអាចទុកវត្តមានចិនថាជារឿងបន្ទាប់បន្សំនៅក្នុងសង្គម តែនៅកម្ពុជាវិញ (ដូចគ្នានឹងប្រទេសស្យាមដែរ) ចិនក្លាយទៅជាដៃគូដ៏សំខាន់មួយនៅក្នុងសកម្មភាពទំនើបរបស់យើង។ គេជំណាងធាតុខ្លាំងដែលអាចជំរុញការអភិវឌ្ឍន៍ បើខ្វះពួកគេគឺ «កិច្ចការ»អ្វីៗទាំងអស់ច្បាស់ជាឈប់គាំងលែងដើរអស់ហើយ។ ចេញមកពីស្រុកចិនខាងត្បូង មាននិន្នាការជាសាធារណរដ្ឋនិយមបន្តិចបន្តួច គេមិនទាន់ជាគ្រោះថ្នាក់ផ្នែកនយោបាយសំរាប់យើងនៅឡើយទេ (បើមើលតាមស្ថានការណ៍ជាក់ស្តែងថ្មីៗនេះ) តែការកើនប្រជាជនឡើងលឿនពេករបស់ពួកនេះនឹងអាចបង្ករបញ្ហាចំពោះអនាគតនៃប្រទេសខ្មែរ។

ចំនួនប្រជាជន«កូនអាទិទេព» (ស្តេចស្រុកចិនតែងទុកខ្លួនជាព្រះអាទិទេព) នេះចេះតែកើនឡើងមិនឈប់ ពិសេសគឺដោយសារពួកកូនកាត់ដែល ជួនកាលជំនាន់ក្រោយៗមកមិនទាំងចេះភាសារបស់ជីដូនជីតាផងតែ នៅតែប្រកាសថា ខ្លួនគេជាជនជាតិបរទេសរហូត។ ប្រទេសស្យាមដែលមានរឿងរ៉ាវដូចគ្នានេះដែរ បានធ្វើការបញ្ច្រាបជាមួយពួកចិន ទាំងផ្លូវនយោបាយ ទាំងផ្លូវសង្គម (ដែលជាមធ្យោបាយមួយល្អម្យ៉ាងដែរ ល្អរហូតអស់មានពូជ ស្យាមសុទ្ធទៀតហើយ)។ ដើម្បីផលប្រយោជន៍ខ្លួន ប្រទេសខ្មែរក៏ប្រហែលជាត្រូវធ្វើដូច្នេះដែរហើយ ព្រោះថា ពួកចិននេះពូកែធ្វើការប៉ិនប្រសប់ខាងផ្នែប្រឌិត ពូកែរកស៊ីធ្វើជំនួញ ហើយចេះរស់នៅដោយសុខដុមជាមួយប្រជាជនដែលការកូនស្រីឲ្យគេ។ ពេលនោះប្រទេសខ្មែរនឹងបានទទួលផ្លែផ្កាពីឈាមថ្មី ព្រោះថាការកាត់ពូជថ្មីនេះឲ្យលទ្ធផលល្អប្រសើរ ទាំងខាងរូបសម្បត្តិ ទាំងខាងប្រាជ្ញា។

*ច្បាប់ពីជំនាន់ដើមហាមប្រាមមិនឲ្យស្ត្រីកម្ពុជាការជាមួយជនជាតិបរទេសទេ។ ច្បាប់នេះបានប្រឆាំងយូរអង្វែងណាស់នឹងការបង្កាត់ពូជថ្មីនេះ ។ តែឥឡូវ គេឃើញមានការផ្សំផ្គុំកូនខ្មែរនឹងចិនកាន់តែច្រើនឡើងៗហើយ(លើកលែងតែពួកចិនកន្តាំងដែលនាំប្រពន្ធមកជាមួយ) ។ ផលិតផលដែលបានមកពិតជាគួរឲ្យចាប់អារម្មណ៍មែនៈគឺជាប្រជាជនមានលំនឹង ពូកែធ្វើការ ហើយមានប្រាជ្ញាឈ្លាសវៃ។ អ្នកខ្លះ មានប្រពន្ធកូននៅស្រុកចិនរួចហើយក៏រៀបការដោយ ធ្វើ«ខសន្យាកំណត់ពេល»*

*។ នៅពេលដែលគេត្រូវត្រឡប់ទៅស្រុកវិញ គេមិនដែលបោះបង់កូនចោលទេ គឺគេតែងតែរៀបចំទុកដាក់ឲ្យកូននិងម្ដាយរបស់វា បានរស់នៅដោយសមរម្យជានិច្ច។*

នៅត្រង់ចំណុចនេះឯងដែលបញ្ហាកាន់តែស្មុគស្មាញហើយបង្វែរខុសពីគោលដៅ ៖ ដោយសារគុណបុណ្យពួកយើង(បារាំង) ប្រជាជនជាតិចិនដែលមានសមាគមសាសនាឯកជនជាច្រើន បានបង្កើតក្នុងពេលបច្ចុប្បន្ននេះនូវ*«រដ្ឋមួយក្នុងរដ្ឋរបស់ខ្មែរ»*។យើងមិនបានជួយឲ្យជនជាតិចេញចាកស្រុកនេះ បានចូលលាយរម្លួតជាមួយជនជាតិនៃប្រទេសដែលទទួលគេឲ្យជ្រកនៅទេ ផ្ទុយទៅវិញ យើងខិតខំធ្វើយ៉ាងណាបំបែកគេឲ្យនៅដាច់ពីគ្នា។ តែបើយើងយកលេស នយោបាយប្រូតិចតូរ៉ាជំនាន់មួយនោះមកនិយាយ ក៏អាចសមហេតុសមផលដែរ ៖ ពេលនោះយើងបានពឹងផ្អែកលើចិន ហើយយើងតាំងខ្លួនជាអ្នកការពារចិន ព្រោះអីចិនមិនទាន់មានកុងស៊ុលនៅតណ្ឌូចិននៅឡើយ។ ប៉ុន្តែចំពោះមុខរាជការខ្មែរពេលនោះ ចិននៅក្រៅការគ្រប់គ្រងរបស់ខ្មែរ គឺហាក់ដូចជាគេរស់នៅក្រៅដីខ្មែរព្រោះ គេមិនបាច់គោរពច្បាប់ទម្លាប់ខ្មែរឡើយ។

*ទើបតែពីឆ្នាំ១៨៩៧ទេដែលស្ថានភាពនេះកើតឡើង គឺថ្មីៗនេះដែរ។ ពីមុនមក ពួកចិន (ដូចជានៅប្រទេសស្យាមដែរ) មានសិទ្ធិនិងភារកិច្ចនៅមុខផ្លូវច្បាប់តាមធម្មតា ដូចប្រជាជនខ្មែរដទៃទៀត ។ នៅថ្ងៃមួយ ដោយសារលោកទេសាភិបាលបារាំងចង់យកឈ្នះជាមួយស្ដេច«ព្រះបាទនរោត្តម» គាត់ក៏បានសំរេចចិត្តបន្ថយអំណាចរបស់ស្ដេចខ្មែរ ហើយយកអំណាចនេះមកឲ្យប្រូតិចតូរ៉ាយើងកាន់វិញ។*

គេយល់ហើយ តើបន្ទុកផ្នែកសង្គមកិច្ចនេះ វាធ្ងន់ឥតប្រយោជន៍យ៉ាងណាក្នុងសង្រែកប្រទេសខ្មែរ។ ម្យ៉ាងវិញទៀត ផ្នែកសេដ្ឋកិច្ចក៏ចិនជាអ្នកកាន់ក្ដាប់ ព្រោះគេជាអ្នកមានទ្រព្យធន។ ដោយសារតែគុណបុណ្យយើង គេបានចូលទៅក្នុងវណ្ណៈខ្ពស់ មានឯកសិទ្ធិនៅក្នុងស្រុកដែលមិនមែនជារបស់គេលើសពីអ្នកម្ចាស់ស្រុក (ខ្មែរអ្នកស្រុកបែរជាខាតលាភទៅវិញ)។ គ្រាន់តែមើលរបៀបគេប្រព្រឹត្តជាមួយអ្នកអាជ្ញាធរក្នុងស្រុកក៏ឃើញហើយ គឺគេកៀបបានដោយប្រាក់សំណូក ឬដោយល្បែង។ បើជាមួយរាស្ត្រសាមញ្ញវិញគេធ្វើមុខញញឹមដើម្បីបង្ហាញការអាណិតអាសូររបស់គេ(តែជាការពេបជ្រាយសោះ!)។ការពិតទៅ គេរស់នៅក្បែររាស្ត្រ នៅលាយឡំនឹងរាស្ត្រ ហើយជិតដិតនឹងរាស្ត្រទៀតផង។ ក៏ប៉ុន្តែគេដឹងយ៉ាងច្បាស់ថា គេស្ដាប់គេខ្លាច តែបារាំងប៉ុណ្ណោះ។ ចំណែកយើងវិញ យើងមានចិត្តទូលាយ យើងនៅឆ្ងាយពីពួកគេ យើងមិនសូវមានលំនឹង យើងមិនមោះមុត ។ ឲ្យតែបានបង់ពន្ធប្រមាណ១៤ត្រណោតក្នុងមួយឆ្នាំទៅ គេគ្មានរឿងភ័យភិតអ្វីទៀតលើសពីជនជាតិអឺរ៉ុបទេ មានតែតិចជាងជនជាតិអណ្ណាមដែលជាប្រជានុរាស្ត្របារាំងផង ។ ពួកជនជាតិចិនគ្មានជាប់

កំណៃន គ្មានជាប់ចំណងពន្ធជាពលកម្ម គ្មានជាប់សំណើពីរាជការ គ្មានជាប់សេវាធ្វើទាហាន គ្មានរឿងរ៉ាវជាមួយពួករាជការ គ្មានជាប់ទាក់ទិនជាមួយសមត្ថកិច្ចខ្មែរ ឬក៏មានរឿងក្តៅក្រហាយដូចរាស្ត្រទូទៅធ្លាប់ជួបប្រទះឡើយ (ឧទាហរណ៍ៈរឿងមួយក្នុងចំណោមរឿងដទៃដែលធ្វើឲ្យរាស្ត្រខ្មែរក្តៅក្រហាយរហូតបះបោរនៅឆ្នាំ១៩១៦គឺ អ្នកដែលតុលាការកោះហៅទៅធ្វើជាសាក្សីក៏ត្រូវគេចាត់ទុកដូចជាជនជាប់ចោទដែរ)។

ដូច្នេះហើយទើបបានជាពួកកូនកាត់ចៅចិនច្រើនណាស់ដែល ទោះបីជំនាន់ក្រោយឆ្ងាយមកហើយ ក៏នៅតែប្រកាសតាំងខ្លួនថាជាជនជាតិចិនមកពីបរទេសដែរ។ តាមពិតបើមើលតាមជាតិពន្ធុពួកគេលែងមានការខុសគ្នាពីអ្នកស្រុកដើមទៀតហើយ (អ្នកខ្លះទៀតជាខ្មែរសុទ្ធសាធ តែខំបង្កើតរឿងជីតាទួតលួតលាចិនដូចគេដែរ)។ ពួកគេបានឃើញឯកសិទ្ធសំរាប់ជាតិចិនគ្រប់កន្លែងដូច្នេះហើយ គេមិនរួញរានឹងធ្វើខ្លួនឲ្យក្លាយទៅជាចិនទេ។ គេសុខចិត្តបង់ពន្ធខ្លួន ដែលថ្លៃ៣ដងលើសពីពន្ធសំរាប់ខ្មែរ
តែគេនៅតែចំណេញៈគេគេចផុតពីរដ្ឋបាល ពីសមត្ថកិច្ច ពីច្បាប់តុលាការខ្មែរ ដែលតឹងតែងធ្ងន់ធ្ងរចំពោះរាស្ត្រ។ ខ្ញុំបានឃើញរឿងរ៉ាវដូចគ្នារបស់អ្នកជិតខាងពីរនាក់ដែល និយាយភាសាដូចគ្នា (បើតាមស្មានមើលទៅ ពូជក៏ដូចគ្នា) តែម្នាក់ត្រូវកាត់ទោសដោយតុលាការបារាំង ម្នាក់ទៀតដោយតុលាការខ្មែរ។ ម្នាក់ត្រូវបង់ពិន័យតែពីរបីត្រណោតប៉ុណ្ណោះ ឯម្នាក់ទៀតត្រូវជាប់គុកដល់ទៅបីឆ្នាំ។

ទីបញ្ចប់យើងមកដល់ការសនិដ្ឋានមួយដែលមិនសមសោះ គឺថានៅក្នុងព្រះរាជាណាចក្រខ្មែរសព្វថ្ងៃនេះ ទោះបីមានឋានៈជាជនជាតិណាក៏ប្រសើរជាងកើតមកជារាស្ត្រខ្មែរដែរ។ ខ្មែរ រស់នៅក្នុងស្រុកកំណើតរបស់ខ្លួនឯងមែន តែក្លាយទៅជាមនុស្សដែលគេបោះបង់ចោលព្រោះគេស្អប់ខ្ពើមគ្រប់គ្នា។

*យើងបានឃើញស្ថានភាពនេះកើតមានជាពិសេសនៅតាមពន្ធនាគារ។គ្រាន់តែប្រៀបធៀបគុកធំដែលយើងកាន់កាប់នៅភ្នំពេញ ជាមួយគុកខ្មែរដែលនៅជាប់គ្នានោះក៏អាចយល់ពីបញ្ហានេះបានយ៉ាងច្បាស់ណាស់ៈក្នុងគុកខ្មែរមានអ្នកទោសច្រើនលើសលប់ ឥតមានអនាម័យសោះ មិនថាគេជាប់ទោសត្រឹម៥ថ្ងៃព្រោះរឿងមិនបានបង់ផាកពិន័យ ឬដោយសារជំពាក់លុយគេ ឬក៏គ្រាន់តែជាអ្នកជាប់ពិរុទ្ធប៉ុណ្ណោះទេ គេសុទ្ធតែត្រូវជាប់ច្រវាក់ ហើយរស់នៅលាយឡំច្របូកច្របល់គ្នាទាំងអស់ ។ ផលវិបាកគឺមានការស្លាប់ច្រើនលើសគុកធំ៥ដង ។ ដូចជានៅក្នុងឆ្នាំ១៩១៥ នៅគុកធំមានអ្នកទោសស្លាប់៨នាក់ ឯនៅគុកខ្មែរមានដល់ទៅ៦២នាក់ (ក្នុងចំនួនអ្នកទោសមិនដល់៣ដងនៃគុកធំ*

*ផង) ។ នៅឆ្នាំ១៩១៦ ៖ ២ទល់នឹង៤២ ។ នៅឆ្នាំ១៩១៧ ៖ ៥ទល់នឹង៤៤ ។ នៅឆ្នាំ១៩១៨(ឆមាសទីមួយ) ៖ ៣ទល់នឹង៣១។*

*ច្រវាក់អ្នកទោសគឺខ្នោះធ្វើអំពីកង២ចងជើងភ្ជាប់គ្នាដោយដែក២ទងយ៉ាងមាំប្រវែងពី២តឹកកន្លះទៅ៣តឹក ហើយធ្ងន់ប្រហែល២ទៅ៣គីឡូក្រាម។ រហូតមកដល់ប៉ុន្មានខែមុននេះ មួយថ្ងៃ២ដងគេអាចឈរមើលក្បួនហែអ្នកទោសនៅភ្នំពេញ ដែលដើរជំហានរាងញាប់ទៅកាន់ការដ្ឋានការងារ គឺស្ថានីយកសិកម្មយើង (ដែលនៅចម្ងាយប្រហែលជា២គីឡូម៉ែត្រពីគុក)។ នៅលើស្មាពួកគេមានពាក់«របារក្រសួងយុត្តិធម៌សំរាប់ដេកថ្ងៃ»(sic)។ គួរឲ្យអនិច្ចាណាស់ កាលព្រះបាទ ស៊ីសុវត្ថិ លោកឡើងសោយរាជ្យនៅថ្ងៃ១៨សីហា១៩០៣ ដើម្បីជាព្រះរាជទានរបស់ព្រះអង្គក្នុងថ្ងៃនក្ខត្តឫក្ស ព្រះអង្គបានប្រកាសឲ្យលប់បំបាត់ឃ្នាងខ្នោះនៅទូទាំងព្រះរាជាណាចក្ររួចទៅហើយ។*

ដោយសារតែយើងមិនរវីរវល់អំពីផលវិបាកនៃស្ថានភាពនេះ យើងយកលេសរឿងបង់ពន្ធដារតិចតួចមកបង្ករជារឿងអាស្រូវដ៏កំណាចមួយ។ ស្ថានភាពនេះរីកកាន់តែធ្ងន់ធ្ងរហូតផ្ទុះឡើងនៅពេលដែលប្រទេសចិនចូលមកដាក់ដំណាងទូតរបស់គេនៅស្រុកខ្មែរ។

&&&&&&&&&

## *ជំពូកទី៤
## នយោបាយបារាំងជាមួយអ្នកក្នុងស្រុក
## ភ្នាក់ងារទំនាក់ទំនងរបស់យើង

មានតួសំខាន់ម្នាក់ដែលជាអ្នកដើរលើឆាកប្រហែលជាង២០ឆ្នាំមកហើយ គឺរដ្ឋមន្ត្រីខាងរាជវាំង។

ជាការពិតណាស់ តាំងពីប៉ុន្មានឆ្នាំចុងក្រោយនៃរាជព្រះបាទនរោត្តមមក (ខ្វង់ឆ្នាំ១៨៩៨) យើងអាចនិយាយថាប្រទេសទាំងមូលឋិតនៅក្នុងកណ្តាប់ដៃលោករដ្ឋមន្ត្រីវាំងជាអ្នកគ្រប់គ្រង។ ទោះពួកទេសាភិបាលបារាំងមានការផ្លាស់ប្តូរជាហូរហែ ក៏គាត់(ឬសម្តេចថៅហ្វាវាំង) នៅតែអង្គុយលើកៅអីអំណាចម្នាក់ឯងរហូត។ ថ្វីដ្បិតតែមានការផ្លាស់ប្តូរ ឡើងចុះខ្លះក៏ដោយ ក៏គាត់ចេះឱបអំណាចជាប់ហើយឥទ្ធិពលគាត់ក៏រឹតតែរីកធំឡើង នៅជួនពេលដែលព្រះរាជាបាត់បង់អនុភាពបន្តិចម្តងៗដោយសារតែបារាំងយើង។ ពីដើមគាត់ជាអ្នកបកប្រែម្នាក់ដែល បារាំងបង្ខំព្រះបាទនរោត្តម ឲ្យទទួលធ្វើជាអគ្គលេខាធិការនៃគណៈរដ្ឋមន្ត្រីដើម្បីជួយសំរួលកិច្ចការរបស់ប្រូតិចតូរ៉ាយើង តែគាត់ចេះឆ្នៃសំណាងគាត់ឲ្យកាន់តែរីកដុះដាលរហូតដល់កំរឹតមួយដែលគាត់មិនដែលស្រមៃឃើញឡើយ។ យើងដឹងហើយថា នៅចុងរាជ្យព្រះអង្គ ព្រះបាទនរោត្តមបានត្រូវគេបញ្ចៀសចេញឆ្ងាយពីកិច្ចការគ្រប់គ្រងក្តីក្តាំឬរឿងរ៉ាវគ្រប់ជំពូក (សូមមើលរឿងក្តីយុគន្ធរ) បន្តមកទៀត ព្រះបាទស៊ីសុវត្ថិក៏គ្រាន់តែជានិមិត្តរូបដ៏តូចមួយ ដែលគួរឲ្យអាណិតនិងស្រឡាញ់។

លោករដ្ឋមន្ត្រីខ្មែររបស់យើងនេះផ្អែកអធិបតេយ្យភាពរបស់គេ

1. លើការខ្វះលំនឹងនៃរដ្ឋបាលយើង៖ក្នុងរយៈពេល១៨ឆ្នាំ យើងបានប្តូរទេសាភិបាលឬអ្នកជំនួស ដល់ទៅ១៤នាក់។
2. លើនយោបាយ«កុំប្រឹងខ្លាំងពេក»របស់យើង៖ធ្វើយ៉ាងណាកុំឲ្យមានរឿងរ៉ាវឲ្យសោះ។
3. លើ«ការមិនអាចយល់គ្នាបាន» ដែលកាន់តែធ្ងន់ឡើងៗ រវាងអ្នកគ្រប់គ្រងរដ្ឋបាលបារាំងនិងរាស្ត្រខ្មែរ តាំងពីប្រហែល២០ឆ្នាំមកនេះ ហើយដែលបានផ្ទុះឡើងនៅពេលមានការរំជើបរំជួលថ្មីៗនេះ(១៩១៦)។ គឺដូចជាកាលពួកអ្នកបះបោរ១០ម៉ឺននាក់ជាដើម ដែលមិនទាំងស្គាល់ពីនយោបាយបារាំងយ៉ាងម៉េចផង (គេមិនស្អប់ ហើយក៏មិនស្រឡាញ់ដែរ) គេមានតែពាក្យមួយម៉ាត់គឺ«ហ្លួង»ឬ ព្រះរាជានៅក្នុងមាត់ប៉ុណ្ណោះ។ គេចង់ជួបស្តេចគេ ព្រោះគេទុកចិត្ត

ខ្ពស់តែលើព្រះអង្គ។ នេះជារឿងមួយគួរឲ្យចាប់អារម្មណ៍ណាស់។ ពួកគេឥតមានគិតមួយពេលតូចណាមួយទេថា ជារឿងដែលត្រូវរកយើងឲ្យដោះស្រាយ។ យើងមានតែរូប តែគ្មានប្រយោជន៍សំរាប់គេឡើយ។

*ប្រជារាស្ត្របីម៉ឺននាក់ឡើងរហូតដល់រាជធានី ពីថ្ងៃ៥មករា ដល់ថ្ងៃ២៤កុម្ភៈ១៩១៦។ ព្រះបាទស៊ីសុវត្ថិ ទោះបីមានព្រះជន្មាយុ៧៧វស្សាទៅហើយ យើងត្រូវទទួលស្គាល់ថា គឺព្រះអង្គនេះហើយដែលជាអ្នកជួយស្រោចស្រង់ស្ថានការណ៍ នៅពេលកំពុងមានគ្រោះថ្នាក់។*

គុណសម្បត្តិពីដំបូងរបស់គាត់គឺ គាត់ជាមនុស្សមានប្រាជ្ញាឈ្លាសវៃ ពេញទៅដោយគតិបណ្ឌិត លុះនឹងការងារ ចេះភាសាបារាំង។ គាត់ខ្លាយទៅជាមនុស្សដ៏សំខាន់ចាំបាច់ម្នាក់សំរាប់អ្នកគ្រប់គ្រងបារាំងដែលមិនសូវមានលំនឹងហើយមិនស្គាល់ការងារដល់ជំរៅ។ គាត់ដូចជាម្ចាស់កសិដ្ឋានម្នាក់ ឬអ្នកនយោបាយម្នាក់ដែល (យកលេសរឿងធានាជួយបញ្ចៀសកង្វល់ពួកលោកទេសាភិបាលបារាំងទាំងអស់) ឆ្លៀតយកការងារគ្រប់គ្រងប្រទេសមកធ្វើជារបររកស៊ីចំណេញដើម្បីទៅជាអ្នកមាន។ គាត់ជាអ្នក ដំណាងស្ថាប័នថ្មីមួយដែលយើងជាអ្នកបង្កើត គឺ ប្រៀបបាននឹងមែកមួយដែលយើងបានផ្សាំភ្ជាប់ទៅនឹងដើមឈើមួយដើម ដំណាង«កម្ពុជា»ជាន់ចាស់ដែលមានដង្កូវស្រាប់។ តឡូវមែកនេះកាន់តែធាត់ធំទៅៗ នៅពេលជាមួយគ្នាដែលយើងបង្ហាញតែភាពទន់ខ្សោយ។ ដោយគាត់ជាមនុស្សប្រសប់ មើលឃើញតែរឿងមានប្រយោជន៍ ចំណាយគុណសម្បត្តិសំរាប់តែកិច្ចការផ្ទាល់ខ្លួន គាត់ក៏បានប្រឹងប្រែង ទាញយកផលរហូតបានដល់ទីដៅដ៏អស្ចារ្យមួយ ដែលគាត់ពិតជាអ្នកភ្ញាក់ផ្អើលមុនគេកាលពីដំបូង។ តែពេលក្រោយ គាត់ខំពង្រឹងស្ថានភាពនេះដោយធ្វើឲ្យល្បែងបិទពួនរបស់គាត់ជាមួយព្រះមហាក្សត្រនិងលោកទេសាភិបាលបារាំងកាន់តែស្មុគស្មាញ គាត់យកគ្រួសារមិត្តភក្ត្រ ឬអតិថិជនគាត់មកឲ្យកាន់ដំណែងសំខាន់ៗ។ គាត់ចងក្រឡាយ៉ាងជិតមិនឲ្យជ្រាបចេញចូលបានឡើយ(វាជារឿងអាយុជីវិតសម្រាប់គាត់)។ គាត់ចាក់ឫសកាន់តែជ្រៅទៅៗក្នុងសាច់ឈើព្រះមេគាត់នេះ។

គាត់ក្លាយទៅជាអ្នកមានលើសស្តេច ។ ក្នុងព្រះរាជាណាចក្រទាំងមូល មានតែគាត់ដែលមានទ្រព្យសម្បត្តិច្រើនជាងគេ។ មិនតែប៉ុណ្ណោះ គាត់ចេះរកបង្អែកដ៏ខ្លាំងមាំល្អណាស់ព្រោះថា ថ្ងៃមួយពេលលោកទេសាភិបាលបារាំងចុះទៅព្រៃនគរនៅឆ្នាំ១៩១២ ជាមួយសំណុំរឿងយ៉ាងក្រាស់សម្រាប់ចោទទោសនិងបញ្ឈប់ការងាររដ្ឋមន្ត្រីវាំងនេះ ស្រាប់តែមានកម្លាំងខាងលើមករារាំងលោកមិនឲ្យធ្វើកើត។ អ្នកជាប់ពិរុទ្ធបែរជាបានទទួលគ្រឿងឥស្សរិយយស« officier de la Legion d'honneur »ថែមទៅវិញ។ កិត្យានុភាពគាត់ក៏កាន់តែខ្ពស់ ព្រោះគាត់ខ្លាំងជាងអ្នកដំណាងប្រទេស

បារាំងទៅទៀត។ គាត់បានបង្ហាញថាគាត់ជាអ្នកឈ្នះក្នុងទឹកនេះទៀតហើយ។តាមពិតទៅមេធំគឺគាត់ រដ្ឋមន្ត្រីឯទៀតគ្មានបានការទាំងអស់។ ឯពួកអ្នកអង្គម្ចាស់ និងព្រះមហាក្សត្រចាស់ជរា សុទ្ធតែខ្លាចគាត់ញ័រចំប្រប់ អត់ហ៊ានហើបមាត់នៅមុខគាត់បន្តិចទេ។

*បើចង់សរសេររឿងទុក្ករកម្មខាងផ្លូវចិត្តលើស្តេចចាស់ជរាមួយនេះ គឺអាចក្រងជាសៀវភៅមួយបាន ព្រោះថាគេតាមដានមើលគ្រប់សកម្មភាពព្រះអង្គ សូម្បីជាសកម្មភាពក្នុងវាំងនិងក្នុងគ្រួសាររាល់ថ្ងៃក៏ដោយ។គេបន្ទំធ្វើឲ្យ បុគ្គលរបស់គេក្លាយទៅជាស្តេច។*

*តើហេតុអ្វីបានជាសាធារណជនខ្មែរឆាប់ភ្លេចម្ល៉េះ រឿង«អតិចារិយា»ឬការផិតក្បត់ដ៏អាស្រូវនៅលើ «នាវា l'Amiral-Ponty »នៅពេលស្តេចស៊ីសុវត្ថិយាងមកពីប្រទេសបារាំងវិញ? គឺការផិតរបស់មន្ត្រីខាងលើជាមួយស្នំឯកស្តេច! ពីជំនាន់ដើម ការប្រមាថព្រះចេស្តានេះជាឧក្រិដ្ឋកម្មដែលត្រូវទទួលទោសប្រហារជីវិត តែពេលទៅដល់រាជធានីវិញ ហ្លួងស៊ីសុវត្ថិគ្រាន់តែសុំឲ្យដករដ្ឋមន្ត្រីនេះចេញពីដំណែងប៉ុណ្ណោះ។ ក៏ប៉ុន្តែ អ្នកដំណាងយើងបែរជាយល់ហើយសម្រេចថា ឲ្យត្រឹមតែសុំទោសគឺជាការគ្រប់គ្រាន់ហើយ ។ បើសិនជាអ្នកក្រោយនេះគេគិតគូរចង់បង្ហាញរាស្ត្រទាំងប្រទេសឲ្យឃើញថាស្តេចរបស់ពួកគេទាំងអស់គ្នានេះគ្មាននៅសល់អំណាចអ្វីបន្តិចទេនោះ ក៏ប្រហែលជាមិនបានលទ្ធផលល្អលើសនេះដែរ !*

បើមានលោកទេសាភិបាលណាម្នាក់ចង់តទល់នឹងគេ គេធ្វើជាខ្លបខ្លាច ដកខ្លួនភ្លាម។ លុះពេលលោកទេសាភិបាលថ្មីមួយទៀតមកដល់ គេក៏ត្រឡប់មកសម្រុកវិញភ្លែត។ មានរឿងពិតមួយរបស់មន្ត្រីរាជការដែលជាសាច់សាលោហិតលោករដ្ឋមន្ត្រី។ ម្នាក់នោះបានត្រូវលោកទេសាភិបាលដកចេញពីដំណែងនៅឆ្នាំ១៩១១ (ពេលនោះ ព្រះមហាក្សត្រសព្វព្រះទ័យណាស់ដោយឃើញថាមានអ្នកខ្លាំងហ៊ានប្រឆាំងនឹងរដ្ឋមន្ត្រីវាំង ព្រះអង្គក៏ដកចិញ្ចៀនមួយវង់ពីម្រាមដៃទ្រង់ប្រទានទៅលោកទេសាភិបាលនោះភ្លាម) តែនៅឆ្នាំ១៩១៥ ពេលលោកទេសាភិបាលថ្មីមកដល់ មន្ត្រីរាជការដដែលនោះក៏ត្រឡប់មកវិញដោយបានឡើងបុណ្យសក្តិថែមទៀតផង។ អ្នកមុនទំលាក់គេចុះ អ្នកក្រោយលើកគេដល់កំពូល!

*ក៏ប៉ុន្តែនៅកណ្តាលពេលប្រជុំគណៈរដ្ឋមន្ត្រីសម័យនោះ មានសម្លេងមួយហ៊ានលើករឿងនេះឡើងដើម្បីប្រឆាំងនឹងទង្វើនេះ (ពាក្យចចាមអារាមថាទេវតានាំមាត់)។ អ្នកម្ចាស់សម្លេងបានទទួលការព្រមានយ៉ាងធ្ងន់ (តាមការប្រាប់ផ្ទាល់មាត់ផង រួចហើយជាលាយលក្ខណ៍អក្សរថែមទៀត)។*

យើងសង្កេតមើលចុះ តើរឿងច្របូកច្របល់ខ្វះទំនាក់ទំនងគ្នារបៀបនេះ(មិនមែនតែម្តងនេះទេ គ្រាន់តែលើកនេះវាល្បីពេញមួយប្រទេស!) អាចធ្វើឲ្យអំណាចលោកវាំងរឹតតែខ្លាំងយ៉ាងណា ឯចំ

វណ្ណេកយើងវិញ ជាមួយគ្នានោះ តើយើងបាត់ទំនុកទុកចិត្តអំពីប្រជាជនរហូតត្រឹមណា ? រាស្ត្រគេបែរ រហ័សណាស់ទៅរកអ្នកណាដែលខ្លាំងជាងគេ ! តើមិនឲ្យអ្នកធ្លាប់ធ្វើសាក្សីក្នុងរឿងអាស្រូវទាំងនេះ ភ័យញ័រខ្លួនចំប្រប់ដេកមិនលក់ឯណាបាននៅថ្ងៃនេះ បើក្រឡាប់ចាក់អស់យ៉ាងនេះ? គឺជាមេរៀន សំខាន់និងជាគំរូសំរាប់មនុស្សគ្រប់រូប ! ប្រជាពលរដ្ឋខ្មែរ ដែលកើតមកហើយរស់នៅលើទឹកដីរបស់ ដូនតាគេ ក៏បានបកស្រាយរឿងនេះតាមការសង្កេតនិងកត់សម្គាល់របស់គេទៅតាមពាក្យសុភាសិត ថា៖«ទូកទៅកំពង់នៅ»។ ទូកនេះគឺសំដៅលើយើងបារាំង ៖ ចំពោះភ្នែករាស្ត្រ ពួកយើងគ្រាន់តែជា អ្នកចូលមកនៅក្នុងស្រុកគេតែមួយភ្លែតប៉ុណ្ណោះ។

&&&&&&&&&&&

# ជំពូកទី៥
# អំពីស្ថានភាពសេដ្ឋកិច្ច

ផ្នែកសេដ្ឋកិច្ច យើងត្រូវតែទទួលយកការកត់សម្គាល់ដ៏សំខាន់ពីរខាងក្រោមនេះ៖

១/ ប្រទេសកម្ពុជាជាប្រទេសដែលសម្បូរធនធាន - ប្រជាជនកម្ពុជាជាប្រជាជនក្រ។ ដីប្រទេសខ្មែរមានដើមកំណើតកកើតពីដីល្បប់ (ដូចដីនៅកម្ពុជាក្រោមដែលមានជីរជាតិល្អដោយសារទឹកជំនន់ដ៏ទៀងទាត់នៃទន្លេមេគង្គ ដែលគេហៅថាទន្លេនីលនៅឥណ្ឌូចិន) ។ ការដឹកនាំផលិតផលរបស់គេចេញទៅក្រៅ ច្រើនលើសការដឹកនាំទំនិញចូល ព្រោះតែប្រទេសនេះផលិតស្រូវអង្ករលើសពីសេចក្តីត្រូវការក្នុងស្រុក។ ផ្នែកនេសាទដែលផ្តល់នូវធនសឹងតែមិនចេះអស់ ការរៀបអាជីវកម្មដី (ដោយដាំដំណាំកប្បាសឬគ្រឿងទេសផ្សេងៗជាដើម) និងធនធានក្រោមដី ពិតជាអាចធានាឲ្យប្រទេសនេះនូវអនាគតដ៏រុងរឿងមួយបាន។

ត្រង់នេះក្តី ការផ្ទុយគ្នាជាមួយកម្ពុជាក្រោមដូចជាស្តែងខ្លាំងណាស់។ ភាពផ្ទុយនេះ លេចឡើង ពិសេស ត្រង់ថារាស្ត្រខ្មែរក្ររហាម ចំណែកឯរាស្ត្រនៅកម្ពុជាក្រោមបែរជាធូរធារ(គឺរាស្ត្រគ្រប់សាសន៍ ទាំងខ្មែរ ទាំងសាសន៍ដទៃ)។ គ្រាន់តែប្រៀបធៀបដំបូលផ្ទះនៅស្រុកខ្មែរដែលប្រក់សុទ្ធតែពីស្បូវសឹងតែទាំងអស់ ពិសេសនៅដំបន់ក្នុង ទៅនឹងដំបូលផ្ទះប្រក់ក្បឿងដ៏ច្រើននៅកូសាំងស៊ីន(ដែលជាសញ្ញានៃភាពធូរធាររបស់ប្រជាជន) ក៏យើងអាចទាញការសន្និដ្ឋានបានដែរ។ បើសិនជាមន្ត្រីរាជការខ្មែរខ្លះនៅសកម្មនៅឡើយ គាត់អាចមានការរស់នៅដោយសុខស្រួល (គ្មានវណ្ណៈគហបតីដូចនៅកូសាំងស៊ីនទេ)។ ឯរាស្ត្រសាមញ្ញវិញ ជាទូទៅ គឺរស់ពីមួយថ្ងៃទៅមួយថ្ងៃដោយវេទនាជាទីបំផុត។ គេដឹងថា កាលពីជំនាន់ដើម ដើម្បីគេចផុតអំពីការស្រែកឃ្លានលោភលន់របស់នាម៉ឺនក្នុងស្រុក គាត់ត្រូវតែបញ្ចេញថាគាត់ក្ររហាម។ឥឡូវក៏គាត់ឥតមានប្តូរទេ គឺនៅតែក្រដដែល។ គាត់គ្មានរបស់សល់ទុកដាក់ទេ ដូច្នេះនៅពេលមានទុរ្ភិក្ស ទោះបីគាត់ហូបយ៉ាងតិចបំផុតក៏នៅតែមិនគ្រប់ ៖ យើងបានឃើញជាក់ថាគាត់ពិតជា*ស្លាប់ដោយអត់បាយ* មែន(តាមពាក្យដែលធ្លាប់ឮញឹកញាប់គឺ«ស្លាប់ដាច់ពោះ»)។

*ជាមួយគ្នានោះ នៅភ្នំពេញមានការរៀបចំពិធីបុណ្យដ៏ធំឱឡារិក (ហាក់ដូចជាចង់បិទបាំងបរិយាកាសដ៏អាប់អួក្នុងពេលនោះ) ដើម្បីអបអរសាទរទទួលលោកទេសាភិបាលថ្មីម្នាក់ទៀតរបស់ដែនឥណ្ឌូចិន។*

*ការរងទុក្ខវេទនាពេញទាំងប្រទេសនេះធ្វើឲ្យខ្ញុំរឹតតែទើសភ្នែកនិងអណោចអធម្មថែមទៀត នៅពេលដែលឃើញរបៀបរស់នៅក្នុងភាពឆើតឆាយប្រណិតរបស់អ្នកដំណាងយើងលេចធ្លោឡើងដូច្នេះ។ ទីតាំងរបស់អស់លោកទាំងនោះ តាំងពីសម័យសង្គ្រាម តែងល្បីយ៉ាងអាស្រូវអំពីភាពហ៊ឺហាប្រណិតហួសហេតុនេះ។យើងសុំលើកតែតួលេខមួយមកនិយាយ ដែលហេតុតែធំពេកទៅ ក៏អាចជានិមិត្តសញ្ញានៃរបៀបរស់នៅនេះដែរ។*

*«ផ្ទះភ្នំ» ដែលជាសម្បត្តិរបស់ប្រូតិចតូរ៉ានៅភ្នំពេញ មានកន្លែងចាប់ភ្លើងអគ្គិសនីដល់ទៅ ៨៥ (សំរាប់បំភ្លឺ និងសំរាប់ឲ្យមានខ្យល់ចេញចូល ចេញសោហ៊ុយដោយរដ្ឋបាលបារាំង)។ ការរៀបចំការបំភ្លឺដ៏អស្ចារ្យនេះមិនមែនដើម្បីសម្រួលការងារលោកទេសាភិបាល ឬក៏ដើម្បីលើកតម្កើងកិត្យានុភាពប្រទេសបារាំងក្នុងការជប់លៀងទទួលភ្ញៀវទេ ។ នេះគ្រាន់តែជាគ្រឿងប្រណិតខ្លះដែលគេ ផ្តល់ថែមដល់ផ្ទះនៅធម្មតារបស់មនុស្សម្នាក់ ដែលជាមន្ត្រីរាជការថ្នាក់លេខមួយប៉ុណ្ណោះ។*

បើយើងបានឃើញការរត់ចោលស្រុកដោយការអត់បាយ ក្នុងរវាងឆ្នាំស្ងួតហួតហែង (ដូចជាឆ្នាំ១៩១២ជាដើម) ដែលលោកគីព្លីង R.Kipling បានពិព័ណ៌នាយ៉ាងក្បោះក្បាយនៅក្នុងសៀវភៅរបស់គាត់ឈ្មោះថា «La Trève de la Soif» ឬ «ការផ្អាកសេចក្តីស្រេកឃ្លាន» ទើបពេលនោះយើងអាចវាស់បាននូវទំហំនៃការអត់ឃ្លានរបស់ប្រជាជននៅតាមជនបទ!

២/ **កម្ពុជជនសុទ្ធសឹងជាកសិករ (ឬអ្នករាជការ)**។ បើសិនជាគេចេះបង្កើតឧបករណ៍ ធ្វើទូក ឬធ្វើរទេះ ក៏ដោយសារតែ ការរស់នៅឆ្ងាយដាច់ស្រយាលតម្រូវឲ្យគេដោះស្រាយខ្លួនឯង ហើយគេក៏ធ្វើដោយយកចិត្តទុកដាក់ដូចអ្នកសិល្បករម្នាក់ដែរ ។ យើងមិនអាចនិយាយថា គេជាកម្មករ ជាឧស្សាហករ ឬជាពាណិជ្ជករបានឡើយ ។ មានតែដើម្បីការចងចាំទុកទើបគេអាចនិយាយពីរឿងសិប្បករខ្លះ ឬបើនិយាយឲ្យចំ ពីសិល្បករ(ជាងទង)នៅក្នុងវាំង ឬតាមវត្តនានាដែលជាទីលំនៅចុងក្រោយរបស់ឧស្សាហកម្មខ្មែរដែលធ្លាប់រីកចំរើនតាំងពីដើមមក តែឥឡូវត្រូវគេបោះបង់ចោល ប្រៀបបាននឹងការបំភ្លេចចោល ក្នុងរយៈពេលប្រទេសខ្មែរជួបប្រទះនឹងគ្រោះកាចប៉ុន្មានទសវត្សរ៍ក្រោយនេះ។

*បើតាមទ្រឹស្តី ទឹកដីដែលជាទីសក្ការៈ (ព្រះធរណី) គឺជាទ្រព្យរបស់ព្រះមហាក្សត្រ ។ តាមការពិតជាក់ស្តែង ដីជាទ្រព្យរបស់អ្នកដែលធ្វើស្រែឬចម្ការច្បារដំណាំនៅទីនោះ ។ ដីដែលគ្មានអ្នកណាថែទាំចំនួន៣ឆ្នាំត្រូវ ត្រឡប់ចូលរាជទ្រព្យវិញ ។ តែរាស្ត្រអាចស្នើសុំជួលដីនោះធ្វើដំណាំ ។ ការហូតពន្ធទាក់ទងតែទៅលើផលដែល បានមកពីដីប៉ុណ្ណោះ ។ គឺជាការដកហូតផលជាស្រូវមួយចំនួនអំពីទិន្នផលប្រចាំឆ្នាំរបស់ស្រែទាំងឡាយ ដោយ ពួក«ឧកញ្ញាហ្លួង» ដែលជាព្រះរាជដំណាងរបស់ព្រះមហាក្សត្រ គ្មានទាក់ទងជាមួយអភិបាលខេត្តទេ។ គេដូចជា ពួកមីស៊ីដូមីនីស៊ី missi Dominici ពីដើម ជំនាន់ស្តេចស្លារឡឺម៉ាញ Charlemagne ដែលជាអ្នកដើរត្រួតពិនិត្យមើលភោគផលដែលកើតបានមក នៅលើទឹកដីរបស់ស្តេចទាំងប៉ុន្មាន។*

តើប្រាក់ដែលបានមកពីការដកពន្ធនេះទៅណាអស់ទៅ? គឺច្បាស់ជាមាន «ធ្លាក់ឈាមនៅទីណាមួយហើយ !»។ ទីនេះ ក៏មានចិនជ្រៀតជ្រែកលូកដៃទៀតដែរ។

យើងដឹងហើយថាចិនតែងតែជាប់ចិត្តជាមួយទឹកដីដ៏មានជីវជាតិល្អ ពោរពេញទៅដោយពន្លឺថ្ងៃគ្រប់គ្រាន់ទាំងនេះ។ សូម្បីលោកជូតាគ្វាន់ ដែលបានរៀបរាប់តាំងពីសតវត្សទី១៣អំពីទ្រព្យសម្បត្តិស្តុកស្តម្ភនៃប្រទេសខ្មែរ ក៏បានទាយទុកថា នឹងមានជនជាតិគាត់មករស់នៅយ៉ាងច្រើនដើម្បីចម្រើនសេដ្ឋកិច្ចពួកគេនៅស្រុកនេះដែរ។ ដោយការធ្វើដំណើរកាន់តែងាយស្រួល រឿងចំណាកស្រុកចិនក៏កាន់តែច្រើនឡើងៗ ។ ឥឡូវណេះ គ្មានភូមិណាមួយ ទោះនៅចុងកាត់មាត់ញកឬក៏ទីប្រជុំជនណាមួយក្តី ដែលចិនមិនទៅតាំងទីលំនៅទេ។ គេរស់នៅលាយឡំជាមួយរាស្ត្រខ្មែរ ហើយច្រើនយកប្រពន្ធខ្មែរ (លើកលែងតែចិនកន្តាំង) ។ ចិនជាអ្នកប្រមូលទិន្នផលទាំងអស់តាមស្រុកស្រែនិងតាមព្រៃ ។ គេក្តាប់ពួកអ្នកអាជ្ញាធរជាប់ ហើយពឹងលើអ្នកទាំងនេះឲ្យសម្រួលការដើរប្រមូលការប្រាក់ ឬប្រាក់កម្ចីពីរាស្ត្រខ្មែរ។ ធនធានជាប្រាក់ក្តី ជារបស់របរក្តី ត្រូវប្រមូលក្នុងដៃគេ។ *អ្នកមានទ្រព្យសម្បត្តិនៅស្រុកខ្មែរគឺចិន។ ដីល្អៗ ចិនទិញអស់។ ប្រាក់រត់ទៅស្រុកចិនច្រើនណាស់។*

មានសិទ្ធិពិសេសផ្នែកនយោបាយផង ជាថៅកែធំផ្នែកសេដ្ឋកិច្ចផង កូនទេវតានេះ(សំដីនេះមិនហួសហេតុទេ!)រស់នៅស្រុកខ្មែរដូចជានៅក្នុងស្រុករបស់គេអញ្ចឹង ខ្ញុំចង់និយាយថា គេរស់នៅទីនេះគ្រាន់បើជាងនៅស្រុកចិនឆ្ងាយណាស់។ ពីរឿងប្រូតិចតូរ៉ាយើងនេះ អ្នកកំប្លែងគេនិយាយថា៖« *ជាអណានិគមចិន មើលខុសត្រូវដោយបារាំង»។*

ក្រៅពីសកម្មភាពផ្ទាល់ខ្លួនរបស់គេ ពីការឆ្លាតវៃក្នុងរបររកស៊ី ពីការប្រសប់ធ្វើជំនួញ ពីគំនិតពូកែឆ្នៃប្រឌិត ចិននៅមានល្បិចដ៏ឆ្នើមពីរយ៉ាងទៀតសំរាប់ចម្រាញ់យកប្រាក់ពីខ្មែរ ទាំងរាស្ត្រ ទាំងមន្ត្រី រាជការ គឺ ៖ *ការចងការប្រាក់ខ្ពស់ហួសហេតុ និងល្បែង។*

គេដឹងហើយថាតើតម្លៃការប្រាក់ ខ្ពស់យ៉ាងណាក្នុងស្រុកខ្មែរដែលពីដើម ព្រោះតែប្រាក់ប៉ុន្មានត្រណោតសោះដែលគាត់ជំពាក់គេ មនុស្សម្នាក់អាចក្លាយទៅជាទាសករបានរហូតមួយជិវិត ព្រោះការងារគាត់បានត្រឹមតែបង់ការប្រាក់ មិនអាចបង់ដោះដើមកម្ចីទេ ។ រហូតមកដល់ពេលថ្មីៗនេះការប្រាក់ឡើងដល់៣៦% នៅនឹងមុខតុលាការយើងនេះតែម្តង ។ ស្ថានការណ៍នេះ ទោះបីយើងធ្វើយ៉ាងណាក៏ *មិនងាយប្តូរផ្លាស់ភ្លាមទេ។* នៅតាមជនបទ រាស្ត្រសាមញ្ញមិនចេះគិតគូរទុកដាក់ទេ។ ចិននៅជិតនោះជាអ្នកចាំហុច បំពេញការខ្វះខាត ពេលណាគេសម្លឹងឃើញថាគេអាចទាញកំរៃបានច្រើន។ កាលណាជាប់ក្នុងជុជនេះហើយ ខ្មែរនោះរើខ្លួនលែងបានហើយ។ ខ្ញុំស្គាល់ដំបន់ខ្លះ ស្រូវ១រង្វាល់បុលខែប្រាំង ត្រូវសងគេជា៥រង្វាល់នៅរដូវវស្សាបន្ទាប់នោះ ដូច្នេះការប្រាក់ស្មើនឹង ៥០០% ក្នុងរយៈពេល ៦ខែប៉ុណ្ណោះ! កសិករម្នាក់ហ៊ានខ្ចីប្រាក់តែបន្តិចបន្តួច ឧទាហរណ៍ថា១៥ឬ២០ត្រណោត (ព្រោះចិនគេមិនល្ងង់ឲ្យខ្ចីច្រើនពេកទេ) បីខែម្តង ចិនគេធ្វើក្រដាសជំពាក់បំណុលថ្មី ។ លុះ២ឬ៣ឆ្នាំក្រោយមក បំណុលឡើងដល់រាប់រយត្រណោត កសិករនោះត្រូវអស់ដី អស់គោក្របី អស់ខ្លួនប្រាណ ទាំងប្រពន្ធ ទាំងកូនក្លាយទៅជាសម្បត្តិរបស់ចិន។ ខ្មែរធ្លាក់ខ្លួនក្ររហាម អស់ពូជអំបូរ អស់ទឹកចិត្តរលីង នៅសល់តែជម្រើសចុងក្រោយមួយគឺ ធ្វើជា *ទាសកររបស់ចិន។*

បើនិយាយអំពីល្បែងវិញ គេដឹងថាកាលពីមុនមាន «បនល្បែងមួយ» ដែលជាជង្រុកប្រមូលប្រាក់របស់ព្រះរាជទ្រព្យ ។ ក្នុងនាមជាអ្នកមានឧត្តមគតិខ្ពស់ យើងបានលប់បំបាត់បននេះចោលពេលយើងមកដល់ ។ ក៏ប៉ុន្តែ ទីនេះក៏ដូចជាទីណាៗទាំងអស់ *យើងមិនបានផ្លាស់ប្តូរអ្វីឡើយ។* ការលេងល្បែងនៅតែបន្តទៅទៀតដូចពីអតីតកាល ខុសតែផ្ទះបនធំតាមផ្លូវការបានត្រូវគេបិទហើយ បង្កើតបនតូចៗក្រៅច្បាប់វិញ នៅគ្រប់ទីកន្លែង ។ ប្រាក់លែងហូរចូលឃ្លាំងព្រះរាជទ្រព្យទៀតហើយ តែហូរទៅចូលតាមហឹបមន្ត្រីមូលដ្ឋានម្តង។ គេដឹងច្បាស់ថានៅខេត្តណាមានបនប៉ុន្មាន គេស្គាល់ទាំងឈ្មោះមេថៃមទៀតផង។ តើមេនោះមានរឿងអីត្រូវខ្លាច បើគេមានពួកលោកអាជ្ញាធរ មានអ្នកបកប្រែ មានទាំងអ្នកជិតដឹតជាមួយលោកទេសាភិបាលផង នៅចាំជួយគេទៅហើយ ។ បើមានក្រុមប៉ូលិសចុះឆែក ពួកគេចាប់បានតែអ្នកឈរឈ្មោះជួស ឬមេដែលគ្មានបង្អែក។

*ឧទាហរណ៍៖ នៅខេត្តខ្សាច់កណ្តាលមានបនដល់ទៅ៨ ក្នុងមួយថ្ងៃបននិមួយៗបញ្ជូនប្រាក់ចូលហិបលោកអភិបាលខេត្តខ្មែរប្រហែល១០ត្រណោត ជារួមបាន៨០ត្រណោតដោយមិនបាច់ធ្វើការ (១៩១៦-១៩១៦)។នៅជើងព្រៃមាន៧ ។ល។ បើប្រៀបធៀបទៅនឹងបនល្បែងនៅខេត្តបាត់ដំបងដែលយើងទើបនឹងដកហូតពីស្យាមមកកាន់កាប់ខ្លួនឯងវិញ(ដោយរក្សាទុកនូវរបៀបគ្រប់គ្រងមួយពិសេស) តួលេខទាំងនេះមិនជាហួសហេតុពេកទេ ព្រោះនៅបាត់ដំបងមុនពេលបំបិទ«បៀរ៣៦*

*សន្លឹក រូបសត្វ» គេផ្ដល់ឲ្យឃ្លាំងយើងដល់ទៅជាង២០ម៉ឺនត្រណោតក្នុងមួយឆ្នាំៗ ហើយឥឡូវក៏នៅ ៩៦៣ាន់ត្រណោតដែរ។*

ក្នុងចំណោមល្បែងទាំងអស់ មានល្បែងមួយដែលមានភាពចម្រៃជាងគេគ្មានអ្វីប្រដូចបាន គឺ «បៀររូបសត្វ៣៦សន្លឹក»។ ជាការលេងឆ្នោតមួយដែលផ្សព្វផ្សាយទូទាំងប្រទេស តាំងពីទីក្រុងរហូតស្រុកស្រែចុងកាត់មាត់ញក ហើយមិនមែនពិសេសតែចំពោះមនុស្សមួយបែបទេ គឺជាល្បែងដែលទាក់អស់មនុស្សទាំងគ្រួៗនៅតាមផ្ទះ ។ ដំបៅសង្គមនេះរាលដាលគ្រប់ទីកន្លែង សឹងតែគ្មានការលាក់លាមបន្តិចឡើយ។ ជួនកាលជនជាតិស្បែកសយើងក៏ចូលលេងម្ដងម្កាលដែរ។ បើអ្នកភូមិគេដឹងថាយើងស្លូត ឬគ្មានទំនាក់ទំនងជាមួយរដ្ឋបាលទេ ពេលដើរកាត់ភូមិតូចមួយ យើងនឹងអាចឮសួរការចេញឆ្នោតនៅថ្ងៃនោះ ដូចជា«រូបក្ងោក» «រូបខ្លា» ជាដើម។

*សន្លឹកឆ្នោតដែលមានរូបសត្វលើនោះត្រូវគេលក់នៅតាមបន ឬដើរចែកតាមផ្ទះ។ អ្នកលេងដែលមានសំណាង អាចឈ្នះដល់ទៅ៣៦ដងនៃតម្លៃឆ្នោតពេលទិញ ។ «សត្វ»ដែលត្រូវចេញមានរូបរាងធំគ្រាន់ ។ គេខ្ចប់វាបិទយ៉ាងជិត បោះត្រាត្រឹមត្រូវ ហើយព្យួរនៅផ្ទះល្បែងឲ្យឃើញគ្រប់គ្នា ។ អ្នកខ្លះខំទៅដេកយាមកញ្ចប់នោះទល់ភ្លឺព្រោះភ័យខ្លាចគេលួចប្ដូរ។ អ្នកខ្លះទៀតដើរផ្សាយថាខ្លួនចេះទាយធុត អាចមើលឃើញរូបសត្វដែលត្រូវចេញ (គេឈ្មោះថាគ្រូហួយ)។ យើងអាចស្មានបានហើយថាតើមានរឿងផ្លូវងងឹតបែបនេះច្រើនយ៉ាងណា ពិសេសក្នុងភាពលាក់លាមក្រៅច្បាប់ដូច្នេះ?*

របៀបសព្វថ្ងៃនេះ ក្រៅអំពីបង្ហាញការទន់ខ្សោយរបស់រដ្ឋបាលយើង វាពិតជាចម្រៃជាងកាលមានបនតាមផ្លូវច្បាប់ទៅវិញ ។ ប្រាក់មិនបានចូលក្នុងដៃអ្នកទារសារពើពន្ធទេ (មួយភាគធំហូរទៅប្រទេសចិន) ហើយ ដោយអ្នកក្រោយនេះមិនអាចគ្រប់គ្រងរឿងនេះបាន ប្រជាជនដែលស្លូតត្រង់គ្មានអ្នកជួយតាមផ្លូវច្បាប់ក៏ត្រូវគេឆ្មក់លួចឥតប្រណីដៃ ។ បើសិនជាយើងបានជួយតម្រង់ផ្លូវរឿងអាក្រក់មួយដែលជៀសមិនផុត ហើយជាមួយគ្នានោះបានទាញកម្រៃចំណេញខ្លះឲ្យឃ្លាំងផង ប្រហែលជា ត្រឹមត្រូវល្អប្រកបដោយគតិបណ្ឌិតជាង។

យើងមើលទៅដូចជាមិនឃើញមានច្រកណាអាចជួយឲ្យខ្មែរងើបឈរបានទេ បើគេចងក្រៀក គេដើរខ្សែលើ គេបោកប្រាស គ្រប់ទិសទីយ៉ាងដូច្នេះនោះ។

ការដឹកគោនាំចេញទៅប្រទេសម៉ានិលថ្មីៗនេះ មើលភ្លាមពីដំបូងឃើញហាក់ដូចជាឱកាសមួយដ៏ល្អដើម្បីរុញសេដ្ឋកិច្ចឲ្យរីកចំរើន ៖ ជាការពិតណាស់ដែល មុនសង្គ្រាម កិច្ចការនេះបាននាំប្រាក់ចំណូលជាមធ្យមដល់ទៅប្រហែល១លានត្រណោតឯណោះក្នុង១ឆ្នាំ។ ប៉ុន្តែស្ដាយណាស់! រាស្ត្រខ្មែរមិនបានក្លាយទៅជាអ្នកមានឡើយ។ ផ្ទុយទៅវិញ ពេលនោះគេបែរជាប្រមូលគោក្របីលក់

ទាំងទទឹងទិស ហើយយកប្រាក់ទៅចាយខ្ជះខ្ជាយអស់ភ្លាម ព្រោះថាឈ្មួញល្មោភចិននេះគេនៅតែពីក្រោយពួកម៉ានិលទិញគោនេះឯង ! ម្យ៉ាងទៀត ពួកចោរក៏ឆ្លៀតឱកាសនេះដែរព្រោះថា ការលក់សត្វទៅក្រៅស្រុកជាមធ្យោបាយមួយដ៏ស័ក្តិសិទ្ធិហើយរហ័សដើម្បីបំបាត់ភស្តុតាងនៃ«អង្គបទល្មើស» (ពោលគឺសត្វដែលគេលួចពីអ្នកស្រុក)។

*ចិនមិនមែនជាជនជាតិអ្នកចិញ្ចឹមសត្វទេ (ការប៉ិនប្រសប់របស់គេបានត្រឹមចេះធ្វើឲ្យជ្រូក ឬសត្វស្លាបមានខ្លាញ់ធំធាត់ប៉ុណ្ណោះ) ។ ផ្ទុយទៅវិញ ខ្មែរហាក់បានទទួលមរតកពីជនជាតិហិណ្ឌូនូវគុណសម្បត្តិខ្លះៗជាអ្នកចិញ្ចឹមសត្វដ៏ល្អ ។ ជាពិសេស គេមានអំណត់ហើយថ្នាក់ថ្នមសត្វធាតុ ធ្វើឲ្យសត្វស្លូត ហើយចេះស្រឡាញ់ និងស្ដាប់គេណាស់ ។ គេដឹងថា បើតាមធម៌ព្រះម៉ានូនៅប្រទេសឥណ្ឌា ធ្វើបាបសទៅលើសត្វពាហណៈមានទោសស្មើនឹងធ្វើបាបសទៅលើមនុស្សលោក។*

ꙮꙮꙮꙮꙮꙮꙮꙮꙮꙮꙮꙮ

# ជំពូកទី៦
# ការវាយតម្លៃលើសង្គមមនុស្ស

និយាយយ៉ាងខ្លីទៅ តាំងពីកន្លះសតវត្សមកនេះ សកម្មភាពយើងនៅប្រទេសខ្មែរអត់បានផ្លាស់ប្តូរស្ថានភាពពីដើមប៉ុន្មានទេក្រៅអំពី ការសាងផ្លូវគមនាគមន៍ខ្លះពេលថ្មីៗនេះ ការចាក់ដីបន្ថែមការតាក់តែងរាជធានីនិងលំនៅដ្ឋានពួកយើងឲ្យទាន់សម័យនិយម ព្រមទាំងការផ្តល់នូវជំនួយល្អៗខ្លះផ្នែកវេជ្ជសាស្ត្រ។ យើងបានកាន់ក្តាប់គេក្នុងទម្រង់ដើមដដែល យើងបានរក្សាភាសារបស់គេ ហើយពិសេសបំផុត យើងបានផ្តល់នូវសុខសន្តិភាពដល់គេ គឺសន្តិភាពជាមួយប្រទេសអ្នកជិតខាងគ្នា។

*បើជាមួយខេត្តបាត់ដំបងវិញ ដែលកាន់កាប់យ៉ាងយូរអង្វែងដោយប្រទេសស្យាម ការប្រៀបធៀបធ្វើឲ្យ ភ្ញាក់ផ្អើលព្រោះអី ប្រជាជននៅទីនោះ (ពិសេសអ្នកធូរធារ) លូតលាស់ដើរទាន់សម័យណាស់។ អ្នកស្រុកសង្កេត ឃើញថា «ពួកគេស៊ីវិល័យជាង» តែមិនបានលើកឡើងថា មានការខុសគ្នាដោយសារពូជសាសន៍ដ៏តិចតួចនោះទេ។*

តាមពិតទៅ ក្រោមសំបកក្រៅដែលបង្ហាញនូវសណ្តាប់ធ្នាប់ ភាពអនាធិបតេយ្យកំពុងតែវាតទីយ៉ាងខ្លាំងក្លា។ គេយកយើងធ្វើជាខែលដើម្បីបង្កើតហើយពង្រឹងរបបជិះជាន់រាស្ត្រដ៏គួរស្អប់ខ្ពើមមួយ។ អ្នកបះបោរនៅឆ្នាំ១៩១៦បានយករឿងអាស្រូវទាំងនោះមកលាតត្រដាងទាំងអស់ ៖ ការគំរាមកំហែងមួលបង្កាច់បង្ខូចរាស្ត្រ ជាវិធីម្យ៉ាងដែលអស់លោកមូលដ្ឋានភូមិយកមកប្រើសម្រាប់រកចំណូល។ជាប្រភពចំណូលដ៏សំខាន់ហើយមានដំណើរការស្រួលសម្រាប់ពួកគេ។ គេគ្មានខ្លាចរអាយើងបន្តិចណាទេ ព្រោះយើងឧស្សាហ៍ផ្លាស់ប្តូរច្បាប់ទម្លាប់ញឹកញាប់ហើយបន្ទាន់ពេក ធ្វើឲ្យរាស្ត្រសាមញ្ញមានការពិបាកតាមដានឲ្យបានយល់ច្បាស់ល្អ។

*យើងមានឧទាហរណ៍រឿងអង្គាសប្រាក់ដើម្បីធ្វើទាន ដូចជា «ទិវា៧៥» «ឆ្នោតស្នេហាជាតិ» ។ល។ នៅតាមស្រុកស្រែ គេចែកចាយឬលក់ឆ្នោតដែលចេញរួចទៅហើយ!...*

*បើមានរាស្ត្រណាម្នាក់ហ៊ានតវ៉ា ក៏មិនងាយបានទទួលការដឹងឮពីអាជ្ញាធរភូមិដែរ ។ ពួកអ្នករាជការក្នុងស្រុកគេជួយគ្នាណាស់ អ្នកប្តឹងនិងអ្នកកាត់ក្តីគឺគេទាំងអស់។ ម្យ៉ាងទៀត ភាគច្រើនសុទ្ធតែជាប់សាច់ញាតិឬខ្សែស្រឡាយជាមួយអស់លោករដ្ឋមន្ត្រីនៅភ្នំពេញ។ ទោះជាបណ្តឹងដាក់ផ្ទាល់ក្នុងដៃលោកទេសាភិបាលនៃប្រទេសបារាំង ក៏គ្មានសង្ឃឹមថាបានសម្រេចដូចបំណងដែរ។ ការពិត លោកទេសាភិបាលនេះនឹងប្រញាប់ប្រញាល់បញ្ជូនសំណុំរឿងទៅឲ្យចៅហ្វាយខេត្តរបស់គាត់បានដឹង ហើយចៅហ្វាយខេត្តនេះក៏... ឯលទ្ធផលគឺ ដូចយើងបាននិយាយពីខាងលើមកហើយ ។*

*ដូច្នេះយើងត្រូវដឹងថាមានជញ្ជាំងមួយខណ្ឌយ៉ាងជិតល្អណាស់ មិនឲ្យរាស្ត្រសាមញ្ញនិងអ្នកដំណាងប្រទេសបារាំងបានជួបស្គាល់គ្នាទេ។*

*នៅដំបន់ខ្លះមានការច្រឡំរឿងហូតពន្ធ«ចង្ក្រាន»។ពាក្យនេះសំដៅលើចង្ក្រានដុតប្រេងខ្លាញ់ត្រីផង(ដែលត្រូវមានពន្ធ) និងចង្ក្រានមុមបីដែលអាចលើកចុះឡើងបានហើយប្រើទូទៅសំរាប់ចំអិនបាយនិងម្ហូបអាហារផង(ឥតជាប់ពន្ធទេ) ។ ដោយមិនអាចជជែកវែកញែករកខុសត្រូវបានពីរឿងនេះហើយក៏មិនចង់ជាប់ជំពាក់រវល់ជាមួយអ្នករាជការ រាស្ត្រដែលខ្លាចខ្លាំងសុខចិត្តយកឈើបីដុំបោះជាប់ក្នុងដីជាមុមបីធ្វើជាចង្ក្រានដាំបាយទៅវិញ។អញ្ចឹងទើបគេច្បាស់ថាបានរួចខ្លួនមិនបង់ពន្ធ។*

*រាល់ពេលដែលគេជួបនឹងការលំបាកខ្លាំងនៅក្នុងជិវិតរបស់គេ គេលូនទៅជ្រកក្នុងភាពទុត៌តរបស់គេ។គេយកពាក្យស្លោកបុរាណមករំលឹកថា «បើអ្នកខ្លាំងត្រូវធ្វើឲ្យគេខ្លាច តែបើអ្នកខ្សោយត្រូវធ្វើឲ្យគេអាណិត»។*

*នៅដំបន់ខ្លះទៀត សូម្បីតែខ្ទមបាក់បែកក៏មិនហ៊ានជួសជុលដែរ ព្រោះរឿងបង់ពន្ធមេព្រៃវាពិបាកពេក!*

នៅមានចោរប្លន់ តាមខេត្តដូចជំនាន់ដើម ។ បើតាមចាស់ៗគាត់និយាយថា ក្នុងរយះពេល ១៥ទៅ២០ឆ្នាំក្រោយនេះ មានការប្លន់ច្រើនជាងមុនទៅទៀត ។ គេដុតផ្ទះអ្នកស្រុក តែអ្នករងគ្រោះដែលស្គាល់មុខចោរក៏មិនហ៊ានប្ដឹងផ្ដល់ដែរ ព្រោះគេខ្លាចចោរមកសងសឹកវិញ ។ ឧក្រិដ្ឋកម្មមួយចំនួនគ្មានទទួលទោសពៃរ៍អ្វីទាំងអស់ ។ ពួកចោរសុទ្ធតែមានអ្នកការពារពីក្រោយគ្រប់កន្លែង ។ អសន្តិសុខមានលើទ្រព្យសម្បត្តិនិងលើខ្លួនបុគ្គល នៅតាមទីជនបទនានា។ យើងពិចារណាមើលចុះ! អ្នកស្រែគ្នាក្រហើយ ត្រូវគេកេណ្ឌទៅធ្វើពលកម្ម ត្រូវរកប្រាក់បង់ពន្ធ ត្រូវរងគ្រោះដោយការជំរឹតប្រាក់ពីពួកមន្ត្រី លុះដល់ពេលយប់ត្រូវដេកទាំងភ័យញ័រចំប្រប់ទៀតព្រោះខ្លាចចោរព្រៃមកប្លន់ ឬមកដុតផ្ទះ!

*ក្នុងចំណោមបទឧក្រឹដ្ឋទាំងអស់ ការដុតផ្ទះដោយចេតនាជាទង្វើដែលងាយជាងគេបំផុតព្រោះអីខ្ទមខ្មែរសង់ខ្ពស់ពីដី (ជាផ្ទះនៅឥណ្ឌូចិនជាន់ដំបូងនិងនៅម៉ាឡេស៊ី ពោលគឺផ្ទះខ្មែរ ឬផ្ទះអ្នកដែលមានភាសាដូចខ្មែរ ចាមនិងម៉ាឡេ។ល។) ងាយនឹងឆេះណាស់ ។ ដូច្នេះសុបិន្តរបស់អ្នកស្រុកទាំងអស់គឺចង់ប្ដូរដំបូលក្បឿងមកជំនួសដំបូលស្បូវ យកក្ដារឈើមកធ្វើជញ្ជាំងជំនួសស្លឹក។*

*សំណង់ទាំងនេះស្របទៅតាមធាតុអាកាសនិងទីកន្លែង ហើយផ្ដល់នូវប្រយោជន៍ផ្នែកអនាម័យ ជាពិសេសចំពោះទីដំបន់ដែលមានជាតិស្អុយរលួយមកពីភក់ជ្រាំ ។ យើងអាចនិយាយថា ផ្ទះ*

*របៀបនេះពិតជាបាន ជួយដល់ជនជាតិខ្មែរឲ្យមានរូបកាយមាំមួន មានសុខភាពល្អ ជៀសវាងជម្ងឺរបេងបានមែន ពិសេសនៅតាមជនបទ។*

នៅសម័យដែលខ្ញុំដើរចាក់«វ៉ាក់សាំង» ឬថ្នាំការពារនៅតាមជនបទឆ្ងាយដាច់ស្រយាល តាមដំណាក់និមួយៗដែលធ្លាប់ទៅរាល់ថ្ងៃ ខ្ញុំឃើញសឹងតែរាល់លើកថា ក្នុងចំណោមអ្នកមកមើលពេទ្យតែងមានក្រុមអ្នករងគ្រោះថ្មីៗដោយសារពួកចោរប្លន់ ៖ ខ្លះរបួសធ្ងន់ ខ្លះស្រាល ខ្លះបាក់ដៃឬជើង។ ថ្ងៃមួយអ្នករងគ្រោះម្នាក់បានធ្វើការចាប់អារម្មណ៍ជាមួយខ្ញុំថា៖«*តើអ្នកស្លូតត្រង់ត្រូវធ្វើម៉េចដើម្បីទប់ទល់នឹងមនុស្សអាក្រក់? តើឈ្លូសត្រូវទប់ទល់យ៉ាងម៉េចជាមួយខ្លា? មនុស្សសាមញ្ញម្នាក់ដែលស្លូតត្រង់ គ្មានអាវុធក្នុងដៃ គិតតែខំរកប្រាក់ចិញ្ចឹមកូន (គេជាកោសិកាដ៏ស្លូតត្រង់មួយរបស់សង្គម) តើធ្វើម៉េចទើបគេអាចឈ្នះបានទៅ? គេធ្វើម៉េចនឹងហ៊ានតទល់ជាមួយមនុស្សគ្មានការអៀនខ្មាស មនុស្សអាវ៉ាសែ មនុស្សដែលធ្លាប់ជាប់គុកច្រវាក់ទាំងនេះ*»។

តាមការពិត អ្នកប្រកបការងារ អ្នកបង្កើនផលពេញទាំងប្រទេស ត្រូវការចាំបាច់ឲ្យមានការការពារ ថែទាំគាំពារពួកគេ ទប់ទល់នឹងការបំផ្លិចបំផ្លាញដោយក្រុមកម្ទេលសង្គមនេះ។ តែនៅចំពោះមុខការប្រយុទ្ធមិនស្មើភាពគ្នានេះ ពួកគេសុំចុះចាញ់ជាមុន ហើយខំសម្របសម្រួលការរស់នៅទៅតាមកាលៈទេសៈ ។ អញ្ចឹងហើយបានជារឿងរ៉ាវឧក្រិដ្ឋកម្មក្តី ការលួចប្លន់ក្តី ជនពាលមួយចំនួនបានគេចផុតពីការជាប់ចោទ ឯអាជ្ញាធរបារាំងក៏រឹតតែឥតបានដឹងឮរហូត ។ ចំពោះអាជ្ញាធរមកដល់ថ្មី មិនដែលស្គាល់រាស្ត្រក្នុងស្រុកផង ខ្វះទំនាក់ទំនងផ្ទាល់ជាមួយពួករាស្ត្រផង លោកពិតជាហ៊ានអះអាងថា «គ្មានបញ្ហាទេនៅក្នុងខេត្តរបស់លោក»។ តើឲ្យលោកឮពាក្យតវ៉ាទាមទារជំនួយសន្តិសុខនៅតាមភូមិស្រុកនេះម្តេចនឹងកើត បើគ្រាន់តែអ្នកស្រុកហើបបន្តិចគេបំបិទមាត់ទៅវិញបាត់ទៅហើយនោះ។

ខ្ញុំសុំលើកឧទាហរណ៍មួយក្នុងចំណោមរឿងរាប់រយពាន់ ដើម្បីបញ្ជាក់ពីផលវិបាកក្នុងសង្គមដែលកើតឡើងដោយអសន្តិសុខតាមជនបទនេះ ។ កសិករម្នាក់ចង់លក់គោមួយនឹមរបស់គាត់ ។ ជារឿងសាមញ្ញសោះ ប៉ុន្តែគាត់បែរជាធ្វើដោយលួចលាក់ ៖ ដំបូងគាត់លាក់មិនឲ្យអ្នកណាដឹងពីគោលបំណងនេះទេ។គាត់រង់ចាំឱកាសល្អទើបរកលេសចេញទៅស្រុខឆ្ងាយដោយយកទាំងគោទៅជាមួយផង ។ លុះលក់បានប្រាក់រួចរាល់ត្រឡប់មកផ្ទះវិញក៏មិនទាន់ប្រាប់អ្នកណាដែរ បើគេដេញដោលត្រូវរឿងក៏និយាយតរបង្វែងដានទៅវិញ ។ គាត់ទុកឲ្យពេលវេលាកន្លងទៅយ៉ាងយូរមុននឹងសារភាពពីរឿងលក់គោនេះ។ ទង្វើអូសបន្លាយឲ្យខាតបង់ពេលវេលាទាំងអស់នេះគឺមកតែពីរឿងមួយគត់ ៖ ដោយខ្លាចចោរមកប្លន់ គាត់ត្រូវមានពេលយកប្រាក់ទៅលាក់ទុកដាក់សិន មុននឹងឲ្យគេឯងបានដឹង។

គេអាចជួបរឿងរ៉ាវរបៀបនេះរហូតមកដល់ជាយក្នុំពេញ។ ដូច្នេះដើម្បីរកកំណប់ទាំងនោះ ពួកចោរនៅសល់តែមធ្យោបាយមួយគត់ ក្នុងរយៈពេលថ្មីៗនេះ គឺ«សួ»អ្នកស្រុកទាល់តែបានចម្លើយ ។ សូម្បីលោកសង្ឃដែលបានទទួលប្រាក់ទុកឲ្យអ្នកស្រុក ក៏ពួកចោរហ៊ានប៉ះពាល់លោកគ្មាន ញញើតដៃដែរ ! នេះជារោគសញ្ញាដ៏សាហាវមួយ ដែលគេអាចប្រដូចបានតែជាមួយកម្ពុជានៅ សម័យដុនដាបខ្លាំងប៉ុណ្ណោះ !

ដោយហេតុថាយើងគ្មានសមត្ថភាពបំបាត់ការលួចប្លន់នេះ អ្នកអាជ្ញាធរភូមិមិនហ៊ានប្រឆាំង នឹងចោរទេ គេបែរជារកមធ្យោបាយចងសម្ពន្ធមិត្តជាមួយពួកវាទៅវិញ ។ តើយើងបន្ទោសគេយ៉ាង ដូចម្តេចទៅ? អ្នកណាដែលមិនដឹងថាគុកធំបានធ្វើឲ្យរបូតអ្នកទោសល្បីៗជាច្រើន។ ហើយតើមានអ្វី ចម្លែកទៅបើមានកុងត្រាធានារ៉ាប់រងរវាងពួកចោរនិងប្រជាជនខ្លះៗ ដូចជាពួកជនជាតិចិនជាដើម នោះ!

តែស្ថានភាពគួរឲ្យឈឺចាប់នេះក៏ត្រូវបានបន្ធូរបន្ថយខ្លះដោយសារបរិយាកាសផង ដោយសារ ធាតុអាកាសផង ដោយសារធនធានធម្មជាតិដ៏សម្បូរ «បែបប្រទេសកូកាញ»ផង និងដោយសារឥរិ យាបទស្លូត មិនសូវច្រងេងច្រងាង របស់អ្នកស្រុកផង ។ ប៉ុន្តែពេលខ្លះគឺដោយសារពួកចោរផ្ទាល់តែ ម្តង ព្រោះថាមានអ្នករងគ្រោះមួយចំនួនចេះនិយាយលួងលោមរហូតទាល់តែពួកចោរទន់ចិត្តអាណិត ពួកគេវិញបាន។

*នៅពេលដែលគេភ័យរន្ធត់ អ្នកភូមិមិនខ្លាចនឹងបន្ទាបខ្លួននៅពីមុខចោរហើយលើកកំពស់ពួក វាទេ។ ខ្លាចផង គោរពផង (ច្របូកច្របល់គ្នា) គេមិនញញើតហៅចោរថា«លោក»ទេ ដូចជាគេហៅ សត្វខ្លាថាជា«លោកម្ចាស់»ក្នុងព្រៃដែរ។ យើងធ្លាប់បានឮគេនិយាយថាពួកចោរនេះក៏ចេះមានការ អាណិតអាសូរដែរ(ពិសេសចំពោះកូន ក្មេង អ្នកជម្ងឺ និងមនុស្សចាស់ជរា)។ ជារឿងមួយដែលគួរឲ្យ គេស្ងើចសរសើរខ្លះដែរ។*

ការខំប្រឹងបង្កើតរឿងកែប្រែថ្មីៗ (ក្នុងបំណងពិសេសសម្រាប់ឲ្យមានរឿងនិយាយតាមព្រឹត្តប័ត្ររដ្ឋបាលរបស់យើង) មិនគ្រាន់តែមិនបានឲ្យលទ្ធផលល្អប្រសើរផ្នែកសន្តិសុខ ឬធ្វើឲ្យប្រទេសបាន ចំរើនក្នុងចីរភាពទេ ផ្ទុយទៅវិញវាច្រើនតែបង្កការយល់ច្រឡំស្មុគស្មាញថែមទៀតនៅក្នុងសតិ អារម្មណ៍ប្រជាជនក្នុងស្រុក។

*ក្នុងបណ្តាប្រទេសដែលប្រកាន់ប្រពៃណី យើងអាចទុកជាគោលការណ៍ថា នៅរាល់ពេល ដែលមានការផ្លាស់ប្តូរ ក្រៅពីការជ្រួលច្របល់ជៀសមិនផុត នឹងមានការកកើតស្របជាមួយគ្នានូវមុខ ងារប៉ារ៉ាស៊ីតមួយដែល ឆ្លៀតពេលនោះដើម្បី គេចំរាញ់យកផលប្រយោជន៍ថែមទៀតអំពីអ្នកស្រុក*

*ល្ងង់ខ្លៅ ។ ពាក្យទំនៀមបុរាណមួយគេថា«លើកស្នា រំអាក្អែក» គឺគេប្រើកលឧបាយព្យុហ៍ឲ្យខ្លាចរអា ប៉ុន្តែមិនបម្រុងនឹងបៀតបៀនទេ ប្រហែលដូចជាគេគ្រាន់តែលើកស្នាផ្គងឡើង ឲ្យក្អែកខ្លាចប៉ុណ្ណោះ។*

យ៉ាងហោចណាស់ក៏ ការរកយុត្តិធម៌មជំនាន់ដើម នាសម័យយុគកណ្ដាល ដែលប្រើច្បាប់រំលោភបំពានមែនតែ បានការពារសណ្ដាប់ធ្នាប់មួយទៅតាមទំនៀមទំលាប់ដែលឲ្យសិទ្ធិឈ្នះដល់អ្នកខ្លាំងជាងគេដែរ។ ជំនាន់នោះគេមានគោលការណ៍ជាក់លាក់ ៖ គេដាក់ទោសដល់ពួកចោរឧទ្ទាម មិនឲ្យរួចខ្លួនទេ។ នរណាក៏ខ្លាចច្បាប់នេះដែរ ព្រោះស្របទៅនឹងស្ថានការណ៍ ហើយមិនយោគយល់នរណាទាំងអស់។ ចំណែកយុត្តិធម៌របស់យើងវិញ មិនស្របនឹងសេចក្ដីត្រូវការក្នុងស្រុកទេ ៖ គ្មានប្រសិទ្ធិភាព គ្មានកម្លាំង មិនច្បាស់លាស់ និងធ្វើឲ្យរំជើបរំជួល ។ ប្រជាជនខ្មែរនិយាយថា៖ ទោះក្នុងគោលបំណងល្អយ៉ាងណា ក៏យុត្តិធម៌នេះ«សម្រាប់ជួយតែមនុស្សកំហូចទល់នឹងអ្នកស្លូតត្រង់ប៉ុណ្ណោះ»។ ការអត់ឱនរបស់យើងបានចំណេញតែទៅលើជនទុច្ចរិត ។ ការប្រឹងប្រែងបញ្ជ្រាបរបស់យើងរឹតតែត្រូវសាច់រឿង ពួករបិលរប៉ូចថែមទៀត។ពួកវាមិនរំភើបចំពោះការសំរាលទោសដែលយើងធ្វើដល់មនុស្សខូចដូចវាទេ ពេលចេញពីគុក វារត់ទៅនៅស្រុកលើឆ្ងាយ ដើម្បីវាអាចវាតអំណាចពេញទី។

យើងអាចយល់បានពីការខ្លាចមិនហ៊ានធ្វើជាសាក្សីរបស់ប្រជាជនដែលរស់នៅក្នុងព្រៃដាច់ស្រយាលតាមរបបសម័យយុគកណ្ដាល ព្រោះថាគេអាចទទួលការសងសឹក ការផ្ចាញ់ផ្ចាល ដោយងាយស្រួលបំផុត។ ក៏ប៉ុន្តែយើងដឹងដែរថា ការធ្វើសាក្សីក្លែងក្លាយអាចនាំមកនូវផលប្រយោជន៍ដល់អ្នកដែលមិនព្រមសារភាព។ មិននិយាយ ឬក៏និយាយក្លែងក្លាយ បូករួមទៅគឺប្រឆាំងនឹងការពិតទាំងអស់!អ្នកណាដែលធ្លាប់បានអង្គុយស្ដាប់ការកាត់ក្ដីនៅក្នុងតុលាការរបស់យើងរួចមកហើយ មិនអាចទុកចិត្តបានលើស្ថាប័នមួយ ដែលអ្នកបកប្រែជា«មេធំផ្ដាច់ការ» ដែលមានជញ្ជាំងមួយបិទយ៉ាងជិតរវាងចៅក្រមនិងកូនក្ដី បិទជិតជាងជញ្ជាំងអាជ្ញាធរជាមួយកូនចៅក្នុងភូមិឃុំទៅទៀត។

*ដោយខ្ញុំធ្លាប់ធ្វើជាមេប្រយោគ ខ្ញុំហ៊ាននិយាយថា គុណភាពបេក្ខជនដែលមកប្រឡងយកសញ្ញាប័ត្រភាសាក្នុងស្រុកកាន់តែចុះថយជាលំដាប់ក្នុងរយៈពេល១៥ឆ្នាំកន្លងមកនេះ។ ឯការរៀបចំថ្មីៗនេះ (១៩១២) ក៏ធ្លាក់ទឹកទាំងអស់ ៖ ពួកចៅក្រម ក៏ដូចជាពួកអ្នករដ្ឋការទូទៅ សុទ្ធតែមានសញ្ញាប័ត្រត្រឹមត្រូវ តែគេនៅតែពឹងផ្អែកលើអ្នកបកប្រែដដែល ហើយគេមិនទាំងអាចត្រួតពិនិត្យការងាររបស់អ្នកក្រោយនេះបានទាំងអស់ផង ។ ឥឡូវនេះបញ្ហាកាន់តែស្មុគព្រោះគេបញ្ជូនអ្នកមានសញ្ញាប័ត្រភាសាលាវ ឬភាសាអណ្ណាមឲ្យមកធ្វើការនៅស្រុកខ្មែរ។*

នៅក្នុងការកាត់ក្តីរបស់តុលាការខ្មែរផ្ទាល់ ក៏មានភាពច្របូកច្របល់ដែរ។ ច្បាប់ដើមបានត្រូវគេកែប្រែផ្លាស់ប្តូរ ឯច្បាប់ថ្មីក៏ធ្វើទាំងតក់ក្រហល់មិនទាន់បានចប់ស្រួលបួលនិងសមស្របទៅនឹងតម្រូវការបច្ចុប្បន្នផង។ ខ្មែរនិយាយប្រដូចយុត្តិធម៌ក្នុងស្រុកគេទៅនឹង ដាវថ្មីដែលគេទើបនឹងសំលៀងយ៉ាងមុត ហើយដាក់នៅក្នុងដៃមនុស្សខ្វាក់ម្នាក់ !

*អត់ពីតុលាការជំនាន់ដើមរបស់គេទៅ* ដោយតុលាការយើងមិនអាចជំនួសបាននោះ ជាតុអ្នកទៀងត្រង់ អ្នកធ្វើការឈ្មុសឈ្មុលក៏បែរជាគាំងស្លាប់ដៃជើង ព្រោះគ្មានច្បាប់ការពារពួកគេតទល់នឹងជនកំហូចឬជនអ្នកដៃដល់ទៀត ។ *នេះជាស្ថានភាពដ៏ធ្ងន់ធ្ងរមួយ ក្នុងចំណោមរឿងដែលគួរឲ្យព្រួយបារម្ភនៅក្នុងស្រុកខ្មែរ !*

ក៏ប៉ុន្តែ ក្នុងចំណោមបញ្ហាចាំបាច់ទាំងឡាយដែលត្រូវប្រឈមភ្លាមៗ ការរៀបចំច្បាប់តុលាការឡើងវិញពិតជារឿងមួយដែលយើងគួរតែធ្វើបានយ៉ាងងាយ។ នៅប្រទេសស្យាមគេបានរៀបចំរឿងនេះតាំងពីយូរមកហើយ គេបានរើសតែអ្នកពូកែចេះដឹងច្បាប់តុលាការច្បាស់លាស់ មានលក្ខណៈសម្បត្តិល្អឥតទាស់ពិតប្រាកដ។ យើងដឹងថា នៅស្រុកខ្មែរ គេបានសាកល្បងធ្វើរបៀបណាដែរនៅក្នុងន័យនេះ៖ការត្រួតពិនិត្យផ្នែកតុលាការជាន់ខ្ពស់បានត្រូវគេប្រគល់ផ្តាច់មុខទៅឲ្យមនុស្សតែម្នាក់ជាអ្នករដ្ឋការដែលគ្មានសមត្ថភាពអ្វីបន្តិចណាសោះ ។ ផ្ទុយពីនៅតុងកឹង (ជាដើម) ដែលមានចៅក្រមទាំងក្រុមទៅហើយនៅសាលាឧទ្ធរណ៍ ក៏ធ្វើការដ៏ធំធេងនេះសឹងមិនចង់ទាន់ផង។

ក្នុងការគ្រប់គ្រងទូទៅផ្នែករដ្ឋបាលរបស់យើង (ទាំងសេវាកម្មគ្រប់គ្រង ទាំងសេវាកម្មបច្ចេកទេស)ដោយសារអ្នកដំណាងគ្មានចិរភាព សកម្មភាពទាំងអស់មានលក្ខណៈបណ្តោះអាសន្ន លក្ខណៈប្រញាប់ (គុណវិបត្តិធំរបស់រដ្ឋបាលគឺការមិនចងចាំ មិនបន្តដំណើរទៅមុខ មិនចេះតភ្ជាប់កុំឲ្យដាច់) ។ តើមានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលបើការអនុវត្តរបស់គេច្រើនតែបរាជ័យ (ទោះបីអ្នកបំពេញការងារខំប្រឹងប្រែងអស់សមត្ថភាពយ៉ាងណាក៏ដោយ) ដល់ទីបញ្ចប់ ឃើញបានតែសំដី និងការធ្វើពុតលលេងប៉ុណ្ណោះនោះ?

*ខ្ញុំធ្លាប់ឆ្លងកាត់ប៉ុស្តិ៍ធ្វើការជាច្រើនក្នុងពេលខ្ញុំដើរចាក់វ៉ាក់សាំង ក្នុងចំណោមអ្នករដ្ឋការគ្រប់គ្រងដំបន់សំខាន់ទាំងបី (លោករ៉េស៊ីដង់ លោកលេខាធិការ និងអ្នកបើកប្រាក់) គ្មាននរណាម្នាក់ចេះទាក់ទងជាភាសាខ្មែរជាមួយអ្នកស្រុកទេ ។ ប៉ុន្តែ ខ្ញុំបានដឹងថា មានអនុក្រិត្យ ឬសារាចរប្រហែលជា១០ទាក់ទងនឹងការចាំបាច់ឲ្យអភិបាលខេត្តចេះភាសាខ្មែរ ។ តែ លិខិតទាំងនោះទុកជាមោឃៈឥតបានការ។*

*មានក្រិត្យព្រះរាជាមួយនោះបានហាមប្រាមមិនឲ្យមន្ត្រីរាជការជក់អាភានជាដាច់ខាត !*

*ក្រិត្យមួយទៀតបានលប់បំបាត់ការដាក់ច្រវាក់ នៅក្នុងស្រុកខ្មែរទាំងមូល....! ។ល។ និង ។ល។*

*តែអ្វីដែលមានលក្ខណៈ រាក់សើៗ ហើយមិនទៀងទាត់សោះ គឺការបកប្រែជាភាសាខ្មែរតាមផ្លូវការរបស់យើង ។ គេធ្វើក្នុងភាពប្រញាប់ប្រញាល់ជានិច្ច ភាគច្រើនធ្វើឲ្យរួចតែពីដៃ ជួនកាលមើលមិនយល់ (ឬជួនកាលបែបកំប្លែងទៅវិញផង)។ ជាទូទៅ គេឲ្យសារៈសំខាន់យ៉ាងទាបបំផុតទៅលើអត្ថបទជាភាសាខ្មែរ។ មានតែ«សៀវភៅសិស្សសាលា»ទេទើបគេឲ្យតម្លៃ បើយោងតាមសម្បជញ្ញៈអ្នកអប់រំ។*

តាមពិតទៅ ដើម្បីយកច្បាប់ក្រិត្យក្រមទៅប្រតិបត្តិ ទាល់តែមានការនឹងនខ្ជាប់ខ្ជួន មានពេលវេលាច្រើន និងមានអំណត់។ ត្រូវចេះរៀបចំឲ្យស៊ីសង្វាក់គ្នា ត្រូវសិក្សាគ្រប់ជ្រុងជ្រោយ ស្ទាបស្ទង់សិនបើចាំបាច់ ត្រូវឲ្យហ្មត់ចត់ក្នុងការត្រួតពិនិត្យ។ និយាយឲ្យខ្លីគឺ ត្រូវទុកពេលឲ្យមុខងារនេះបង្កើតអង្គការតាមសម្រួល។ ប៉ុន្តែវាជាការហួសពីសមត្ថភាពរបស់«អ្នកដែលគ្រាន់តែមកមួយភ្លែត»... !

រឿងពិតទាំងអស់នេះ គ្មានអ្នកណាម្នាក់ក្នុងស្រុកដែលមិនទទួលស្គាល់បានទេ។ ស្រួលណាស់បើចង់បានភស្តុតាង ៖ មានរឿងមួយយ៉ាងសាមញ្ញដែលបង្ហាញពីកង្វះផ្នែករដ្ឋបាលនេះ គឺរឿងចុះអេតាស៊ីវិល។ ច្បាប់នេះមាននៅតែលើក្រដាសទេ គឺលើក្រិត្យរបស់ហ្លួងដែលចេញតាំងពីឆ្នាំ១៩០៨។ តាមការពិតទៅ ការជំរឿនប្រជាជនមិនដែលបានធ្វើដោយហ្មត់ចត់ទេ ទោះបីនៅក្នុងដំបន់ទីក្រុងភ្នំពេញក៏ដោយ។ បើយើងលើកយកការជំរឿននៅឃុំចោមចៅ កាលពីឆ្នាំ១៩១៥ ការរាប់តាមតួលេខបញ្ជី (របៀបតែម្យ៉ាងគត់របស់យើង) បានឲ្យចំនួនប្រជាជនពីរពាន់និងចិតសិបនាក់ (២០៧០)។ ពេលនោះមានមន្ត្រីបារាំងម្នាក់គាត់ចង់ប្រៀបធៀប ក៏ដើររាប់យ៉ាងត្រឹមត្រូវតាមផ្ទះ ហើយបានលទ្ធផលដល់ទៅបីពាន់បួនរយនាក់(៣៤០០)។

យើងផ្តល់ក្រដាសគំរូចុះអេតាស៊ីវិលដោយឥតគិតថ្លៃទេ តែអាជ្ញាធរភូមិបានដាក់តម្លៃផ្សារក្រៅច្បាប់មួយ ។ ឧទាហរណ៍នៅភូមិមួយឈ្មោះ កំពង់ ត...៖ ពួកគេបានទាមទារពីអ្នកភូមិដែលមកចុះសំបុត្រកំណើតឲ្យកូន នូវប្រាក់ចំនួន១ត្រណោត ថែមទាំងស្រាសពីរដបផង(នៅឆ្នាំ១៩១៦)។ បើសិនជាមកយឺតយ៉ាវ គេនឹងពិន័យ១ថ្ងៃ១ត្រណោតថែមទៀត។

តើឲ្យយើងភ្ញាក់ផ្អើលយ៉ាងម៉េចទៀតអំពីបរាជ័យនៃការអនុវត្តន៍ច្បាប់ចុះអេតាស៊ីវិលនេះ ? តើនៅមានជំនឿអ្វីទៀត ចំពោះការប្រឹងប្រែងរៀបចំស្ថាប័ន បើគេចេះតែយកទៅកែឆ្នៃឲ្យស្របតាមតែប្រយោជន៍គេដូច្នេះ ! តើនៅពេលឥឡូវ យើងអាចហ៊ានសាកបណ្តុះ«ដំណាំ»អ្វី បើដីនេះមិនទាន់បានគេស្ការត្រឹមត្រូវផង ហើយថែមទាំងពោរពេញទៅដោយសត្វល្អិតចង្រៃទៀតនុ៎ះ !

ខ្ញុំសូមនិយាយអំពីអ្វីដែលយើងបានបង្កើតថ្មីផ្សេងទៀតដើម្បីទុកជាការចងចាំ ព្រោះបើតាមការយល់របស់រាស្ត្រសាមញ្ញ (គេបានឲ្យយើងដឹងកាលពីពេលគេបះបោរនៅឆ្នាំ១៩១៦) អ្នកបង្កើតរឿងថ្មីៗអស់នេះគឺពួកអាជ្ញាធរក្នុងស្រុកដែលមានបំណងចង់ជាន់កករាស្ត្រ។ មានរឿងថ្មីមួយដែលយើងបានធ្វើគឺបង្កើតឲ្យមានអ្នកដំណាងរាស្ត្រនៅ«រដ្ឋសភា» នៅ«ក្រុមសភាខេត្ត» ឬក៏នៅ«សភាសម្រាប់ពិគ្រោះ»។ យើងបានបង្ខំឲ្យអ្នកទាំងនោះធ្វើតាមរបៀបយើង នៅពេលដែលខួរក្បាលពួកគេមិនទាន់ទាំងចាប់បានអំពីភាពជាបុគ្គលម្នាក់ផង ក្នុងសង្គមមួយដែលមានច្បាប់ទម្លាប់មិនសូវច្បាស់លាស់នៅឡើយ ៖ គេឥតមានយល់ពីអ្វីទាំងអស់ដែលយើងចង់បានសោះ។

ឧទាហរណ៍ ៖ សមាជិកខ្លះដែលជាប់ឆ្នោតក្នុង«សភាពិគ្រោះ» (គេជាដំណាងរាស្ត្រខ្មែរនៅតាមខេត្ត) ពេលបានឮលោកទេសាភិបាលប្រកាសថានឹងបើកប្រាក់បំណាច់ឲ្យម្នាក់៣ត្រណោតក្នុង១ថ្ងៃនៅពេលទៅធ្វើការនៅភ្នំពេញ ក៏សួរដោយត្រង់ទៅលោកទេសាភិបាលវិញថា «តើពួកយើងត្រូវបង់ប្រាក់ប៉ុន្មានដើម្បីសុំមិនបាច់ទៅវិញ?»។ នៅកន្លែងមួយទៀត មានដំណាងរាស្ត្រម្នាក់ហ៊ានឲ្យដល់ទៅ ២០០ត្រណោតដើម្បីបានរួចខ្លួន...។

នៅទីបំផុត ដើម្បីបំភ្លឺអំពីភាពមិនចុះសំរុងគ្នាជាអចិន្ត្រៃយ៍រវាងទ្រឹស្តីនិងការអនុវត្តន៍ នៅគ្រប់មែកធាងនៃការផ្តួចផ្តើមកិច្ចការអប់រំរបស់យើង យើងអាចនិយាយប្រដូចថា យើងបានរៀបចំក្រុមភ្លេងដែលមានសមាជិកជិតគ្រប់ ដាក់នៅគ្រប់ទីកន្លែង យើងបានចំណាយឥតសំចៃដើម្បីទិញឧបករណ៍ភ្លេងដ៏ប្រណិត យើងបានទាំងដាក់សន្លឹកអក្សរភ្លេងដ៏ថ្លៃនៅលើជើងទ្រហើយស្រេច វានៅខ្វះតែរឿង មួយ ៖ យើងឥតបានបង្ហាត់ភ្លេងដល់អ្នកលេង!។

ខ្មែរអ្នកមានជំនឿអូមអាមគេនិយាយថា «ភាពខាងក្រៅធ្វើ ឲ្យភ័ន្តច្រឡំលើភាពពិតដែលគេចង់បិទបាំង»។ ដូចគ្នានេះដែរ «ភាពពិតមិនទៀងទាត់ អាចធ្វើឲ្យរបួសថ្នាំងថ្នាក់ដល់ភាពពិតជាក់ប្រាកដ»។

ឯយើងធ្លាប់និយាយថា «អត្តរូប បានឈ្នះលើ អត្តន័យ»។

## ជំពូកទី៧
## សេចក្ដីបញ្ចប់

ក៏ប៉ុន្តែ ក្នុងពេលដែលសាកលលោកកំពុងក្រឡាប់ចាក់ក្រោយសង្គ្រាមលោកថ្មីៗនេះ ក្នុងពេលដែលគេស្រេកឃ្លានចង់ផ្លាស់ប្តូរចូលក្នុងយុគកំណើតថ្មី បន្ទាប់ពីការបង្ហូរឈាមដ៏ច្រើនមក តើធ្វើម៉េចយើងនឹងអាចស្រមៃថា ប្រទេសបារាំងក្រោយសង្គ្រាមក៏នៅតែ«បានតែមាត់ក្រៅ » «សប្បាយនឹងបំភាន់ភ្នែក» ហើយ« ឲ្យតម្លៃតែលើសំបកក្រៅ»ទៀតដូច្នេះ ! «ចំណង់ស្វែងរកការពិត»ជារឿងជៀសមិនបាន។ ព្រលឹងមួយដែលចង់តែឈ្នះនឹងដឹកនាំគេគ្រប់សកម្មភាព។ របៀបរបបថ្មី ត្រូវតែកំណត់ដោយផ្លូវនយោបាយមួយដែលស្មោះត្រង់ជាមួយជនរួមជាតិខ្លួន ដោយគិតដល់ប្រយោជន៍ពួកគេផង និងជាមួយជនជាតិឯទៀតដែលនៅក្រោមការគ្រប់គ្រងរបស់របបនេះផង។

ធ្វើក្លែងបន្លំប៉ុណ្ណឹងបានហើយ ! ឈប់យកតែមុខមាត់ទៀតទៅ ! ត្រូវបង្ហាញសមិទ្ធផលវិញ !

ដូច្នេះត្រូវមានទ្រឹស្តីមេមួយចំនួនដើម្បីដឹកនាំនយោបាយនេះ។

1. <u>ជាដំបូង ត្រូវបំបាត់«*ភាពគ្មានលំនឹង*»របស់យើងឲ្យបាន ព្រោះថាតាមភាពជាក់ស្តែង នេះហើយជាដើមហេតុនៃការវង្វេងផ្លូវរបស់យើង។</u>

*យើងអាចលើករឿងមុខដំណែងការងារមួយមកនិយាយ ៖ គ្រាន់តែក្នុងរយៈពេល១ឆ្នាំ មានអ្នកមកកាន់កាប់ បន្តបន្ទាប់គ្នាដល់ទៅ៧នាក់ អ្នកខ្លះពេញមុខ អ្នកខ្លះស្តីទី។ រាស្ត្រក្នុងស្រុកដែលមានផ្ចត់គំនិតជំនាន់សក្តិភូមិនៅ ឡើយ ទៅជាភ័ន្តភាំង ហើយរំជើបរំជួលព្រោះគេមិនយល់នឹងការដូរមន្ត្រីហូរហៃយ៉ាងនេះសោះ។*

*បើប្រើវិធីរបៀបខាងលើនេះ តើធ្វើម៉េចជៀសវាងលទ្ធផលអវិជ្ជមានបាន ? តើធ្វើម៉េចយើងអាចទាមទារឲ្យ មន្ត្រីនោះយកចិត្តទុកដាក់នឹងរាស្ត្រក្នុងស្រុក នឹងភាសា ទំនៀមទំលាប់ នឹងចំណូលចិត្តរបស់សាសន៍គេ ! តើធ្វើ ម៉េចមន្ត្រីនេះគេនឹងអាចរវីរវល់ពីរឿងផ្សេងក្រៅពីខំយកចិត្តចៅហ្វាយធំ ? គេគ្មានការផ្តើមគំនិត គ្មានចំណង់ ចិត្ត គេមិនចង់ស្គាល់ជាតិសាសន៍សង្គមថ្មី មិនចង់ដឹងឮរឿងរ៉ាវអ្វីទាំងអស់ គេធ្វើតែការងារប្រចាំថ្ងៃ ក្នុងគោលបំណង តែមួយគត់ គឺកសាងអនាគតការងាររបស់ខ្លួនគេផ្ទាល់ប៉ុណ្ណោះ !*

*ធ្វើម៉េចមន្ត្រីនេះនឹងអាចមានទឹកចិត្តជាឪពុកម្តាយ ដូចដែលខ្មែរទូទៅតែងទុកដាក់អ្នកបង្ហាត់បង្រៀនឬអប់រំគេ ! គេហៅយើងថាគ្រូ (មកពីពាក្យសំស្រ្កឹតថាគុរុ) គេហ៊ាននិយាយប្រាប់យើងពី*

*រឿងរ៉ាវក្នុងជម្រៅចិត្ត ពីរឿងអាថ៌កំបាំងរបស់គេ ដោយឥតលាក់លាមអ្វីទាំងអស់ ! ជាងទីណាៗទាំងអស់ នៅស្រុកនេះ យើងជាអ្នកអប់រំត្រូវមានព្រលឹងដូចជាអ្នកផ្សព្វផ្សាយសាសនា ដើម្បីបំពេញការងារដ៏ថ្លៃថ្នូរតែសែនពិបាកនេះ។*

យើងអាចរំពឹងមើលថា បើសិនជាលោកអាចទទួលខុសត្រូវលើការងារផ្ទាល់ក្នុងរយៈពេល១០ ឬ ១៥ឆ្នាំជាប់នៅស្រុកនេះ ទោះបីត្រូវឈប់សម្រាក ឬទៅបំពេញបេសកកម្មនៅប្រទេសក្រៅម្តងម្កាលក៏ដោយ តើលោកទេសាភិបាលនឹងមានកម្លាំងខ្លាំងយ៉ាងណាទៅ ?

*ក៏ប៉ុន្តែកន្លែងនេះ យើងត្រូវជំពប់នឹងរឿងបង្ការរបស់រដ្ឋបាលមួយដែលអាចនៅជាគ្រោះចង្រៃយូរទៅទៀតសម្រាប់ប្រទេសខ្មែរដ៏អភ័ព្វនេះ៖ បើគិតតាមឋានានុក្រមនៃមុខដំណែងធំៗនៅឥណ្ឌូចិនវិញ (ដែលគិតរឿងហិរញ្ញវត្ថុ រឿងថវិកាចំណាយជាធំ) ប្រទេសខ្មែរ ដែលរងគ្រោះដោយសារការវិនិច្ឆ័យរបស់មនុស្ស ត្រូវគេឲ្យចំណាត់ថ្នាក់ ទាបក្រោមគេ។*

*ក្នុងស្ថានភាពនេះ តើមានអ្នករាជការណាដែលជាអ្នកពូកែធ្វើការលេខមួយ មានលក្ខណៈជាអ្នកដឹកនាំពិតប្រាកដហើយមានចិត្តចង់មកជួយយឹតយោងប្រទេសខ្មែរ មករស់នៅលាក់ខ្លួនក្នុងស្រុកដែលគេទាំងអស់គ្នាយល់ឃើញថាជាស្រុកមិនសមនឹងសមត្ថភាពអ្នកខ្លាំងពូកែដូច្នេះ ! គេគ្រាន់តែអើតក្នុងរាជធានីខ្មែរមួយភ្លែតដើម្បីបង្ហាញពន្លឺត្រចះត្រចង់តែមួយរយៈរបស់គេ ព្រោះគេប្រញាប់ឈោងទៅចាប់ដំណែងធំជាងនេះនៅក្នុងរដ្ឋាភិបាលឥណ្ឌូចិន គេប៉ងធ្វើជាទេសាភិបាលថ្នាក់លើនៅតុងកឹង ឬស្តីទីនៅក្នុងរដ្ឋាភិបាលនាយក។ ដូច្នេះប្រទេសខ្មែរដ៏ថ្លៃថ្នូរនេះត្រូវតែបកទៅរកភាពគ្រប់គ្រងមិនឋិតថេរ មិនរីកចម្រើនជាថ្មីម្តងទៀត !*

*រឿងអាក្រក់ទាំងប៉ុន្មានមកតែពីការយល់ច្រឡំពីដំបូងនេះ ៖ ដោយយើងជាបុគ្គលនិយម យើងតែងទម្លាប់ទុកមុខដំណែងដែលជាអ្នកធ្វើឲ្យក្រសួងមួយដើរបានល្អ គ្រាន់តែមាននាទីបន្ទាប់បន្សំសម្រាប់ផលប្រយោជន៍របស់ក្រសួងមួយនោះប៉ុណ្ណោះ។*

យើងកុំភ្លេចឲ្យសោះថា ទោះបីយើងចង់ទៅដល់ទីដៅដោយឆាប់រហ័សយ៉ាងណាក្តី លទ្ធផលដែលបានជាក់ស្តែងហើយនៅឋិតថេរបានយូរ មិនមែនអ្វីក្រៅពីផ្លែផ្កានៃការខំប្រឹងប្រែងស្វែងរកដោយហ្មត់ចត់ ក្នុងរយៈពេលដ៏យូរនោះទេ !

2. <u>ត្រូវសម្របទង្វើទៅនឹងគំនិតគោល ដែលជាអ្នកតម្រែតម្រង់បញ្ហាអាកប្បកិរិយារបស់យើង ហើយពិសេសទៅទៀត **សម្របទង្វើទៅនឹងសំដី** ដែលជាការសម្តែងចេញមកនៃគំនិតនេះ។</u>

ការពិសោធន៍បានបង្ហាញហើយបង្ហាញទៀតដល់អ្នកក្នុងស្រុកថា គម្រោងរបស់យើងទាំងអំបាលម៉ាន ដែលអ្នកដំណាងយើងតែងប្រកាសរាល់លើកដើម្បីដាក់អនុវត្តន៍ ច្រើនតែជាសុន្ទរកថាមួយមានតែពាក្យពេជន៍ពិរោះ ឬមានតែគោលការណ៍នយោបាយសម្រាប់បន្ទន់ត្រចៀកសាធារណជននៅប្រទេសបារាំង តែគ្មានខ្លឹមសារពិតប្រាកដសម្រាប់រាស្ត្រខ្មែរឡើយ ។ ហេតុនេះ ភាពផ្ទុយគ្នារវាង ពាក្យពេជន៍ក្នុងសុន្ទរកថានឹងការអនុវត្តន៍ជាក់ស្តែងក៏ រឹតតែពិបាកឲ្យគេទទួលបាន ។ ជនជាតិអាស៊ីដែលធ្លាប់ភ្ញាក់ផ្អើលនឹងសុន្ទរកថាពួកយើងពីមុន គេឈប់វង្វេងនឹងពាក្យបោកបញ្ឆោត គេឈប់ស្តាប់សំដីផ្អែមល្ហែមទៀតហើយ ព្រោះគេបានលាក់នៅក្នុងជម្រៅបេះដូងរបស់គេថាការមិនគោរពពាក្យសំដីរបស់យើង គឺជាការភរភូតបោកប្រាស។

*សាធារណជនកម្ពុជាមិនចូលចិត្តសុន្ទរកថា ឬក៏ការនិយាយចែប៉ប្រែច្រើន (របៀបជនជាតិស្បែកខ្មៅ និងសាសន៍ដទៃទៀតមួយចំនួន) ទេ ។ គេធ្លាប់ស្គាល់តែការទេសនារបស់ព្រះសង្ឃជាភាសាបាលី ដែលអ្នកស្តាប់ទូទៅមិនទាំងយល់ន័យទាំងអស់ផង។*

មិនត្រូវផ្សព្វផ្សាយគម្រោងណាមួយដែលមិនទាន់បានទទួលការគិតគូរពិចារណាល្អិតល្អន់ឡើយ។ តែបើសម្រេចថាយកវាហើយ ត្រូវតែអនុវត្តឲ្យបានហ្មត់ចត់លុះដល់ទីបំផុត។

3. <u>ត្រូវឈប់ដើរលើផ្លូវនយោបាយទន់ខ្សោយដែលខំបិទបាំងបញ្ហាមិនឲ្យធ្លាយទៅដល់ថ្នាក់លើ អ្នកធ្វើខុសមិនដែលមានទោស ច្បាប់ទម្លាប់ត្រឹមត្រូវក្លាយទៅជាអត់បានការ រឿងពុករលួយរឹតតែរីកដាលព្រោះតែការលើកលែងឲ្យមនុស្សខូច ។ រូបមន្តនយោបាយនោះប្រហែលជាមានរបៀបដូចនេះ៖ *«ត្រូវដកបញ្ហាទាំងអស់ចេញ ដើម្បីជៀសវាងការទទួលខុសត្រូវគ្រប់យ៉ាង»*។</u>

*ការរើសមន្ត្រីរាជការបារាំងមិនបានល្អឲ្យទៅធ្វើការនៅស្រុកខ្មែរនេះមានទំនាក់ទំនងជាមួយនឹងស្មារតីនយោបាយទន់ខ្សោយនេះឯង ។ គេដឹងថា ប្រទេសខ្មែរជាមួយប្រទេសលាវ គឺជា«ទីចាក់សំរាម»ពួកមន្ត្រីក្របខ័ណ្ឌនៅឥណ្ឌូចិន ។ របៀបរៀបចំការគ្រប់គ្រងរដ្ឋបាលនេះចម្លែកណាស់ (បែកចេញមកពីភាពអត្តទត្តបុគ្គល)៖ មន្ត្រីណាទន់ខ្សោយ គេដកទៅដាក់កន្លែងឆ្ងាយ ឆ្ងាយពីអ្នកត្រួតពិនិត្យ ឆ្ងាយពីជំនួយគ្រប់បែបយ៉ាង។ រឿងអស្ចារ្យគឺថា គេផ្តល់ប្រយោជន៍គ្រប់បែបយ៉ាងដល់ភ្នាក់ងារម្នាក់ដែលអន់ឬមិនបានការទាល់តែសោះតែរំខានគេ ដូច្នេះគេឲ្យពិន្ទុល្អ ឲ្យឡើងបុណ្យសក្តិ រួចបញ្ជូនភ្នាក់ងារនោះឲ្យទៅឆ្ងាយផុតពីមុខពីមាត់គេ កាលណាបើមានឱកាសហុចឲ្យ។*

តើយើងអាចស្រមៃថា ថៅកែផ្ទះជំនួញម្នាក់គាត់សុខចិត្តបិទភ្នែកមិនមើលការភាន់ច្រឡំ ឬការកេងបន្លំលុយកាក់របស់គាត់ បានឬទេ? យើងត្រូវមានសេចក្តីក្លាហានបើកភ្នែកមើលដើម្បីស្វែងរកការពិត ។ ទទួលស្គាល់កំហុសដែលបានធ្វើ ហ៊ានមើលវាចំពីមុខ គឺជាល័ក្ខខ័ណ្ឌទីមួយដើម្បីកែលម្អឡើងវិញ។

បោសសម្អាតទីកន្លែងដែលពុករលួយ បំបាត់ដើមដែលមានជម្ងឺដោយដកទាំងឫស គឺជាវិធានការចាំបាច់បំផុតបើសិនជាយើងមិនចង់ធ្វើឲ្យ ការខំប្រឹងប្រែងបណ្តុះបណ្តាលជាបន្តបន្ទាប់របស់យើងខូចអសារបង់។ យើងមើលតែម្ចាស់ចំការទំពាំងបាយជូរ តើគាត់ត្រូវពុះពារពលិកម្មដ៏ធ្ងន់ធ្ងរយ៉ាងណាដើម្បីសម្អាតដីចំការរបស់គាត់ឲ្យអស់នូវសត្វល្អិតចង្រៃ មុននឹងបង្កើតចំការទំពាំងបាយជូរដ៏ល្បីល្បាញរបស់ប្រទេសបារាំងជាថ្មីឡើងវិញនុ៎ះ ? ឯចំណែកវេជ្ជបណ្ឌិតវះកាត់សម័យឥឡូវក៏ដូច្នោះដែរ គេមិនហ៊ានធ្វើការវះកាត់ជាដាច់ខាត លំដាប់ណាដែលកន្លែងត្រូវវះមិនទាន់បានទទួលការលាងសម្អាតឲ្យងាប់អស់មេរោគចង្រៃជាមុនសិនទេនុ៎ះ !

គ្រប់ការងារតម្រូវចាំបាច់ឲ្យមានការការពារទប់ទល់នឹងការឈ្លានពានបំផ្លាញពីក្រៅ។ បើចង់បានផល ត្រូវតែការពារការផលិត។

4. <u>ត្រូវជំនះឲ្យបាននូវ***ការមិនយល់គ្នា*** ពោរពេញទៅដោយការយល់ច្រឡំ រវាងបារាំងនិងរាស្ត្រខ្មែរក្នុងស្រុក «***ការបិទជិតស្លុង***» ដែលបង្កនៅជុំវិញខ្លួនយើងទាំងអស់គ្នានូវតំបន់មិនទុកចិត្តមួយ ដែលធ្វើឲ្យពួកមនុស្សឥតអៀនខ្មាសមួយចំនួនឆ្លៀតឱកាសចូលជ្រាតជ្រែកបាន។</u>

*ការពិតមួយដែលមិនអាចទាត់ចោលបានគឺថា **ពួកលោកទេសាភិបាលចាស់ៗអាចទាក់ចិត្តប្រជាជនខ្មែរឲ្យស្រឡាញ់លោកបាន ។ នេះជារឿងមួយដែលយើងពិបាកស្រមៃឃើញនៅសម័យនេះ** ដូច្នេះយើងត្រូវស្វែងយល់អំពីដើមហេតុរបស់វា ! តើយើងមិនមែនមកទីនេះក្នុងឋានៈជាអ្នករកសន្តិភាព ជាអ្នកជួយប្រទេសខ្មែរទេឬ? មានអស់លោកខ្លះ មានប្រជាប្រិយខ្លាំងមែនទែនជាមួយប្រជាជន (រហូតដល់មានមន្ត្រីក្នុងស្រុកមួយចំនួន ពិសេសអ្នកនៅក្នុងវាំង មានការច្រណែន)។ លោកចេះភាសាខ្មែរ លោកយកចិត្តទុកដាក់នឹងជីវភាពអ្នកស្រុក មានទំនាក់ទំនងមិនសូវដាច់ជាមួយពួកនេះ។ **អ្នកស្រុកស្គាល់ពួកលោកច្បាស់ គេស្រឡាញ់ពួកលោក**។ នៅក្នុងភូមិជាច្រើន នៅពេលដែលខ្ញុំរំលឹករឿងអស់លោកដែលមានឈ្មោះល្បីល្បាញខ្លះ (សូមអានសៀវភៅ «Explorations et Missions de Doudart de Lagrée. Paris. Jules Tremblay, 1883») ភ្នែកអ្នកចាស់ៗក្នុងភូមិនោះមានទឹកភ្នែក*

*រលីងរលោង ព្រោះពួកគាត់ពិតជាមានមនោសញ្ចេតនាជ្រៅជាមួយពួកលោកទេសាភិបាលជំនាន់មុននោះមែន!*

*ការប្រែប្រួលបន្តិចម្តងៗបានចាប់មានមកប្រហែល២០ឆ្នាំហើយ ។ នៅពេលដែលរាស្ត្រខ្មែរចាប់ផ្តើមសង្ឃឹមថានឹងបានស្គាល់ការរះឡើងវិញនូវពន្លឺព្រះអាទិត្យនៃថ្ងៃថ្មីមួយ ស្រាប់តែមានអ្វីមកបិទបាំងពន្លឺនេះមិនឲ្យចែងចាំងទៀត*

*ការកសាងផ្លូវថ្នល់ក្នុងពេលថ្មីៗនេះបែរជាឲ្យលទ្ធផលផ្ទុយពីការស្មានទុក ៖ កាលលោកទេសាភិបាលចាស់ៗជំនាន់មុនធ្វើដំណើរដោយជិះលើសេះ ឬលើខ្នងដំរី តាមជនបទកាត់វាលចូលព្រៃ លោកដឹងសុខទុក្ខ លោកដឹងរឿងរ៉ាវ លោកដឹងពីបំណង ពីសេចក្តីរំពឹងរបស់ប្រជារាស្ត្រជាកូនចៅទាំងអស់ ចំណែកអ្នករាជការសម័យឥឡូវ ដែលគិតតែពីការប្រមូលពន្ធ គេជិះឡានតាម«ផ្លូវធំ»ថ្មីទាំងនេះ(ដែលគេកសាងសម្រាប់សម្រួលការងាររដ្ឋបាលប៉ុណ្ណោះ មិនមែនសម្រាប់ជំរឿនសេដ្ឋកិច្ចទេ!) តែគេមិនស្គាល់រាស្ត្រដែលរស់នៅជិតផ្លូវផងទេ។*

យើងស្គាល់ច្បាស់អំពីដើមហេតុនៃការឃ្លាតឆ្ងាយនេះ ៖ ដំបូងគឺមកពីការខ្វះខាតបុគ្គលិកដែលត្រូវទាក់ទងផ្ទាល់នឹងរាស្ត្រ ជាពិសេសការមិនចេះភាសារបស់រាស្ត្រ (ហេតុអ្វីក៏មានតែពួកលោកសង្ឃបារាំងដែលអាចរៀនភាសាខ្មែរចេះ?)។ គំលាតនេះធ្វើឲ្យកើតការប្រេះឆានៅក្នុងការគ្រប់គ្រងផ្នែករដ្ឋបាល ឲ្យមានគំនិតពីរប្រឆាំងគ្នារាល់សកម្មភាព លុះបានលទ្ធផលគឺសុទ្ធតែលេងសើច ឬអត់បានការ។ ទាល់តែលោកចេះប្រើភាសាស៊ីជម្រៅរបស់អ្នកស្រុក ទើបលោកអភិបាលអាចសម្រេចបំណងដែលចង់បង្កភាពស្និទ្ធស្នាលជាមួយ នឹងរាស្ត្រទាំងអស់របស់លោកបាន។

*ក្នុងការអនុវត្តន៍ អ្វីៗប្រព្រឹត្តទៅ បីដូចជាមានផែនការរដ្ឋបាលពីរថ្នាក់និងបុគ្គលិកពីរក្រុមផ្សេងគ្នាសម្រាប់បម្រើសេវាកម្ម៖ ១/ ថ្នាក់លើ ជាថ្នាក់តែមួយដែលគេទទួលស្គាល់ (ក្រុមពេលថ្ងៃ) តែមិនមានដំណើរការ ២/ ថ្នាក់ក្រោម នៅក្នុងទីកំបាំង (ជាក្រុមរាត្រី) តែពូកែស័ក្តសិទ្ធិ។*

ត្រូវតម្រង់គោលដៅទៅរក«ទំនុកទុកចិត្តគ្នាទៅវិញទៅមក» ព្រោះបើមិនដូច្នេះទេ យើងមិនអាចសង្ឃឹមថានឹងបានទទួលភាពល្អូកល្អិនជាមួយគ្នា ដ៏មានសារសំខាន់ បានឡើយ។ យើងត្រូវប្រយ័ត្ននិងក្រែងជាទីបំផុតនូវការធ្លាក់ទឹកចិត្តរបស់មនុស្សស្មោះ នូវ«កូដកម្មរបស់អ្នកស្លូតត្រង់»។

5. <u>ត្រូវបញ្ឈប់*«នយោបាយជំពាក់ជំពិននឹងពន្ធដារ»* ដែលតែងនាំមកនូវផលវិបាកគ្រប់យ៉ាង ហើយដែលគ្របដណ្តប់គ្រប់ទំនាក់ទំនងរបស់យើងជាមួយប្រជាជនក្នុងស្រុក។ នយោបាយនេះគឺដូចជា«កាប់ដើមព្រោះចង់បានផ្លែ»។</u>

យើងមិនបាច់និយាយច្រើនពេកទេមើលទៅ។ បើនិយាយគឺច្រំដែលព្រោះ អ្នកណាមិនដឹង ដូចជារឿងអាភាន រឿងចាប់ពន្ធគយ ហើយនឹងរឿងព្រៃឈើ ។ល។ ៖ រដ្ឋបាលព្រៃឈើក្លាយទៅជា«សេវាកម្មទទួលប្រាក់»មួយយ៉ាងពេញមុខ ប្រជែងជាមួយគយផង ជាមួយខាងពន្ធដារផង ។ ក្នុងមួយឆ្នាំគេបានប្រមូលប្រាក់ជិតស្មើនឹង«ពន្ធស្រូវ» (សែសិបម៉ឺនត្រណោតនៅឆ្នាំ១៩១៥)។

*ខ្ញុំមិនជឿថាខ្ញុំនិយាយបំផ្លើសទេកាលណាខ្ញុំអះអាងថា មានតែពួកគ្រូពេទ្យ(សេវាកម្មពេទ្យបង្អែក)ទេដែលជាភ្នាក់ងាររាជការហើយដែលចុះទៅជួបប្រជាជនតាមទីជនបទ ដោយមិនរកគួនពួកគេអំពីរឿងពន្ធ រឿងកំណែន រឿងពលកម្ម រឿងជំពាក់បំណុល...ឬអ្វីទាំងអស់ គឺគិតតែអំពីសុខភាពពួកគេទៅវិញ។*

ស្ថានភាពមិនគួរជឿបានរបស់ជនជាតិចិនក្នុងស្រុក ដែលផ្តល់ជាអាទិ៍នូវផលវិបាកធ្ងន់ធ្ងរផ្នែកនយោបាយ គ្មានការបកស្រាយណាទៀត លើសពីនេះឡើយក្នុងពេលបច្ចុប្បន្ន៖ គឺដើម្បីបានចំណេញភ្លាមៗអំពីពន្ធដារដ៏ធ្ងន់ដែលចិនបង់ឲ្យយើង យើងសុខចិត្តបោះបង់អនាគតហើយគិតតែបច្ចុប្បន្ន យើងជ្រើសយកការប្រព្រឹត្តដ៏គួរឲ្យខ្លាចមួយ ដែលផ្ទុយស្រឡះពីប្រយោជន៍របស់ខ្មែរ។

6. <u>យើងត្រូវឈប់ននាលក្រាញចាត់ទុកប្រទេសខ្មែរថា*ដូចជាខេត្តមួយរបស់ប្រទេសអណ្ណាម* ឬគ្រាន់ជាការវាតទីតាំងមួយ (អភ័ព្វក្ររហាម) បន្តពីដែនកូសាំងស៊ីន។</u>

យើងស្គាល់ប្រវត្តិសាស្ត្រស្រុកនេះហើយ។ យើងដឹងហើយថាមានជ្រោះជ្រៅកាត់ប្រទេសទាំងពីរគឺប្រទេសខ្មែរនិងអណ្ណាមឲ្យដាច់ពីគ្នា។ មួយងាកទៅរកប្រទេសចិនទាំងស្រុង។ មួយទៀត ទាំងភាសា របស់គេ ទាំងអក្សរដែលមកពីសំស្រ្កឹត ឬក៏អារ្យធំម គឺសុទ្ធសឹងមានទំនាក់ទំនងទៅជាមួយប្រទេសឥណ្ឌាទាំងអស់។ ដូចជាប្រទេសចម្ប៉ាពីមុន ប្រទេសលាវ និងប្រទេសស្យាមដែរ។

ទីនេះ ពិភពពីរដែលចាស់ជាងគេនៅក្នុងប្រវត្តិមនុស្សលោកបានមកជួបគ្នា តែមានការវិវត្តខុសគ្នា ប្រកួតប្រជែងគ្នា ក្នុងភាពប្រមាថគ្នា ដើម្បីរកឈ្នះរៀងខ្លួន !

ភាពផ្ទុយគ្នានៃសង្គមទាំងពីរកាន់តែរីកខ្លាំងនៅលើចំណុចរសើបជាច្រើន ហើយកាន់តែពិបាកដោយសារការនៅជិតខាងគ្នានេះ (បេះដូងប្រជារាស្ត្រទាំងពីរពោរពេញទៅដោយគំនុំ) និងដោយសារមានកត់ត្រាជាប់ក្នុងប្រវត្តិសាស្ត្រដែលគេមិនអាចបំភ្លេចឬលោតរំលងបាន៖ទោះបីជនជាតិទាំងពីរ

រស់នៅលាយឡំគ្នា ក៏ការចងស្ពានមេត្រីរវាងពូជទាំងពីរនៅតែជារឿងពិសេសតិចតួចបំផុត ក្នុងពេលឥឡូវនេះ។

*ដើម្បីហៅជនជាតិអណ្ណាមខ្មែរមានតែពាក្យមួយម៉ាត់គឺ«យួន» ក្លាយមកពីភាសាសំស្ក្រឹត«យៈវៈនៈ»ដែលមានន័យថា មនុស្សព្រៃផ្សៃមកពីខាងជើង។ ចំណែកពួកអណ្ណាមក៏តែងឆ្លៀតឱកាសជាន់ឈ្លីម្ចាស់ដើមរបស់ស្រុកដែលបានចាញ់សង្គ្រាមដែរ (គេមានពាក្យ«ថូ»សម្រាប់ហៅខ្មែរដោយមាក់ងាយ)។ ការស្អប់ខ្ពើមគ្នាទៅវិញទៅមកនេះនៅតែមានជីវិតរហូតដល់ថា ទោះបីអ្នកម្ខាងមានចិត្តចង់រាប់អានដោយស្មោះក៏អ្នកម្ខាងទៀតស្មានថាជាការលេងសើចមើលងាយទៅវិញ។*

*អ្វីដែលអាក្រក់បំផុតសម្រាប់អ្នកនៅក្រោមការការពាររបស់យើងគឺ អ្នកបំរើរបស់យើងពោលគឺអ្នកនៅជិតជុំវិញយើងក្នុងស្រុកខ្មែរសុទ្ធសឹងជាជនជាតិកូសាំងស៊ីនទាំងអស់ ព្រោះចារឹកខ្មែរមិនចូលចិត្តធ្វើអ្នកបំរើស៊ីឈ្នួល ស៊ីប្រាក់ខែ ខ្វះភាពជិតស្និទ្ធ ដូចដែលយើងចង់បាននោះទេ ។ យើងអាចស្មានបានថា ពួកអ្នកឆ្លាតហើយមានចិត្តឈ្លានពានរបៀបជនជាតិអណ្ណាមនេះនឹងឆ្លៀតឱកាសទាញផលប្រយោជន៍ពីស្ថានភាពនេះដោយយកឥទ្ធិពលយើងទៅប្រើលើពួកជាប់ពន្ធ ព្រោះតែយើងខ្វះការពិសោធន៍។ ពីមួយថ្ងៃទៅមួយថ្ងៃ ការយល់ច្រឡំមានកាន់តែច្រើន ចង្អូរមួយដែលបំបែកយើងឲ្យឃ្លាតពីអ្នកស្រុកកាន់តែធំហើយជ្រៅទៅៗ។ ក្នុងរយៈពេលជាច្រើនឆ្នាំ មន្ត្រីបារាំងណាដែលបានទទួលការចាត់តាំងឲ្យទៅធ្វើការនៅស្រុកខ្មែរដ៏អាថ៌កំបាំងនេះ មន្ត្រីនោះតែងតែរើសពួក«អ្នកបំរើក្នុងផ្ទះ»នៅពេលដែលគេ(ចុះពីកប៉ាល់)មកដល់ព្រៃនគរភ្លាម។ គឺពួកអ្នកបំរើនេះហើយដែលជាអ្នកបង្ហាត់បង្ហាញមន្ត្រីទាំងនោះឲ្យស្គាល់ស្រុកខ្មែរ ទម្លាប់ខ្មែរ ហើយដែលតម្រែតម្រង់ការគិតយល់របស់គេទៅអនាគត។ ស្រុកខ្មែរធ្លាប់ទទួលបាបកម្មក្នុងប្រវត្តិសាស្ត្ររួចមកហើយ (ទាំងផ្លូវនយោបាយ ទាំងផ្លូវសង្គមរបស់ប្រជារាស្ត្រ) ឥឡូវ ដោយសារអ្នកគ្រប់គ្រងខ្លួន ខ្មែរត្រូវទទួលបាបកម្មដោយសារទម្រង់ភូមិសាស្ត្រខ្លួនឯងថែមទៀត។*

*ក៏ប៉ុន្តែ រវាងរាស្ត្រសាមញ្ញកម្ពុជា និងរាស្ត្រនៅតុងកឹង ហាក់ដូចជាគ្មានការស្អប់គ្នាទៅវិញទៅមកឲ្យជាក់ស្តែងទេ បើតាមប្រវត្តិសាស្ត្រ ក្រុមទាំងពីរនេះមិនទាំងស្គាល់គ្នាផង ។ នេះបើតាមការសង្កេតផ្ទាល់ខ្លះៗដែលខ្ញុំបានធ្វើ។*

សូមកុំភ្លេចថាកម្ពុជាបានរត់មករកយើងដោយស្ម័គ្រស្មោះដើម្បីសុំឲ្យយើងជួយការពារអត្ថិភាពរបស់គេ។ តែគួរឲ្យស្តាយ ព្រោះថា ដោយសារគំនិត«សម្ព័ន្ធឥណ្ឌូចិន» (ដែលគិតតែភាពហិរញ្ញវត្ថុ) យើងរុញប្រទេសនេះឲ្យទៅជួបនឹងរឿងអយុត្តិធម៌មួយគឺ យើងធ្វើឲ្យគេនៅក្រោមឥទ្ធិពលទាំងខាងសេដ្ឋកិច្ច និងទាំងខាងនយោបាយខ្លះផង របស់បច្ចាមិត្រសួរពូជខ្មែរ គឺប្រទេសអណ្ណាមនេះឯង។

ចំពោះចំណោទមួយចំនួនដែលពាក់ព័ន្ធទៅនឹងប្រទេសទាំងពីរ ទោះជារឿងសាមញ្ញក៏ដោយ ក៏យើងត្រូវជៀសវាងកុំឲ្យធ្លាក់ចូលក្នុងការច្របូកច្របល់គ្នារវាងប្រទេសទាំងពីរឡើយ។ មិនតែប៉ុណ្ណោះ គេអាចបង្កើតស្វ័យសត្យ Axiome មួយថា៖ អ្វីដែលសម្រេចបានល្អជាមួយអ្នកម្ខាង (វិធី, បុគ្គលិក ។ល។)គឺពិតជាខុសផ្នែកសីលធម៌ជាមួយអ្នកម្ខាងទៀតមិនខាន។ ជនជាតិអណ្ណាមច្រើនបញ្ចេញភាពអង់អាច ហាក់មានការទុកចិត្តលើខ្លួនខ្លាំងណាស់ ផ្ទុយទៅវិញ ខ្មែរច្រើនតែបង្ហាញការដាក់ខ្លួន និងភាពមិនហ៊ានអារកាត់។ ការមិនយល់ដឹងរបស់យើងអំពីចរឹតពិតប្រាកដរបស់ខ្មែរ ការប្រើប្រាស់ជនជាតិអណ្ណាមជាអ្នកបកប្រែឲ្យយើងគ្រប់ពេលមានទំនាក់ទំនងជាមួយខ្មែរ គឺជាគ្រោះចង្រៃ ជាបាបកម្មមួយសម្រាប់ប្រទេសកម្ពុជា ពេលនៅក្រោមការគ្រប់គ្រងរបស់យើង។

*ការប្តូរមន្ត្រីរាជការបារាំងចុះឡើង រវាងប្រទេសកម្ពុជានិងតុងកឹង គឺជាការមិនសមហេតុសមផលតាំងពីដើមទីមកម្លេះ ក៏ប៉ុន្តែគេនៅតែឃើញធ្វើហូរហែរហូតមកសព្វថ្ងៃនេះ។ លោកទេសាភិបាលម្នាក់ដែលមកពីប្រទេសអណ្ណាម ទោះបីមកពីដែនកូសាំងស៊ីនក៏ដោយ ក៏ច្បាស់ជាប្លែកវង្វេងវង្វាន់ស្មារតី ដូចជាគេទៅនៅ«ម៉ាដាហ្គាសកា» Madagascar អញ្ចឹង។ ប្រទេសខ្មែរតម្រូវឲ្យមានកម្មាភិបាលខាងមន្ត្រីនិងខាងថៅក្រមដែលបានទទួលការហ្វឹកហាត់ពិសេស។ យកល្អ (នេះតាមយោបល់ខ្ញុំផ្ទាល់) ត្រូវយកបុគ្គលិកដ៏ឆ្នើម មានជំនាញ ចេះប្រើយុទ្ធសាស្ត្រ ទាំងផ្លូវចិត្ត ទាំងផ្លូវវិទ្យាសាស្ត្រ អាចធ្វើការនៅជិតប្រជាជនខ្មែរដែលខ្លាចញញើតញញើមច្រើន។ ការជ្រើសរើសនិងការតម្លើងបុណ្យសក្តិរបស់មន្ត្រីទាំងនេះត្រូវផ្អែកទៅលើសីលធម៌ផង លើមនោសញ្ចេតនាផង (ឫកពារ ស្លូតបូតទន់ភ្លន់ ចេះយល់ចិត្តថ្លើម ចេះបត់បែនតាមកាលៈទេសៈ។ល។) ទើបអាចធានានាំមកនូវជ័យជំនះឲ្យយើងបាន។*

*ចំពោះចំណុចនេះ យើងមានតែសោកស្តាយប៉ុណ្ណោះ ដោយសារការបន្លំដកយក«សហភាពឥណ្ឌូចិន»ចេញបន្តិចម្តងៗពីព្រំដែនទីតាំងហិរញ្ញវត្ថុរបស់គេ។ ក៏ប៉ុន្តែ ជាការស្រួលសោះបើយើងចង់បង្កើតសហភាពឥណ្ឌូចិនតែមួយ ដែលមានការគ្រប់គ្រងចែកជាពីរដាច់គ្នា តម្រូវទៅតាមខឿនអារ្យធម៌មេរបស់ប្រទេសពីរដែលប៉ះគ្នាតែមិនអាចរលាយចូលគ្នាបាន៖ យើងគ្រាន់តែរើសកម្មាភិបាលមន្ត្រីឥណ្ឌូចិនពីរក្រុម ដែលបានទទួលការហ្វឹកហាត់ពិសេសសម្រាប់តែប្រទេសនិមួយៗ មិនឲ្យដោះដូរគ្នាបាន។*

ដូចនេះយើងមានទំនាក់ទំនងជាមួយជនទោល កើតនៅសម័យសក្តិភូមិ ជាអ្នកចុះចាញ់... ប៉ុន្តែខ្លាំងមាំរឹងប៉ឹង ពោរពេញទៅដោយសីលធម៌ក្នុងខ្លួន។ គេទីទ័លក្រមែនតែមិនល្ងង់ខ្លៅ មិនពុក រលួយទេ។ គេពិតជាដូចក្នុងការរៀបរាប់រូបរាងអំពីមនុស្សក្លាហានហើយឧស្សាហ៍គួរឲ្យយើងទុកចិត្តបាន «

ជាមនុស្សដែលគួរឲ្យស្គាល់និងរាប់អាន» ។ យើងមិនត្រូវវាយតម្លៃតាមសំបកក្រៅដោយប្រញាប់ប្រញាល់ទេ ត្រូវប្រើភាពទន់ភ្លន់ដើម្បីទាក់ទាញគេ ព្រោះកាយវិការឬសំដីគ្រោតគ្រាតអាចធ្វើឲ្យគេភ័យស្លន់ស្លោ ឬធ្វើឲ្យគេថយឆ្ងាយពីយើង។

ប៉ុន្តែមានរឿងមួយទៀត៖ គេជាមនុស្សឆាប់រំភើប ឆាប់រំជួលចិត្តណាស់ គេមាននិស្ស័យជាសិល្បករ ជាអ្នកស្មោះត្រង់។ នេះជាលក្ខណសម្បត្តិពិសេសរបស់សាសន៍ខ្មែរ។ត្រង់នេះហើយដែលយើងត្រូវឆ្លៀតចាប់ឲ្យបាន ព្រោះជាខ្សែមនោសញ្ចេតនាដែលអាចកេះឲ្យរំភើបញាប់ញ័របាន ជាផ្លូវដែលយើងត្រូវដើរ ដើម្បីទៅឲ្យដល់ព្រលឹង ដល់បេះដូងរបស់គេ។ បើសម័យឥឡូវ ការចូលរួមក្នុងចលនាវិវដ្តដោយសាមគ្គីភាពពេញទាំងពិភពលោកនៃរាស្ត្រទាំងអស់ក្លាយទៅជាការចាំបាច់ជៀសមិនរួចទៅហើយ បើសិនការលាក់ខ្លួនរបស់ខ្មែរ ក្រោមបារមីព្រះនៅពេលមានសត្រូវ ជាការចាស់គំរឹលខ្វះផាសុខភាព ដែលតម្រូវឲ្យជ្រើសរើសទីតាំងថ្មីដែលស្របនឹងលក្ខណៈយុគថ្មី ការលេងផ្លូវចិត្តខាងលើនេះពិតជាមធ្យោបាយដែលយើងត្រូវប្រើ ដើម្បីឲ្យខ្មែរអាចស៊ាំបន្តិចម្តងៗតាមសេចក្តីប្រាថ្នា។

ជនអ្នកស្មោះត្រង់ជាអ្នកចូលចិត្តធ្វើការបញ្ចេញថ្វីដៃ។ដើម្បីធ្វើឲ្យព្រលឹងបុព្វបុរសរះចិញ្ចែងក្នុងចិត្តពួកគេ ប្រហែលជាខ្វះតែការជ្រោមជ្រែង ក្នុងពេលមួយ អំពីអ្នកមានចិត្តជាសាវ័កម្នាក់ចំពោះខ្មែរសព្វថ្ងៃប៉ុណ្ណោះ។គេអាចហ៊ានស្រមៃថា បើសិនជាខ្មែរនៅក្រោមដៃអ្នកដឹកនាំដូចជាលោកប៉ាវី Pavie ជាដើម មិនដឹងជាខ្មែរបានជឿនលឿនយ៉ាងណាទៅហើយទេ។ ក្រោមការនាំផ្លូវដោយស្លូតទន់ភ្លន់របស់លោកប៉ាវី វត្តអារាម ប្រហែលជាក្លាយទៅជាដងថ្លឹង ជាគំនាស់ក្នុងការអប់រំផ្នែកសង្គម ដល់ប្រជាជនមិនខានឡើយ។ យើងប្រហែលជាត្រូវពឹងទៅលើទីវត្តអារ៉ាមនេះហើយ បើសិនជាមិនទាន់ហួសពេល។

ដូច្នេះយើងត្រូវប្រើឱសថផ្សំជាពិសេសសម្រាប់ស្ថានការណ៍នេះ។ យើងត្រូវមានអំណត់ មានការគួរសម មានសច្ចធម៌គួរឲ្យទុកចិត្ត មានការយោគយល់អាណិតអាសូរ ត្រូវចំណាយពេលរៀនសូត្រឲ្យស្គាល់របៀបរស់នៅ របៀបគិតគូរ របៀបយល់ឃើញ របៀបតទប់ពិសេស របស់ប្រជាជនដែលនៅក្រោមការការពាររបស់យើង។ ជំនឿរបស់គេចំពោះអារក្សអ្នកតា ជាជំនួយធំ ក្នុងជីវិតគេ ដូច្នេះយើងត្រូវគោរពហើយឲ្យតម្លៃថែមទៀត។

7. <u>បញ្ឈប់វិវាទកម្មផ្នែកនយោបាយ រវាងរាស្ត្រក្នុងស្រុកទាំងពីរពួក (រាស្ត្រសញ្ជាតិខ្មែរ-រាស្ត្រសញ្ជាតិបារាំង) ដែលធ្វើឲ្យប្រទេសគ្រាំគ្រា ដែលបើកទ្វារចំហឲ្យអ្នកឱកាសនិយមឆ្លៀតកេង</u>

ចម្រាញ់ ធ្វើឲ្យជនអ្នកម្ចាស់ដី ម្ចាស់ស្រុកទទួលរងគ្រោះ ហើយបែរជាឲ្យចំណេញទៅចិនជាជនជាតិបរទេសទៅវិញ។

គេមិនអាចចាញ់បោក ឬធ្វើជាជឿតទៅទៀតថា យើងមានរដ្ឋបាល"ប្រយោល"មួយបានទេបើគេចង់និយាយអំពីម៉ាស៊ីនដែលយើងជាអ្នកកាន់ខ្សែបញ្ជាទាំងអស់នៅក្នុងដៃនេះ។ គ្មាននរណាអាចយកពាក្យថា "របបការពារឧបត្ថម ឬ របបប្រូតិចតូរ៉ា" ធ្វើជាការបានទេ នៅចំពោះមុខប្រជាជនដ៏អ័ភព្វដែល នៅពេលក្តៅក្រហាយខ្លាំង ពេលលំបាកវេទនាខ្លាំង បែរជាធ្វើបាតុកម្មដោយអង្គុយលុតជង្គង់ ឬនៅចំពោះព្រះភ័ក្ត្រព្រះរាជាចាស់ជរាដ៏កំសត់ដែលគេបានទម្លាប់បង្ខំឲ្យចុះព្រះហស្ថលេខាទាំងបិទព្រះនេត្រ។

*អ្នកណាក៏ដឹងដែរថា រាជកិច្ច ឬ សារលិខិត្រជាផ្លូវការទាំងប៉ុន្មាននៅក្នុងព្រះរាជវាំង គឺសុទ្ធតែត្រូវបានគេរៀបចំទុកជាមុនស្រេច ជាភាសាបារាំងផងនិងភាសាខ្មែរផង នៅកន្លែងលោកទេសាភិបាលបារាំង "ឡារ៉េស៊ីដង់ស៊ុប៉េរីយ័រ"។ តាមការពិតទៅ ការប្រកួតប្រជែងបញ្ចេញអំណាចនេះគ្រាន់តែជាការបំភ័ន្តភ្នែក ជារឿងប្រឌិតផ្នែកនយោបាយមួយប៉ុណ្ណោះដែលជួយឲ្យគេធ្វើអ្វី ក៏បានតាមចិត្ត ក្នុងនាមរបស់ស្តេចជាម្ចាស់ផែនដី។*

ដំណោះស្រាយមានតែពីរដែលសមហេតុសមផលៈឬមួយការគ្រប់គ្រងផ្នែករដ្ឋបាលដោយផ្ទាល់មិនលាក់លៀម ដូចនៅដែនកូសាំងស៊ីនដែលហាក់ដូចជាមានដំណើរការល្អគួរសម ឬមួយត្រឡប់ទៅកាន់"របបការពារនិយម" ប្រូតិចតូរ៉ា ដ៏ស្មោះចំពោះមែនពិត ឥតក្លែងក្លាយ ស្របទៅតាមតួនាទីរបស់របបនេះ។

របបការពារនិយមនេះនឹងនៅតែមានប្រយោជន៍ជាច្រើនជំនាន់ទៀតនៅក្នុងប្រទេសមួយនេះ ដែលមានភក្តីភាពដ៏ជ្រាលជ្រៅចំពោះស្តេចរបស់ខ្លួន។ ឯផ្នែកសង្គមរបស់គេវិញ ពួកយើងមិនសូវបានប្តូររូបភាពប៉ុន្មានទេ។លោកអាយម៉ូនីញេបានមានប្រសាសន៍ថា "លទ្ធិរាជាធិបតេយ្យគឺជានិមិត្តរូបរបស់ ពូជសាសន៍ដែលមានអាយុដ៏វែងនេះ"។ការបះបោរនៅឆ្នាំ១៩១៦បានបង្ហាញនូវភ័ស្តុតាងថ្មីមួយទៀតៈបើព្រះមហាក្សត្រដ៏ឈ្លាសវៃ គឺព្រះបាទស៊ីសុវត្ថិ ព្រះអង្គមិនបានធ្វើអន្តរាគមន៍ទាន់ពេលវេលាទេ យើងប្រហែលជាមិនអាចជៀសវាងការបង្ហូរឈាមក្នុងស្រុកពេលនោះបានទេមើលទៅ!។

ទោះបីយ៉ាងណា ស្ថានភាពសព្វថ្ងៃក៏មិនអាចបន្ធូរបន្ថយហួសពីសង្គ្រាមបានទេ។ អាណានិគមនេះសឹងតែត្រូវសើរើផ្លូវនយោបាយទាំងអស់ ដើម្បីរៀបចំគ្រឹះថ្មីៈ ពោលគឺត្រូវរៀបចាប់តាំងតែពី

គោលការណ៍ ឡើងទៅ។ទីនេះត្រូវរករូបមន្តមួយដែលពិបាកផ្សំ ហើយហ៊ានចាត់វិធានការដ៏ក្លាហានខ្លះ តាំងពីដំបូង។ លទ្ធផលចុងក្រោយត្រូវពឹងផ្អែកទាំងស្រុងទៅលើការជ្រើសរើសមនុស្សមកអនុវត្តកិច្ចការនេះ។ មានតែនៅក្នុងការងារធំៗរបស់អាណានិគម ដែលតួនាទីជាមេកើយមានចំណែកទូលំទូលាយខាងការផ្តួចផ្តើមគំនិត ទើបអ្នកដឹកនាំចំណានអាចបង្ហាញខ្លួន ទើបការជ្រើសរើសមនុស្សពិតជាលក្ខ័ណមិនអាចរំលងបានដើម្បីជោគជ័យនៅទីបញ្ចប់។

ក្រោយពេលដែលយើងបានយល់ច្បាស់នូវការពិតថា "យើងនឹងអាចយកឈ្នះទឹកចិត្តអ្នកដែលយើងត្រូវការពារបាន គឺអាស្រ័យលើសន្តានចិត្តស្មោះត្រង់ សប្បុរសធម៌ ជំនឿដ៏មុតមាំដែលហូរចេញពីធម្មជាតិពិតៗរបស់យើងជាអ្នកការពារ" នៅពេលនោះ ការគ្រប់គ្រងផ្នែករដ្ឋបាលដ៏ឈ្លាសវៃនេះនឹងបានទទួលអ្វីៗគ្រប់យ៉ាងដែលយើងចង់បាន ដែលយើងរំពឹងរង់ចាំ ក្នុងនាមប្រទេសបារាំងអំពីស្តេចខ្មែរមួយអង្គដែលចាំតែសម្របទៅតាមស្ថានភាពនៃសម័យថ្មី ព្រោះអីព្រះអង្គមិនមានព្រះតម្រិះថាយើងមកជិះជាន់ទេ គឺយើងគ្រាន់តែមកជួយផ្តល់យោបល់ទ្រង់ ជួយបង្ហាញផ្លូវ ជួយគ្រប់គ្រង យើងមិនមែនមកបំពានលើបូរណភាពព្រះអង្គជាដាច់ខាត !

❖

នៅពេលបញ្ចប់ការសរសេរកត់ត្រា ស្តីអំពីប្រជាជននៃប្រទេសតូចមួយ ដែលបានទទួលការឈឺចាប់តែ សុខចិត្តបិទមាត់ធ្វើគ ព្រោះតែមកពីយើងបានក្បត់ចំពោះការទុកចិត្តរបស់គេនេះ ខ្ញុំត្រូវបកស្រាយដោយសង្កត់បន្ថែមលើការពិចារណាមួយ ៖

អ្នកធ្វើនយោបាយឈ្លាសវៃក្តី អ្នកប្រាជដែលគេទទួលស្គាល់គ្រប់ផ្នែកទាំងអស់នៃនវិទ្យាក្តី មិនដែលញញើតញញើមនឹងប្រកាសថា"សិទ្ធិទីមួយដែលពលរដ្ឋណាមួយអាចទាមទារបានដើម្បីរស់ គឺ ត្រូវមានសម្បទាអាចការពារជិវិតរបស់ខ្លួននៅក្នុងការប្រកួតប្រជែងស្លាប់រស់រវាងពូជសាសន៍"។ ក៏ប៉ុន្តែប្រវត្តិសាស្ត្រ ហាក់ដូចជាបង្ហាញនូវរូបភាពជាក់ស្តែងមិនអាចបដិសេធបានថា ប្រទេសកម្ពុជាដ៏កំសត់ បានទទួលការជួយសង្គ្រោះអំពីប្រទេសបារាំងនៅចំពេលដែលខ្លួនគេ ជិតនឹងដាច់ខ្យល់ទៅហើយ។ដូច្នេះហើយ តើចាំបាច់ទៅអូសបន្លាយពីមនោសញ្ចេតនាឥតបានការស្អីទៀត ?ជារឿងសោកស្តាយគ្មានប្រយោជន៍ ! គេមិនអាចប្រោះខ្មោចឲ្យរស់ឡើងវិញបានទេ !

ឃើញហើយឬនៅ ការសំអាងដ៏គួរឲ្យខ្លាច ការវិនិច្ឆ័យបែបវិទ្យាសាស្ត្រដែលគេ មិនអាចប្រឆាំង ឬបកក្រោយបាននេះ នៅជំនាន់យើង។ កាលណាមានគេទទួលស្គាល់មតិរបៀបនេះហើយ

អ្នកត្រូវទោសជៀសមិនផុតអំពីការវិនាសបានទេ។ ពីក្រោយគេ នៅសល់តែការរឿងឆ្ងល់បន្តិចបន្តួច ដែលតែងពាក់ព័ន្ធនឹងពូជសាសន៍ដែលបានបាត់រូបជាទូទៅតែប៉ុណ្ណោះ។ លោកដែលត្រូវការពារគេ បែរជានិយមតែការអនុវត្តងាយស្រួល និយមតែរឿងរ៉ាវដែលអាចដោះស្រាយបានភ្លាមៗ ដូចនេះ លោកនោះនឹងឃ្លាតឆ្ងាយពីមនុស្ស ដែលគ្មានសារៈសំខាន់ចំពោះលោក។ មហាជនដែលសម្លឹង មើលមក ទោះបីគេមានសប្បុរសធម៌ក៏ជាជនសាមញ្ញ មិនសន្សំរឿង ឆាប់ជឿការបកស្រាយជាចំហ ទូទៅ ហេតុនេះហើយគេមិនឲ្យខាតពេលវេលាទៅជួយជំរុញការសាកល្បងអនុវត្តផ្ទុយពីនេះទេ។

ក៏ប៉ុន្តែ ទោះបីថាយើងត្រូវនៅក្នុងកម្រិតរង្វង់វិជ្ជមាន រង្វង់ដែលគិតតែប្រយោជន៍ តើបញ្ហានេះមាន ភាពសាមញ្ញយ៉ាងដូច្នេះមែនឬ ? ភាពទន់ជ្រាយរបស់ចក្រភពទាំងឡាយតើអាចលាយឡំជាមួយនឹង ភាពទន់ជ្រាយ

របស់ប្រជាជនលើលោកនេះបានទេ ?

&&&&&&&&&&&